APD BANK
ASIA-PACIFIC DEVELOPMENT BANK

# របាយការណ៍ប្រចាំឆ្នាំ ២០២១

## មាតិការ


៤ សារពីនាយកប្រតិបត្តិ

៦ អំពីធនាគារ អេភីឌី
- ព័ត៌មានអំពីធនាគារ
- ចក្ខុវិស័យ បេសកកម្ម គុណតម្លៃស្នូល

៨ គណៈគ្រប់គ្រង

១៦ ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការគ្រប់គ្រង

១៨ រចនាសម្ព័ន្ធរៀបចំ

២០ ការបង្ហាញសមិទ្ធផលការងារ
- សង្ខេបស្ថានភាពហិរញ្ញវត្ថុសំខាន់ៗ
- សង្ខេបស្ថានភាពហិរញ្ញវត្ថុ

២២ ផលិតផល និងសេវាកម្ម

២៦ ការិយាល័យកណ្តាល & សាខាថ្មី

៣០ របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុង

៥៦ របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម
- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
- របាយការណ៍របស់សវនករឯករាជ្យ
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
- របាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ
- របាយការណ៍បម្រែបម្រួលមូលធន
- របាយការណ៍លំហូរសាច់ប្រាក់
- កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ



សារពី
# នាយកប្រតិបត្តិ

## ទិដ្ឋភាពទូទៅក្នុងឆ្នាំ២០២១

វាមិនមែនជាអាថ៌កំបាំងទេ ដែលថាឆ្នាំ២០២១ គឺជាឆ្នាំដ៏លំបាក ដោយសារជំងឺកូវីដ-១៩នៅបន្តវាយប្រហារទូទាំងសកលលោក រួមទាំងសេដ្ឋកិច្ចកម្ពុជាផងដែរ។ យើងទាំងអស់គ្នាត្រូវសម្របខ្លួនទៅនឹងរបៀបរស់នៅ និងរបៀបធ្វើការបែបថ្មីក្នុងអំឡុងពេលដែលពោរពេញដោយភាពមិនជាក់លាក់ និងត្រូវរក្សាគម្លាត។ ខណៈដែលគ្រប់វិស័យ និងសេដ្ឋកិច្ចត្រូវទទួលរងផលប៉ះពាល់ ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក បានពង្រឹងខ្លួនឯងឱ្យកាន់តែរឹងមាំ និងមានភាពធនក្នុងអំឡុងពេលជំងឺកូវីដ-១៩កំពុងរាលដាល។ យើងបានឃើញពីការរីកចម្រើនកាន់តែខ្លាំងលើផ្នែកគន្លឹះមួយចំនួន រួមមានទ្រព្យសកម្មសរុប ប្រាក់បញ្ញើ និងអតិថិជន។

យើងបានបង្ហាញ នូវសមិទ្ធផលដែលយើងអាចសម្រេចបានក្នុងអំឡុងពេលជំងឺរាតត្បាតនេះ នៅពេលដែលយើងទុកតម្រូវការរបស់អតិថិជនជាស្នូលនៃអ្វីដែលយើងធ្វើ។ យើងបានរៀបចំយុទ្ធសាស្ត្រឡើងវិញដោយយកទំនាក់ទំនង និងការប្រាស្រ័យទាក់ទងជាមួយអតិថិជនជាអាទិភាពចម្បង ដែលអាចឱ្យយើងបន្តគាំទ្រដល់ពួកគេក្នុងអំឡុងពេលដ៏ច្របូកច្របល់នេះ។

> **ជម្រើសធនាគារទៅអនាគត**
>
> ដោយទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ឱ្យធ្វើប្រតិបត្តិការជាធនាគារពាណិជ្ជពេញលេញក្នុងឆ្នាំ ២០១៩ និងមានដើមទុនចុះបញ្ជីរហូតដល់ ៧៧,៤៩ លានដុល្លារអាមេរិក ធនាគារ អេភីឌី បានរីកចម្រើនគួរឱ្យកត់សម្គាល់លើផ្នែកគន្លឹះមួយចំនួន។ ដោយប្រៀបធៀបកំណើនក្នុងឆ្នាំ២០២១ ទៅនឹងឆ្នាំ២០២០ យើងមានទ្រព្យសកម្មកើនឡើង ៧៣% ប្រាក់បញ្ញើកើនឡើង ១២៥% ហើយកម្ចី និងបុរេប្បទានកើនឡើង ៩១%។

មហិច្ឆតាចម្បងរបស់យើងក្នុងការធ្វើឱ្យសេវាធនាគារកាន់តែងាយស្រួល និងខិតទៅកាន់តែកៀកអតិថិជនរបស់យើងត្រូវបានរៀបចំឡើងតាមរយៈការពង្រីកសាខាទៅតំបន់ដែលមានចរាចរណ៍ច្រើនជាងគេនៅរាជធានីភ្នំពេញ។ ការពង្រីកសាខានេះ នឹងអនុញ្ញាតឱ្យយើងផ្តល់សេវា និងបទពិសោធន៍ដ៏ពិសេសដល់អតិថិជន និងអនាគតអតិថិជនរបស់យើង។ ទន្ទឹមនឹងការពង្រីកសាខា យើងបានបង្កើតប្រព័ន្ធធនាគារស្នូល និងកម្មវិធីទូរសព្ទដោយមានគោលដៅធ្វើឱ្យសេវាធនាគារសម្រាប់អតិថិជនរបស់យើងក្លាយជាលក្ខណៈឌីជីថល។ អតិថិជនយើងនឹងអាចគ្រប់គ្រងហិរញ្ញវត្ថុរបស់ពួកគេនឹងម្រាមដៃរបស់ពួកគេ។

ខ្ញុំរីករាយ និងរំភើបហួសពីការស្មាន ដែលធនាគារ អេភីឌី អាចប្រកួតប្រជែងលើទីផ្សារដោយផលិតផល និងបច្ចេកវិទ្យាសម្រាប់អតិថិជនទាំងក្នុង និងក្រៅប្រទេស។

## កំណើនអាជីវកម្ម

ធនាគារ អេភីឌី បានខិតខំប្រឹងប្រែងឥតឈប់ឈរ ដើម្បីអត្ថប្រយោជន៍របស់អតិថិជនក្នុងគ្រប់ដំណាក់កាលនៃព្រឹត្តិការណ៍ជីវិតរបស់ពួកគេ។ នៅចុងឆ្នាំ២០២១ ប្រាក់បញ្ញើសរុបនៅធនាគារយើងបានកើនឡើងរហូតដល់ជាង ២០៦ លានដុល្លារអាមេរិក ហើយឥណទាន និងបុរេប្រទានដុលប្រចាំឆ្នាំ កើនឡើងដល់ជាង ២៤៩ លានដុល្លារអាមេរិក។ ធនាគារបានសម្រេចសមិទ្ធផលហួសពីគោលដៅគន្លឹះទាំងអស់របស់ខ្លួន និងបានកត់ត្រាចំណេញមុនកាត់ពន្ធលើសពី ៥ លានដុល្លារអាមេរិក ដែលកើនឡើង៤០.៨% ពីឆ្នាំ២០២០ ដល់២០២១។

ជាមួយនឹងសមិទ្ធផលវិជ្ជមាន និងគួរឱ្យកត់សម្គាល់ទាំងនេះ ធនាគាររំពឹងដោយសុទិដ្ឋិនិយមថា ឆ្នាំ២០២២ នឹងជាឆ្នាំនៃការរីកចម្រើនដ៏គួរឱ្យទន្ទឹងរង់ចាំ និងគួរឱ្យចងចាំ។ យើងសង្ឃឹមថានឹងទទួលបានចំណែកទីផ្សារកាន់តែច្រើន ដោយផ្តោតលើទំនាក់ទំនងដ៏រឹងមាំជាមួយនឹងអតិថិជនយើង និងខ្សែចង្វាក់អាជីវកម្មរបស់ពួកគេ ដោយលើកកម្ពស់សេវាបន្ថែមតាមរយៈបណ្តាញប្រតិបត្តិការធនាគាររបស់យើង ហើយពង្រីកគុណតម្លៃដ៏ពិសេសនៃបណ្តាញអាស៊ានរបស់យើងទៅអតិថិជនជាក្រុមហ៊ុនរបស់យើង។

## ធនធានមនុស្សរបស់យើង

ដោយអនុវត្តការរក្សាអនាម័យស្អាត និងការរក្សាគម្លាតនៅកន្លែងធ្វើការរបស់យើង ជំងឺកូវីដ-១៩លែងជាការគំរាមកំហែងដល់ប្រតិបត្តិការអាជីវកម្មរបស់យើងហើយ។ បុគ្គលិករបស់យើងបានចាក់វ៉ាក់សាំងគ្រប់ដុសតាមការតម្រូវរបស់រាជរដ្ឋាភិបាល និងអាចសម្របខ្លួនទៅនឹងបរិយាកាសការងារថ្មីដែលបំពាក់ដោយបច្ចេកវិទ្យា និងការការពារសុវត្ថិភាពត្រឹមត្រូវ។ ដើម្បីការរីកចម្រើនកាន់តែរហ័ស និងការបំពេញតម្រូវការរបស់អតិថិជន ធនាគារ អេភីឌី បានបង្កើនកម្លាំងពលកម្មរបស់ខ្លួនលើសពីទ្វេរដងក្នុងឆ្នាំ២០២១។ មានបុគ្គលិករហូតដល់ ១១០ នាក់ (ដែលបានកើនឡើង ១២០%) បានចូលមកកាន់មុខតំណែងខុសៗគ្នា ដែលក្នុងនោះមាន ៤៥,៤៥% ជាយុវជន យុវនារីជំនាន់ក្រោយ។
កម្មវិធីបណ្តុះបណ្តាលទេពកោសល្យ ដែលហៅថា “កម្មវិធីបណ្តុះបណ្តាលការគ្រប់គ្រង និងសហគ្រិនភាព” ត្រូវបានរៀបចំឡើងក្នុងគោលបំណងប្រមូលផ្តុំអ្នកមានទេពកោសល្យដែលនឹងក្លាយជាអ្នកដឹកនាំក្នុងស្ថាប័នមួយនេះ។ យើងជឿជាក់លើគុណភាព និងសមត្ថភាពរបស់បុគ្គលិកយើងក្នុងការកសាងធនាគារដែលរីកចម្រើនជាមួយនឹងអតិថិជន និងបណ្តុះទំនុកចិត្តពីអតិថិជន។

## ការវិនិយោគលើសហគមន៍

ការផ្តល់ឱ្យសហគមន៍វិញ គឺជាជំនឿ និងជាអាទិភាពមួយក្នុងអាជីវកម្មរបស់យើង។ យើងបានផ្តោតទៅលើវិស័យអប់រំ បរិស្ថាន និងសុខាភិបាល ដើម្បីធានាភាពសម្បូរសប្បាយនៃសហគមន៍ដែលយើងចូលរួម។ កាលពីឆ្នាំកន្លងទៅ យើងបានគាំទ្រដល់ក្រសួងសុខាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ តាមរយៈការឧបត្ថម្ភម៉ាស របាំងមុខ និងសម្ភារវេជ្ជសាស្ត្រផ្សេងៗទៀត។ យើងបានលើកកម្ពស់បរិយាកាសរៀនសូត្រ និងអនាម័យសម្រាប់សិស្សានុសិស្សជាង ៥០០នាក់ គ្រូបង្រៀន និងសហគមន៍នៃបឋមសិក្សានៅតំបន់ជនបទក្នុងខេត្តកំពង់ចាម។ ទន្ទឹមនឹងការបន្តរីកចម្រើនឆាប់រហ័សរបស់យើង យើងនឹងបង្កើតឥទ្ធិពលវិជ្ជមានកាន់តែច្រើនលើសង្គមជាតិយើង ព្រមទាំងឱ្យបុគ្គលិកកាន់តែច្រើនចូលរួមក្នុងឆ្នាំខាងមុខៗតាមរយៈគម្រោងវិនិយោគលើសហគមន៍ជាច្រើនរបស់យើង។

## ទិសដៅទៅអនាគត

យើងជឿជាក់ដោយសុទិដ្ឋិនិយមថា សេដ្ឋកិច្ចកម្ពុជាយើងត្រូវបានស្តារឡើងវិញបណ្តើរៗពីជំងឺរាតត្បាត ដោយពង្រឹងកឡានុវត្តភាពកាន់តែច្រើន មិនត្រឹមតែវិស័យធនាគារនោះទេ វិស័យផ្សេងៗទៀតក៏ដូចគ្នាដែរ។ ធនាគារ អេភីឌី តែងតែត្រៀមខ្លួនរួចជានិច្ចដើម្បីប្រកួតប្រជែងក្នុងទីផ្សារ ដោយផ្តោតលើការអភិវឌ្ឍសេវាធនាគារតាមអ៊ីនធើណេត និងកម្មវិធីទូរសព្ទ។ ផលិតផល និងសេវាកម្មថ្មីៗត្រូវបានរៀបចំឡើងដើម្បីបំពេញតម្រូវការរបស់អតិថិជន ម៉ាស៊ីន ATM ឆ្លាតវៃ និងសេវាកាត ការពង្រីកបណ្តាញសាខាកាន់តែច្រើន និងការពង្រឹងទំនាក់ទំនងជាមួយនឹងអតិថិជនទាំងក្រុមហ៊ុន និងបុគ្គល។

មិនចាំបាច់សង្ស័យឡើយ ការរីកចម្រើនយ៉ាងរហ័សរបស់យើងត្រូវបានទ្រទ្រង់ដោយតម្រូវការផលិតផល និងសេវាកម្មធនាគារដែលកើនឡើងក្នុងព្រះរាជាណាចក្រកម្ពុជា។ ហើយវាក៏បង្កើនកម្រិតអត្ថប្រយោជន៍របស់វិនិយោគិនក្នុងស្រុក និងបរទេសផងដែរ។

តាងនាមឱ្យធនាគារ អេភីឌី ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ធនាគារជាតិនៃកម្ពុជា អតិថិជនយើង ភាគទុនិក និងអ្នកដែលពាក់ព័ន្ធទាំងអស់ សម្រាប់ការបន្តផ្តល់ទំនុកចិត្ត ការគាំទ្រ និងឆន្ទៈក្នុងការសហការជាដៃគូជាមួយនឹងធនាគារ អេភីឌី ក្នុងដំណើររីកចម្រើនរយៈពេលវែងរបស់ធនាគារ។ យើងនឹងបន្តពង្រឹងខ្លួនឯង និងខិតខំដើម្បីកសាងធនាគារ អេភីឌី ដែលប្លែកខុសពីគេ។

# អំពី ធនាគារ អេភីឌី

ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន (ធនាគារ អេភីឌី) ត្រូវបានបង្កើតឡើងនៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ជាធនាគារឯកទេស ដោយទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា (“NBC” ឬ “ធនាគារកណ្តាល”)។

នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ ធនាគារ អេភីឌី បានទទួលការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាឱ្យអភិវឌ្ឍខ្លួនទៅជាធនាគារពាណិជ្ជ។ ធនាគារ អេភីឌី បានបង្កើនដើមទុនចុះបញ្ជីរបស់ខ្លួនរហូតដល់ ៧៧,៤៩ លានដុល្លារអាមេរិក។

ធនាគារ អេភីឌី ធ្វើប្រតិបត្តិការក្រោមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយរបស់ធនាគារជាតិនៃកម្ពុជា។

## ព័ត៌មានអំពីធនាគារ

លេខចុះបញ្ជី ៖
០០០០៧៥១៤

ការិយាល័យចុះបញ្ជី ៖
លេខ ១៣២ ផ្លូវ ២៩៤ កែងមហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ភាគហ៊ុនិក ៖
លោក វង្ស ពេជ្រ
លោក ឡាវ អៀវចុង




## បេសកកម្ម

ធនាគារ អេភីឌី ប្តេជ្ញាផ្តល់សេវាកម្មហិរញ្ញវត្ថុប្រកបដោយគុណភាពដែលនឹងបង្កើតតម្លៃ និងលើកកម្ពស់ជីវភាពរបស់អតិថិជន និយោជិត ភាគទុនិក និងសហគមន៍ ដែលយើងបម្រើឱ្យ។

ដើម្បីសម្រេចបេសកកម្មនេះ ធនាគារនឹងបន្តផ្តោតលើអតិថិជន និងរក្សាស្តង់ដាររបស់យើង ដែលក្តោបបញ្ចូលគ្នានូវសច្ចៈភាព ភាពជំនាញ និងភាពជាដៃគូ។

## ចក្ខុវិស័យ

ចក្ខុវិស័យរបស់ធនាគារ អេភីឌី គឺក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុឈានមុខគេ ដែលផ្តល់នូវសេវាមានគុណភាព ដើម្បីបំពេញក្តីស្រមៃរបស់ប្រជាជនគ្រប់រូបទូទាំងពិភពលោក។

## គុណតម្លៃស្នូល

គុណតម្លៃស្នូលទាំងប្រាំពីររបស់ធនាគារ គឺ APDBANK ដែលមានអត្ថន័យដូចតទៅ៖

**១ គណនេយ្យភាព៖**

យើងឆ្លើយតបទៅនឹងការសន្យាដែលយើងបានធ្វើចំពោះអតិថិជនយើង។

**២ ចំណង់ចំណូលចិត្ត៖**

ចំណង់ចំណូលចិត្ត មានសារៈសំខាន់ណាស់ក្នុងការសម្រេចសមិទ្ធផលរបស់យើង។ យើងបានដាក់ស្មារតីទៅក្នុងការងាររបស់យើង ហើយដិតជាប់ក្នុងបុគ្គលិកលក្ខណៈរបស់យើង ដើម្បីសម្រេចគោលដៅរបស់អតិថិជនយើង។

**៣ ភាពយកចិត្តទុកដាក់៖**

យើងយល់ថាអ្វីជាអាទិភាព ហើយយើងប្តេជ្ញាបម្រើជូនឱ្យអស់ពីសមត្ថភាព។

**៤ សប្បុរសធម៌៖**

យើងផ្តោតលើការរក្សា និងការពង្រឹងសុខមាលភាពរបស់អតិថិជនយើង។

**៥ សមិទ្ធផល៖**

ទទួលស្គាល់ និងអបអរសាទរចំពោះការរួមចំណែកដែលមានអត្ថន័យ និងការបំពេញការងារលេចធ្លោរ។

**៦ របៀបរៀបរយ៖**

របៀបរៀបរយ គឺជាសញ្ញានៃសណ្តាប់ធ្នាប់ និងវិន័យដែលមានឥទ្ធិពលវិជ្ជមានលើប្រសិទ្ធភាព ក៏ដូចជាចំណាប់អារម្មណ៍ទូទៅ និងជាធាតុផ្សំនៃកិត្តិយស។

**៧ ចំណេះដឹង៖**

យើងខ្ញុំជឿជាក់លើរបត់ចំណេះដឹង និយោជិតជំនាញ បច្ចេកវិទ្យាទាន់សម័យ ការច្នៃប្រឌិត និងការបង្កើតថ្មីក្នុងសកម្មភាពរបស់យើង។



# គណៈគ្រប់គ្រង



លោក Thoo ជានាយកប្រតិបត្តិ គាត់មានបទពិសោធន៍ និងចំណេះដឹងជាច្រើនក្នុងវិស័យសេវាហិរញ្ញវត្ថុ រយៈពេល ៣១ ឆ្នាំហើយ។ បទពិសោធន៍របស់គាត់ គ្របដណ្តប់លើផ្នែកជាច្រើន រួមមាន ផ្នែកអភិវឌ្ឍអាជីវកម្ម ផ្នែកលក់និងទីផ្សារ និងផ្នែកផ្តល់កម្ចី ហើយអ្វីដែលសំខាន់បំផុត គឺផ្នែកគម្រោងលំនៅដ្ឋានក្នុងតម្លៃសមរម្យ និងការផ្តល់ហិរញ្ញប្បទានដល់អ្នកទិញលំនៅដ្ឋាន (end financing) នៅប្រទេសម៉ាឡេស៊ី។

*លោក Thoo មានសញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម (ទីផ្សារ)។ គាត់ទទួលបានការទទួលស្គាល់នូវជំនាញវិជ្ជាជីវៈឥណទានចុះបញ្ជី (Certified Credit Professional ឬ CCP) ពី Asia Institute of Chartered Bankers (អតីត Institute Bank-Bank Malaysia) ក្នុងឆ្នាំ២០០៤។ គាត់មានបទពិសោធន៍ទូលំទូលាយផ្នែកឥណទាន ហើយគាត់ជាអ្នកសម្របសម្រួលដែលមានការទទួលស្គាល់ពី OMEGA Performance របស់សហរដ្ឋអាមេរិក លើការវាយតម្លៃជំនាញឥណទាន និងជាគ្រូបង្វឹកនាយកប្រតិបត្តិជំនាញ (Certified Professional Executive Coach Manager) ដែលមានការទទួលស្គាល់ពី Cambridge Association of Managers ផងដែរ។*

**THOO KIM SENG**
**នាយកប្រតិបត្តិ**



លោក Chua បច្ចុប្បន្នជានាយកប្រតិបត្តិរងរបស់ធនាគារ។ គាត់មានបទពិសោធន៍ ជាង ១៨ ឆ្នាំក្នុងវិស័យហិរញ្ញវត្ថុជាមួយនឹងធនាគារឈានមុខគេនៅប្រទេសម៉ាឡេស៊ី និងមានបទពិសោធន៍ខាងគម្រោងលំនៅដ្ឋានក្នុងតម្លៃសមរម្យ និងហិរញ្ញប្បទានដល់អ្នកទិញលំនៅដ្ឋាននៅប្រទេសម៉ាឡេស៊ី និងក្រុមហ៊ុនពហុជាតិដែលមានកេរ្តិ៍ឈ្មោះជាច្រើន។ គាត់មានបទពិសោធន៍ទូលំទូលាយក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងការរៀបចំផែនការអាជីវកម្ម។

*គាត់ជាគណនេយ្យករចុះបញ្ជី (Association of Chartered Certified Accountants ឬ ACCA) ពីប្រទេសអង់គ្លេស។ ហើយគាត់មានសញ្ញាប័ត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម ពី University of Malborne ប្រទេសអូស្ត្រាលី។ គាត់ក៏មានការទទួលស្គាល់ពី OMEGA ដែរ ហើយមានបទពិសោធន៍ច្រើនខាងឥណទាន។*

**CHUA THIAM YEW**
**នាយកប្រតិបត្តិរង**



លោក ពិសាល បច្ចុប្បន្ន ជាប្រធាននាយកដ្ឋានប្រតិបត្តិការ ដែលទទួលខុសត្រូវលើប្រតិបត្តិការទូទៅរបស់ធនាគារ។ គាត់ជាសមាជិកស្នូលក្នុងគណៈគ្រប់គ្រងរបស់ធនាគារ។ គាត់ចូលធ្វើការនៅធនាគារ អេភីឌី តាំងពីថ្ងៃទីមួយដែលធនាគារបើកដំណើរការ ក្នុងខែមិថុនា ឆ្នាំ២០១៦ ក្នុងមុខតំណែងជា អ្នកគ្រប់គ្រងផ្នែកប្រតិបត្តិការ។ គាត់មានបទពិសោធន៍ទូលំទូលាយក្នុងមុខងារ និងតួនាទីជាច្រើនខុសៗគ្នា តាំងពីថ្នាក់ទាបដល់ថ្នាក់គ្រប់គ្រង។ ផ្នែកទាំងនោះរួមមានផ្នែកសេវាអតិថិជន ផ្នែកលក់ និងទីផ្សារ ផ្នែកប្រតិបត្តិការ ផ្នែកកម្ចី/ឥណទាន និងផ្នែកគ្រប់គ្រងសាខា ក្នុងវិស័យធនាគារ។

*គាត់ទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ និងបរិញ្ញាបត្រផ្នែកគ្រប់គ្រង ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅរាជធានីភ្នំពេញ។*

**ស្វាយ ពិសាល**
**ប្រធាននាយកដ្ឋានប្រតិបត្តិការ**







លោក តេច ជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងរតនាគារ ដែលទទួលខុសត្រូវលើការរៀបចំផែនការ ការអនុវត្ត និងការគ្រប់គ្រងសកម្មភាពហិរញ្ញវត្ថុ និងរតនាគារទាំងអស់របស់ធនាគារ។ គាត់គឺជាសមាជិកស្នូលមួយរូប ដែលចូលធ្វើការនៅធនាគារ អេភីឌី តាំងពីឆ្នាំ២០១៧ ក្នុងមុខតំណែងជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង។ គាត់មានបទពិសោធន៍ទូលំទូលាយក្នុងផ្នែកសវនកម្មលើវិស័យជាច្រើន ដូចជា ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធានារ៉ាប់រង កម្មន្តសាល ក្រុមហ៊ុន និងអង្គការក្រៅរដ្ឋាភិបាល។

*គាត់ជាគណនេយ្យករចុះបញ្ជី (ACCA) របស់សមាគមសម្ព័ន្ធញាតិនៃសមាគមគណនេយ្យករអង់គ្លេស។ គាត់ទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបរិញ្ញាបត្រផ្នែកអប់រំ ពីវិទ្យាស្ថានភាសាបរទេស។*

**ឈី តេច**
**ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងរតនាគារ**



លោកស្រី សូ ធីតា ជាប្រធាននាយកដ្ឋានធនធានមនុស្ស និងបណ្តុះបណ្តាល ដែលទទួលខុសត្រូវលើការដឹកនាំ និងគ្រប់គ្រងលើការជ្រើសរើសបុគ្គលិក (talent acquisition) ប្រតិបត្តិការធនធានមនុស្ស ការគ្រប់គ្រងប្រាក់ឈ្នួល និងអត្ថប្រយោជន៍ គោលនយោបាយ និងនីតិវិធីធនធានមនុស្ស ការគ្រប់គ្រងការបំពេញការងារ ការជួលនិយោជិត ទំនាក់ទំនងការងារ និងទំនាក់ទំនងនិយោជិត ការបង្ហាត់បង្រៀន ការបណ្តុះបណ្តាល និងការអភិវឌ្ឍ ក៏ដូចជាការអនុវត្តបេសកកម្ម និងយុទ្ធសាស្ត្រស្វែងរកបុគ្គលិកប៉ិនប្រសប់ជូនធនាគារ។ គាត់ចូល អេភីឌី ក្នុងខែធ្នូ ឆ្នាំ២០២០។ គាត់មានបទពិសោធន៍ទូលំទូលាយលើគ្រប់ផ្នែកទាំងអស់ក្នុងការគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស។

*គាត់ជាអ្នកជំនាញបណ្តុះបណ្តាលចុះបញ្ជី (Certified Training Professional) ពី Finance Accreditation Agency របស់ប្រទេសម៉ាឡេស៊ី និង Harvard Business ManageMentor របស់សហរដ្ឋអាមេរិក។ គាត់ទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកគ្រប់គ្រងអាជីវកម្មពីសាកលវិទ្យាល័យជាតិគ្រប់គ្រង និងសញ្ញាបត្រផ្នែកទំនាក់ទំនងអាជីវកម្មពីសាកលវិទ្យាល័យបញ្ញាសាស្ត្រ នៅកម្ពុជា។*

**សូ ធីតា**
**ប្រធាននាយកដ្ឋានធនធានមនុស្ស និងបណ្តុះបណ្តាល**



លោក គង់ហេង ជាប្រធាននាយកដ្ឋានយុទ្ធសាស្ត្រ និងផែនការ ដែលទទួលខុសត្រូវលើការផ្តួចផ្តើមបង្កើតផលិតផលថ្មី និងរៀបចំយុទ្ធសាស្ត្រអាជីវកម្ម ដើម្បីពង្រីកប្រតិបត្តិការអាជីវកម្មរបស់ធនាគារ។ គាត់ចូលធ្វើការនៅធនាគារ អេភីឌី តាំងពីខែមីនា ឆ្នាំ២០២០ ក្នុងមុខតំណែងជាប្រធាននាយកដ្ឋានយុទ្ធសាស្ត្រ។ គាត់មានបទពិសោធន៍ទូលំទូលាយក្នុងមុខងារ និងតួនាទីជាច្រើនខុសៗគ្នា ចាប់ពីថ្នាក់ទាបដល់ថ្នាក់គ្រប់គ្រងក្នុងវិស័យធនាគារ។

*គាត់ទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម និងសញ្ញាបត្របរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យមេគង្គកម្ពុជា នៅរាជធានីភ្នំពេញ។*

**អ៊ឹង គង់ហេង**
**ប្រធាននាយកដ្ឋានយុទ្ធសាស្ត្រ និងផែនការ**



លោកស្រី ថៃ ស្រីមុំ ជាប្រធាននាយកដ្ឋានរដ្ឋបាល ដែលទទួលខុសត្រូវលើការដឹកនាំ និងគ្រប់គ្រងលទ្ធកម្មរដ្ឋបាល និងយុទ្ធសាស្ត្រ ដែលត្រូវស្របតាមនីតិវិធី ប្រព័ន្ធ និងវិធីសាស្ត្ររៀបចំដំណើរការ ក៏ដូចជាធ្វើការសម្រេចសំខាន់ៗពាក់ព័ន្ធនឹងការទិញផលិតផល និងបរិក្ខារ ដើម្បីវិភាគព័ត៌មាន និងស្វែងរកអ្នកផ្គត់ផ្គង់ដែលល្អបំផុត ផ្តល់តម្លៃសមរម្យ និងផលិតផលល្អ។ គាត់ចូល អេភីឌី ក្នុងខែមីនា ឆ្នាំ២០២០។ គាត់មានបទពិសោធន៍ទូលំទូលាយក្នុងវិស័យធនាគារ។

*គាត់ទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ពីវិទ្យាស្ថានវ៉ាន់ដាគណនេយ្យ។ គាត់ក៏បានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញជាច្រើន ដូចជាពន្ធដារ ការគ្រប់គ្រងធនធានមនុស្ស និងភាពជាអ្នកដឹកនាំផងដែរ។*

**ថៃ ស្រីមុំ**
**ប្រធាននាយកដ្ឋានរដ្ឋបាល**

លោក ចុល លីណា ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលទទួលខុសត្រូវគ្រប់គ្រងទូទៅលើសវនកម្ម និងការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។ គាត់ចូលធ្វើការនៅ អេភីឌី ក្នុងឆ្នាំ២០១៩ ហើយក្នុងឆ្នាំដដែលនោះ គាត់ទទួលបានការទទួលស្គាល់ជាផ្លូវការពីធនាគារជាតិនៃកម្ពុជា ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង។ គាត់មានបទពិសោធន៍ទូលំទូលាយខាងសវនកម្ម។

*គាត់កំពុងសិក្សាកម្មវិធី ACCA របស់អង់គ្លេស នៅសាលា CamEd។ គាត់ទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។ លើសពីនេះទៅទៀត គាត់ទទួលបានអាហារូបករណ៍រយៈពេល ៤ ឆ្នាំ ផ្នែកគ្រប់គ្រង ពីអង្គការបារាំងមួយ។*

**ចុល លីណា**
**ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង**





កញ្ញា ស៊ូ សុជា ជាប្រធាននាយកដ្ឋានសេវាធនាគារឌីជីថល ដែលទទួលខុសត្រូវលើផលិតផលធនាគារឌីជីថល។ គាត់មានប្រវត្តិការងារខាងផលិតផលសេវាធនាគារឌីជីថលធនាគារតាមអនឡាញ និងតាមទូរស័ព្ទចល័ត ហើយគាត់មានបទពិសោធន៍ក្នុងការចាត់ចែងគម្រោង និងកម្មវិធីផ្តួចផ្តើមមួយចំនួនក្នុងការផ្លាស់ប្តូរសេវាហិរញ្ញវត្ថុ ពីសេវាធនាគារប្រពៃណីមកសេវាធនាគារតាមអ៊ីនធើណិត និងទូរស័ព្ទចល័ត។ គាត់ចូល អេភីឌី ក្នុងខែមិថុនា ឆ្នាំ២០២០ ហើយគាត់មានបទពិសោធន៍ទូលំទូលាយក្នុងវិស័យធនាគារ និងសេវាទូទាត់។

*គាត់ទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាលភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសញ្ញាបត្របរិញ្ញាបត្រផ្នែកអក្សរសាស្ត្រអង់គ្លេស ពីសាកវិទ្យាល័យពុទ្ធិសាស្ត្រ។*

**ស៊ូ សុជា**
**ប្រធាននាយកដ្ឋានសេវាធនាគារឌីជីថល**





លោក ប៉ែន ច័ន្ទរដ្ឋា ជាប្រធាននាយកដ្ឋានព័ត៌មានវិទ្យា ដែលទទួលខុសត្រូវត្រួតពិនិត្យដំណើរការព័ត៌មានវិទ្យា ស្វែងរក និងកាត់បន្ថយហានិភ័យសុវត្ថិភាពព័ត៌មានវិទ្យា និងវិភាគលក្ខខណ្ឌតម្រូវអាជីវកម្មសម្រាប់តម្រូវការ និងប្រព័ន្ធព័ត៌មានវិទ្យា។ គាត់មានបទពិសោធន៍ទូលំទូលាយខាងព័ត៌មានវិទ្យាក្នុងវិស័យធនាគារ។

*គាត់ទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងមានសញ្ញាបត្រពីរទៀតពីកម្មវិធីអភិបាលកិច្ចព័ត៌មានវិទ្យា ដែលហៅថា “ហានិភ័យព័ត៌មានវិទ្យា និងការគ្រប់គ្រងការត្រួតពិនិត្យ” និង “សវនកម្មព័ត៌មានវិទ្យា និងអភិបាលកិច្ច” ។*

**ប៉ែន ច័ន្ទរដ្ឋា**
**ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា**





លោក សេក សុខ ត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានគ្រប់គ្រងឥណទាននៅដើមឆ្នាំ២០២១។ គាត់ទទួលខុសត្រូវលើរាល់ការវាយតម្លៃ ការពិនិត្យ ការគ្រប់គ្រង និងការតាមដានឥណទាន។
មុននឹងចូលកាន់តំណែងបច្ចុប្បន្ន គាត់មានបទពិសោធន៍ផ្នែកឥណទានរយៈពេល ១២ ឆ្នាំ ជាមួយនឹងធនាគារម៉ាឡេស៊ីចំនួនបី។

*លោកមានសញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងធុរកិច្ចពីសាកលវិទ្យាល័យកម្ពុជា និងវិញ្ញាបនបត្រកម្រិតខ្ពស់ផ្នែកព័ត៌មានវិទ្យា ពីមជ្ឈមណ្ឌលព័ត៌មានវិទ្យាភ្នំពេញ។*

**សេក សុខ**
**ប្រធាននាយកដ្ឋានគ្រប់គ្រងឥណទាន**

លោកស្រី សាំង ម៉ានីតា ជាប្រធាននាយកដ្ឋានប្រតិបត្តិតាម ដែលទទួលខុសត្រូវគ្រប់គ្រងទូទៅលើមុខងារប្រតិបត្តិតាមរបស់ធនាគារ ហើយគាត់ជាបុគ្គលទំនាក់ទំនងដ៏សំខាន់រវាងធនាគារជាមួយនឹង NBC និងនិយតករផ្សេងៗទៀត។ គាត់ចូលធ្វើការនៅ អេភីឌី ក្នុងឆ្នាំ២០១៧ ហើយក្រោយមកក៏ទទួលបានការទទួលស្គាល់ជាផ្លូវការពីធនាគារជាតិនៃកម្ពុជា ជាប្រធាននាយកដ្ឋានប្រតិបត្តិតាម។ ជាងនេះទៅទៀត គាត់ទទួលបានសញ្ញាបត្រផ្នែកប្រតិបត្តិតាមនិយតកម្ម (Certificate of Regulator Compliance) ពីវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ (Institute of Banking and Finance ឬ IBF) នៅកម្ពុជា។

*គាត់បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងហានិភ័យក្នុងវិស័យធានារ៉ាប់រង ធនាគារ និងហិរញ្ញវត្ថុ ពី university of Nantesប្រទេសបារាំង និងពីសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ គាត់មានសញ្ញាបត្របរិញ្ញាបត្រផ្នែកគណនេយ្យ ពីសកលវិទ្យាល័យជាតិគ្រប់គ្រង និងបរិញ្ញាបត្រផ្នែកអប់រំភាសាអង់គ្លេស ពីវិទ្យាស្ថានភាសាបរទេស។*

**សាំង ម៉ានីតា**
**ប្រធាននាយកដ្ឋានប្រតិបត្តិតាម និងច្បាប់**





លោកស្រី ផេង គីមចន្ទ ជាប្រធាននាយកដ្ឋានសេវាធនាគារសម្រាប់សាជីវកម្ម។ គាត់មានបទពិសោធន៍ផ្នែកសេវាធនាគារលើសពី ១៥ ឆ្នាំ ជាមួយនឹងធនាគារក្នុងស្រុក និងធនាគារអន្តរជាតិ។ បទពិសោធន៍របស់គាត់រួមមាន ផ្នែកគ្រប់គ្រងសាខា ផ្នែកឥណទាន និងផ្នែកសេវាធនាគារសម្រាប់សាជីវកម្ម។ លោកស្រី ចន្ទ ជំនាញផ្នែកដឹកនាំ អភិវឌ្ឍអាជីវកម្ម និងបង្កើនប្រាក់ចំណូល។ ជាងនេះទៅទៀត បទពិសោធន៍ពីការងាររបស់គាត់បានផ្តល់ឱ្យគាត់នូវបណ្តុំជំនាញ ដែលរួមមានជំនាញដោះស្រាយបញ្ហាយ៉ាងរហ័ស និងសមត្ថភាពវិភាគ។ គាត់ចូលធនាគារ អេភីឌី ក្នុងខែសីហា ឆ្នាំ២០២០ ក្នុងមុខតំណែងជាអ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកអភិវឌ្ឍអាជីវកម្ម ហើយត្រូវបានដំឡើងតំណែងមកមុខតំណែងសព្វថ្ងៃនេះកាលពីខែមីនា ឆ្នាំ២០២២។

**ផេង គីមចន្ទ**
**ប្រធាននាយកដ្ឋានសេវាធនាគារសម្រាប់សាជីវកម្ម**



លោក ខៀវ សម្បត្តិធនធាន ទទួលមុខតំណែងជាប្រធាននាយកដ្ឋានប្រាក់បញ្ញើក្នុងឆ្នាំ២០២១។ គាត់ទទួលខុសត្រូវគ្រប់គ្រងនាយកដ្ឋានប្រាក់បញ្ញើ ដើម្បីធានាថាបណ្តុំប្រាក់បញ្ញើកើនឡើងជាបន្តបន្ទាប់។
បន្ទាប់ពីទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកទំនាក់ទំនងអាជីវកម្ម គាត់ទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្មពីសាកលវិទ្យាល័យក្នុងស្រុកដ៏ល្បីល្បាញមួយ (ន័រតុន)។ ក្រោយមក គាត់មានឱកាសបានចូលរួមកម្មវិធីរយៈពេលខ្លីមួយនៅរដ្ឋ Queensland ប្រទេសអូស្ត្រាលី។
*ដោយមានបទពិសោធន៍ការងារជាង ១៣ ឆ្នាំ ក្នុងវិស័យខុសៗគ្នាជាច្រើន និងបទពិសោធន៍ជាង ៩ ឆ្នាំ នៅគ្រឹះស្ថានហិរញ្ញវត្ថុ លោក ខៀវ សម្បត្តិធនធាន បានដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យអភិវឌ្ឍអាជីវកម្ម វិស័យគ្រប់គ្រងគម្រោង និងវិស័យគ្រប់គ្រងផ្នែកលក់។*

**ខៀវ សម្បត្តិធនធាន**
**ប្រធាននាយកដ្ឋានសេវាបញ្ញើ**



លោកស្រី ឡុង ស្រីផុស ជាប្រធាននាយកដ្ឋានសេវាធនាគារព្រីមៀរ ដែលទទួលខុសត្រូវលើទំនាក់ទំនងជាមួយអតិថិជន VIP ដើម្បីធានាផ្តល់ជូនអតិថិជននូវប្រតិបត្តិការរលូន និងសេវាល្អ ប្រកបដោយភាពងាយស្រួល និងការយកចិត្តទុកដាក់។ គាត់ចូលធនាគារ អេភីឌី នៅដើមឆ្នាំ ២០២២។
គាត់មានបទពិសោធន៍ ១៣ ឆ្នាំក្នុងវិស័យធនាគារ។ គាត់ចាប់ផ្តើមការងារដំបូងនៅធនាគារម៉ាឡេស៊ីមួយក្នុងឆ្នាំ២០០៩ ហើយបានអភិវឌ្ឍគន្លងអាជីពរបស់គាត់ទៅធនាគារចិនលំដាប់អន្តរជាតិកាលពីឆ្នាំ២០១១។ ដោយភាពឧស្សាហ៍ព្យាយាម និងភាពតស៊ូរបស់គាត់ លោកស្រី ស្រីផុស បានឡើងដល់មុខតំណែងគ្រប់គ្រងជាន់ខ្ពស់ក្នុងខណៈពេលដ៏សំខាន់ក្នុងអាជីពរបស់គាត់។

*លោកស្រី ទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកគណនេយ្យពីវិទ្យាស្ថានវ៉ាន់ដា។ ដោយមានការប្តេជ្ញារៀនសូត្រភាសាបរទេស គាត់បានរៀនភាសាចិនអស់រយៈពេលជាច្រើនឆ្នាំនៅប្រទេសចិនតាំងពីគាត់នៅក្មេង។ គាត់និយាយភាសាចិនបានយ៉ាងរលូន។*

**ឡុង ស្រីផុស**
**ប្រធាននាយកដ្ឋានសេវាធនាគារព្រីមៀរ**







លោកស្រី ជឹម ស្រីណុន ជាប្រធាននាយកដ្ឋានសេវាធនាគារសម្រាប់បុគ្គល ១ ដែលទទួលខុសត្រូវលើកំណើនអាជីវកម្មទាំងអតិថិជនបញ្ញើ និងអតិថិជនកម្ចីនៃអាជីវកម្មធនាគារ។ គាត់ចូលធនាគារ អេភីឌី កាលពីខែតុលា ឆ្នាំ២០២០។ មុននឹងចូលកាន់តំណែងបច្ចុប្បន្នរបស់គាត់ គាត់មានបទពិសោធន៍ជាង ១៥ ឆ្នាំក្នុងមុខតំណែង និងតួនាទីខុសៗគ្នាតាំងពីថ្នាក់ទាបដល់ថ្នាក់គ្រប់គ្រង រួមមានសេវាអតិថិជន បុគ្គលិកដាក់-ដកប្រាក់ មន្ត្រីប្រតិបត្តិការ អនុប្រធានសាខា ប្រធានសាខា និងអ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកអភិវឌ្ឍអាជីវកម្មក្នុងវិស័យធនាគារ។
*គាត់ទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្មពីសាកលវិទ្យាល័យន័រតុន និងបានចូលរួមកម្មវិធីផ្លាស់ប្តូរសិស្សនៅប្រទេសម៉ាឡេស៊ី និងសិង្ហបុរី ដែលឧបត្ថម្ភដោយសាកលវិទ្យាល័យ Newton។ គាត់ក៏មានសញ្ញាបត្របរិញ្ញាបត្រផ្នែកគណនេយ្យ និងហិរញ្ញវត្ថុពីសាកលវិទ្យាល័យបៀលប្រាយផងដែរ។*

**ជឹម ស្រីណុន**
**ប្រធាននាយកដ្ឋានសេវាធនាគារសម្រាប់បុគ្គល ១**



លោក ស៊ិន សុធា ជាប្រធាននាយកដ្ឋានសេវាធនាគារសម្រាប់បុគ្គល ២ ដែលមានឯកទេសខាងសេវាធនាគារបុគ្គល និងការគ្រប់គ្រងទ្រព្យសម្បត្តិ។ គាត់ទទួលខុសត្រូវលើអតិថិជនចិនដែលមានមូលនិធិផ្ទាល់សុទ្ធខ្ពស់ៗ ក៏ដូចជាអតិថិជនសក្តានុពលផ្សេងទៀត។ លោក សុធា មានបទពិសោធន៍ជាច្រើនក្នុងវិស័យធនាគារ និងមានជំនាញចរចា ដោះស្រាយបញ្ហា និងរក្សាទំនាក់ទំនងជាមួយអតិថិជនយ៉ាងល្អប្រសើរ។

*គាត់ចូលធនាគារ អេភីឌី កាលពីខែតុលា ឆ្នាំ២០២០ ហើយក្រោយមកត្រូវបានដំឡើងតំណែងទៅជាប្រធាននាយកដ្ឋានសេវាធនាគារសម្រាប់បុគ្គល ២។ លោក សុធា មានសញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម ជំនាញគ្រប់គ្រងទូទៅ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។*

**ស៊ិន សុធា**
**ប្រធាននាយកដ្ឋានសេវាធនាគារសម្រាប់បុគ្គល ២**



លោក តុល ធារន្ធ ជាប្រធាននាយកដ្ឋានសេវាធនាគារសម្រាប់បុគ្គល ៣ ដែលទទួលខុសត្រូវដឹកនាំក្រុមការងារទាញយកអតិថិជន ដើម្បីបង្កើនចំនួនអតិថិជន និងការប្រើប្រាស់កម្មវិធីធនាគារចល័ត និងផ្សព្វផ្សាយទៅដល់អតិថិជនគោលដៅដែលមានតម្រូវការសេវាធនាគារលំដាប់ខ្ពស់។
មុននឹងចូលកាន់តំណែងបច្ចុប្បន្នរបស់គាត់នៅធនាគារ អេភីឌី គាត់មានបទពិសោធន៍ជាង ១៥ ឆ្នាំក្នុងវិស័យហិរញ្ញវត្ថុ ដែលរួមមានវិស័យធានារ៉ាប់រងជីវិត និងវិស័យធនាគារ។ គាត់មានជំនាញផ្នែកសេវាអតិថិជន ការកសាងទំនាក់ទំនង និងបណ្តាញឃោសនាមហាជន។

*លោក ធារន្ធ មានសញ្ញាបត្របរិញ្ញាបត្រផ្នែកគ្រប់គ្រងអាជីវកម្មពីសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ព្រមទាំងសញ្ញាបត្រភាសាថៃទូទៅពីវិទ្យាស្ថានភាសាបរទេស។*

**តុល ធារន្ធ**
**ប្រធាននាយកដ្ឋានសេវាធនាគារសម្រាប់បុគ្គល៣**

APD BANK
ASIA-PACIFIC DEVELOPMENT BANK



## ក្រុមប្រឹក្សាភិបាល

| | |
|---|---|
| លោក វង្ស ពេជ្រ | ប្រធាន |
| លោក ឡាវ អៀវចុង | អនុប្រធាន |
| លោក ឡូញ ហៃ | អភិបាល |
| លោក YU YONGSHUN | អភិបាល |

## គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

### គណៈកម្មាធិការសវនកម្ម និងប្រតិបត្តិតាម (AUDIT AND COMPLIANCE BOARD COMMITTEE ឬ ACBC)

| | |
|---|---|
| លោក YU YONGSHUN | ប្រធាន |
| លោក វង្ស ពេជ្រ | សមាជិក |
| លោក ឡាវ អៀវចុង | សមាជិក |

### គណៈកម្មាធិការទ្រព្យសកម្ម បំណុល និងហានិភ័យ (ALCO AND RISK BOARD COMMITTEE ឬ ARBC)

| | |
|---|---|
| លោក ឡូញ ហៃ | ប្រធាន |
| លោក វង្ស ពេជ្រ | សមាជិក |
| លោក ឡាវ អៀវចុង | សមាជិក |

### គណៈកម្មាធិការតម្លៃការ និងតែងតាំង (REMUNERATION AND NOMINATION BOARD COMMITTEE ឬ RNBC)

| | |
|---|---|
| លោក ឡូញ ហៃ | ប្រធាន |
| លោក វង្ស ពេជ្រ | សមាជិក |
| លោក ឡាវ អៀវចុង | សមាជិក |

## គណៈកម្មាធិការគ្រប់គ្រង

### គណៈកម្មាធិការប្រតិបត្តិ (EXECUTIVE COMMITTEE ឬ EXCO)

| | |
|---|---|
| លោក THOO KIM SENG | ប្រធាន |
| លោក CHUA THIAM YEW | ប្រធានស្តីទី |
| លោក ស្វាយ ពិសាល | សមាជិក |
| លោក អ៊ឹង គង់ហេង | សមាជិក |
| លោក ឈឹ តេច | សមាជិក |
| លោក ប៉ែន ច័ន្ទរដ្ឋា | សមាជិក |
| កញ្ញា ស៊ូ សុជា | សមាជិក |
| លោកស្រី សូ ធីតា | សមាជិក |
| លោកស្រី ថៃ ស្រីមុំ | សមាជិក |
| លោក សេក សុខ | សមាជិក |

### គណៈកម្មាធិការគ្រប់គ្រងឥណទាន (MANAGEMENT CREDIT COMMITTEE ឬ MCC)

| | |
|---|---|
| លោក THOO KIM SENG | ប្រធាន |
| លោក CHUA THIAM YEW | ប្រធានស្តីទី |
| លោក ស្វាយ ពិសាល | សមាជិក |
| លោក ឈឹ តេច | សមាជិក |
| លោក សេក សុខ | សមាជិក |

### គណៈកម្មាធិការព័ត៌មានវិទ្យា (IT STEERING COMMITTEE ឬ ITSC)

| | |
|---|---|
| លោក THOO KIM SENG | ប្រធាន |
| លោក CHUA THIAM YEW | ប្រធានស្តីទី |
| លោក ស្វាយ ពិសាល | សមាជិក |
| លោក អ៊ឹង គង់ហេង | សមាជិក |
| លោក ឈឹ តេច | សមាជិក |
| លោក ប៉ែន ច័ន្ទរដ្ឋា | សមាជិក |
| កញ្ញា ស៊ូ សុជា | សមាជិក |
| លោក សេក សុខ | សមាជិក |
| លោកស្រី សូ ធីតា | សមាជិក |
| លោកស្រី ថៃ ស្រីមុំ | សមាជិក |

# រចនាសម្ព័ន្ធរៀបចំ



APD BANK
ASIA-PACIFIC DEVELOPMENT BANK

# ការបង្ហាញសមិទ្ធផលការងារ

## ទ្រព្យសកម្មសរុប




## ប្រាក់ចំណេញមុនកាត់ពន្ធ




## ឥណទាន និងបុរេប្រទានដុល




## ប្រាក់បញ្ញើសរុប




## សង្ខេបស្ថានភាពហិរញ្ញវត្ថុ

| | 2021 | 2020 | 2019 | 2018 |
|---|---|---|---|---|
| **ចំណេញ (ជាដុល្លារអាមេរិក)** | | | | |
| ចំណេញមុនចំណាយពន្ធ | 5,045,165 | 3,583,868 | 2,750,607 | 102,686 |
| ចំណេញក្រោយចំណាយពន្ធ | 3,962,202 | 2,856,710 | 2,243,081 | 37,926 |
| **ស្ថានភាពហិរញ្ញវត្ថុ (ជាដុល្លារអាមេរិក)** | | | | |
| ទ្រព្យសកម្មសរុប | 305,896,569 | 176,349,390 | 80,475,159 | 24,009,141 |
| ឥណទាន និងបុរេប្រទាន | 249,357,794 | 130,391,410 | 70,800,911 | 21,496,777 |
| ប្រាក់បញ្ញើពីអតិថិជន | 138,887,712 | 80,775,991 | - | - |
| ប្រាក់បញ្ញើសរុប | 206,002,469 | 91,710,374 | - | - |
| ដើមទុន | 77,490,000 | 77,490,000 | 77,490,000 | 15,000,000 |
| មូលធនរបស់ភាគទុនិក | 86,270,728 | 82,308,526 | 79,451,816 | 14,718,735 |
| **អនុបាតហិរញ្ញវត្ថុ (ជា %)** | | | | |
| ឥណទានមិនដំណើរការ ធៀបនឹងឥណទាន និងបុរេប្រទានសរុប | Nil | Nil | Nil | Nil |
| ចំណូលសុទ្ធលើទ្រព្យសកម្ម | 1.60% | 2.20% | 4.30% | 0.20% |
| ចំណូលសុទ្ធលើមូលធន | 5.10% | 3.70% | 4.90% | 0.30% |
| អនុបាតកម្ចី និងប្រាក់បញ្ញើរបស់អតិថិជន | 180% | 161% | 0% | 0% |
| អនុបាតកម្ចី និងប្រាក់បញ្ញើ | 121% | 142% | 0% | 0% |

APD BANK
ASIA-PACIFIC DEVELOPMENT BANK

# ផលិតផល និងសេវាកម្ម

## គណនីសន្សំ

បង្កើនប្រាក់សន្សំរបស់លោកអ្នកជាមួយនឹងគណនីសន្សំ ដែលមានអត្រាការប្រាក់គួរឱ្យទាក់ទាញ និងមានភាពបត់បែនទៅតាមស្ថានភាព។ លោកអ្នកអាចរកបានកាន់តែច្រើនពីប្រាក់សន្សំរបស់លោកអ្នក ហើយថែមទាំងទទួលបានអត្ថប្រយោជន៍ពិសេសៗជាច្រើនផងដែរ។ គណនីសន្សំរបស់ធនាគារ អេភីឌី ជាគណនីដែលរៀបចំឡើងសម្រាប់ឱ្យលោកអ្នកអាចដាក់ប្រាក់ និងដកប្រាក់បានគ្រប់ពេលវេលា ដោយមិនមានការកំណត់ចំនួនប្រតិបត្តិការ។

លក្ខណៈពិសេស និងអត្ថប្រយោជន៍

- មានផ្តល់ជូនគណនីជាដុល្លារអាមេរិក និងប្រាក់រៀល
- ការប្រាក់គណនាជាប្រចាំថ្ងៃនិង ទូទាត់ជូនលោកអ្នកជារៀងរាល់ខែ
- ផ្តល់ជូនសៀវភៅគណនីដោយឥតគិតថ្លៃសម្រាប់គ្រប់គណនីសន្សំទាំងអស់
- អាចដកប្រាក់បានគ្រប់ពេលវេលា
- អាចដកប្រាក់នៅតាមបញ្ជររបស់ធនាគារដោយឥតកំណត់ និងមិនគិតថ្លៃសេវា
- ទឹកប្រាក់តម្កល់ដំបូង និងសមតុល្យអប្បបរមា គឺ ៤០.០០០ រៀល ឬ ១០ ដុល្លារអាមេរិក។

## បញ្ញើមានកាលកំណត់

ទទួលបានផលចំណេញជាអតិបរមាលើប្រាក់សន្សំដែលមានការគ្រោងទុកត្រឹមត្រូវរបស់លោកអ្នក ដោយបើកគណនីបញ្ញើមានកាលកំណត់នៅធនាគារ អេភីឌី លោកអ្នកនឹងទទួលបានអត្រាការប្រាក់កាន់តែខ្ពស់។ អត្រាការប្រាក់នេះប្រែប្រួលអាស្រ័យលើរយៈពេលបញ្ញើ ចាប់ពី ១ ខែ រហូតដល់លើស ២៤ ខែ។

លក្ខណៈពិសេស និងអត្ថប្រយោជន៍

- មានផ្តល់ជូនគណនីជាដុល្លារអាមេរិក និងប្រាក់រៀល
- អត្រាការប្រាក់ខ្ពស់ជាងគណនីសន្សំ
- ទទួលបានប្រាក់ចំណេញលើប្រាក់របស់លោកអ្នក ដោយឥតកំណត់សមតុល្យអតិបរមា
- ទឹកប្រាក់តម្កល់ដំបូងអប្បបរមា គឺចាប់ពី ២.០០០.០០០ រៀល ឬ ៥០០ ដុល្លារអាមេរិកឡើង។

## គណនីចរន្ត

ចង់បានជម្រើសច្រើនមែនទេ? ធនាគារ អេភីឌី ផ្តល់ជូនលោកអ្នកបាន។ អតិថិជនរបស់ធនាគារ អេភីឌី អាចមានជម្រើសច្រើនក្នុងការប្រើមូលប្បទានបត្រ ដែលក្នុងនោះរួមមានអត្ថប្រយោជន៍មូលដ្ឋាន និងអត្ថប្រយោជន៍ជាច្រើនទៀត។

គណនីចរន្តត្រូវបានរៀបចំឡើងសម្រាប់អតិថិជន ដែលត្រូវការធ្វើប្រតិបត្តិការច្រើនជាប្រចាំជាមួយនឹងធនាគារ រួមមានដូចជាការដាក់ប្រាក់ ការដកប្រាក់ និងការទូទាត់ប្រាក់ជូនដៃគូពាណិជ្ជកម្ម។

លក្ខណៈពិសេស និងអត្ថប្រយោជន៍

- មានផ្តល់ជូនគណនីជាដុល្លារអាមេរិក និងប្រាក់រៀល
- ផ្តល់ជូនរបាយការណ៍គណនីប្រចាំខែដោយឥតគិតថ្លៃ
- មិនមានគិតថ្លៃសេវាថែទាំគណនីប្រចាំខែ
- ធ្វើប្រតិបត្តិការបានដោយឥតកំណត់ និងមិនមានគិតថ្លៃសេវា
- អាចបើកគណនីរួមបាន
- ទឹកប្រាក់តម្កល់ដំបូងអប្បបរមា គឺ ៤០០.០០០ រៀល ឬ ១០០ ដុល្លារអាមេរិកសម្រាប់អតិថិជនជារូបវន្តបុគ្គល ឬ ២.០០០.០០០ រៀល ឬ ៥០០ ដុល្លារអាមេរិក សម្រាប់អតិថិជនជានីតិបុគ្គល។




Download it from
APP STORE

Download it from
GOOGLE PLAY



# ផលិតផល និងសេវាកម្ម

## ឥណទានគេហដ្ឋាន

ធនាគារ អេភីឌី មានផ្តល់ជូននូវឥណទានគេហដ្ឋានក្នុងអត្រាការប្រាក់ដែលមានលក្ខណៈប្រកួតប្រជែង ព្រមទាំងមានក្រុមអ្នកជំនាញផ្នែកឥណទានគេហដ្ឋានដែលត្រៀមរួចជាស្រេចដើម្បីជួយលោកអ្នក។ មិនថាលោកអ្នកបានរកឃើញផ្ទះថ្មីក្នុងក្តីស្រមៃរបស់លោកអ្នកហើយ ឬចង់បានហិរញ្ញប្បទានសម្រាប់សងកម្ចីគេហដ្ឋានសព្វថ្ងៃរបស់លោកអ្នកនោះទេ ធនាគារ អេភីឌី យើងខ្ញុំរង់ចាំជួយដល់លោកអ្នកជានិច្ច។

លក្ខណៈពិសេស និងអត្ថប្រយោជន៍

- រយៈពេលខ្ចីអាចបានរហូតដល់ ២៥ ឆ្នាំ
- ទឹកប្រាក់កម្ចីអាចបានរហូតដល់ ៨០% នៃតម្លៃអចលនទ្រព្យ
- អាចយកអចលនទ្រព្យដែលទិញដោយឥណទាននេះមកធ្វើជាទ្រព្យបញ្ចាំ
- អត្រាការប្រាក់គួរឱ្យទាក់ទាញ ហើយការបង់រំលស់អាចប្រែប្រួលទៅតាមស្ថានភាព

## ឥណទានវិបារូបន៍

ស្នើសុំឥណទានវិបារូបន៍ដើម្បីធានាថា លោកអ្នកអាចមានសាច់ប្រាក់គ្រប់គ្រាន់បើទោះបីគណនីរបស់អ្នកនៅសល់សមតុល្យសូន្យក៏ដោយ។ ស្វែងយល់ឱ្យកាន់តែច្បាស់អំពីឥណទានវិបារូបន៍ និងរបៀបនៃការគ្រប់គ្រងលើហិរញ្ញវត្ថុរបស់លោកអ្នក។

លក្ខណៈពិសេស និងអត្ថប្រយោជន៍

- ឥណទានវិបារូបន៍ជាចំណែកមួយនៃគណនីរបស់លោកអ្នក
- ឥណទានវិបារូបន៍មិនមានកំណត់ទឹកប្រាក់អតិបរមាឡើយ
- អាចយកអចលនទ្រព្យ ឬដីធ្លី ឬបញ្ញើមានកាលកំណត់ធ្វើជាទ្រព្យបញ្ចាំ
- អត្រាការប្រាក់គួរឱ្យទាក់ទាញ ហើយការបង់រំលស់អាចប្រែប្រួលទៅតាមស្ថានភាព
- ការប្រាក់គណនាជាប្រចាំថ្ងៃលើសមតុល្យដែលនៅសល់ ហើយទូទាត់នៅរៀងរាល់ចុងខែ

## ឥណទានមានកាលកំណត់

សម្រេចគោលដៅហិរញ្ញវត្ថុរបស់លោកអ្នកជាមួយនឹងអត្រាការប្រាក់ដែលអាចប្រែប្រួលទៅតាមស្ថានភាព។ ឥណទានមានកាលកំណត់ពីធនាគារយើងខ្ញុំអាចជួយលោកអ្នកឈានទៅរកគោលដៅបាន ហើយឥណទាននេះបត់បែនទៅតាមស្ថានភាព ជាមួយនឹងអត្រាការប្រាក់ថេរ ឬអត្រាការប្រាក់ប្រែប្រួល ព្រមទាំងផ្តល់នូវជម្រើសក្នុងការសងត្រឡប់ប្រាក់ដើម ដោយមិនមានគិតថ្លៃសេវាបន្ថែមឡើយ។ ឥណទានមានកាលកំណត់អាចបំពេញតម្រូវការលោកអ្នកក្នុងការទូទាត់ការចំណាយបន្ទាន់ ផ្តល់ជាថវិកាសម្រាប់គម្រោងជួសជុលផ្ទះ ឬបន្ថែមទុនលើអាជីវកម្មរបស់លោកអ្នក។

លក្ខណៈពិសេស និងអត្ថប្រយោជន៍

- រយៈពេលខ្ចីអាចបានរហូតដល់ ១៥ ឆ្នាំ
- ទឹកប្រាក់កម្ចីអាចបានរហូតដល់ ៧០% នៃតម្លៃអចលនទ្រព្យ
- អាចយកអចលនទ្រព្យ ឬដីធ្លីធ្វើជាទ្រព្យបញ្ចាំ
- អត្រាការប្រាក់គួរឱ្យទាក់ទាញ ហើយការបង់រំលស់អាចប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែង

## សេវាផ្ទេរប្រាក់

ផ្ញើរប្រាក់តាមវិធីដែលមានសុវត្ថិភាពខ្ពស់ និងរហ័សទាន់ចិត្ត ទៅកាន់ដៃគូររបស់លោកអ្នកនៅគ្រប់ទីកន្លែងជុំវិញពិភពលោក ជាមួយនឹងជម្រើសនៃការផ្ទេរប្រាក់ដូចខាងក្រោម៖

សេវាផ្ញើ-ទទួលប្រាក់ពីក្រៅប្រទេស ដែលជាវិធីទូទាត់ប្រាក់តាមប្រព័ន្ធ SWIFT ។

សេវាផ្ញើ-ទទួលប្រាក់ក្នុងស្រុក និងអន្តរជាតិពីគណនីធនាគារ អេភីឌី និងគណនីធនាគារជាដៃគូសហការ។

លក្ខណៈពិសេស និងអត្ថប្រយោជន៍

- ជាវិធីផ្ទេរប្រាក់ក្នុង និងក្រៅប្រទេសដោយមានសុវត្ថិភាពខ្ពស់ និងរហ័សទាន់ចិត្ត
- មានបណ្តាញធនាគារទំនាក់ទំនង និងធនាគារជាដៃគូរសហការធំទូលាយ
- ថ្លៃសេវាគួរឱ្យទាក់ទាញ
- លេខកូដ SWIFT: ADEOKHPP ។

APD BANK
ASIA-PACIFIC DEVELOPMENT BANK

# ការិយាល័យកណ្តាល







ការិយាល័យចុះបញ្ជី៖
ផ្ទះលេខ C២០, C២១, C២២, C២៣, D៣២, D៣៣, & D៣៣A, វិនផាក ដីឡូត៍លេខ៥៨ ផ្លូវលេខR៨ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

# សាខាម៉ៅសេទុង







ការិយាល័យចុះបញ្ជី៖
អាគារ Royal K Plaza មហាវិថីម៉ៅសេទុង ភូមិភូមិ ២ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ

APD BANK
ASIA-PACIFIC DEVELOPMENT BANK

# សាខាអូឡាំព្យា










ការិយាល័យចុះបញ្ជី៖
អាគារ លេខ អេស៣-១៧ ផ្លូវលេខ១៨២ សង្កាត់វាលវង់
ខណ្ឌ៧មករា រាជធានីភ្នំពេញ

# មហាវិថីព្រះនរោត្តម









ការិយាល័យចុះបញ្ជី៖
ដីឡូត៍លេខ១៣២ ផ្លូវ២៩៤ កែងមហាវិថីព្រះនរោត្តម
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

# របាយការណ៍
# ត្រួតពិនិត្យផ្ទៃក្នុង

## សេចក្តីណែនាំ

ធនាគារ អេភីឌី ត្រូវបានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជា និងបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ក្នុងទ្រង់ទ្រាយជា ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងមានអត្តលេខចុះបញ្ជីលេខ ០០០០៧៥១៤ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦។

ធនាគារទទួលបានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារឯកទេសដែលមានសុពលភាពអចិន្ត្រៃយ៍ ពីធនាគារជាតិ នៃកម្ពុជា កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ហើយបានចាប់ផ្តើមដំណើរការជាផ្លូវការនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦។ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ ធនាគារបានទទួលអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារពាណិជ្ជ ពីធនាគារជាតិនៃកម្ពុជា និងបានប្តូរនាមករណ៍ពី ធនាគារឯកទេស អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ភីអិលស៊ី ទៅជា ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក។ ឯកសារផ្លូវច្បាប់របស់ធនាគារដែលបានធ្វើវិសោធនកម្មរួចត្រូវបានដាក់ជូនទៅអាជ្ញាធរពាក់ព័ន្ធ និងបានទទួលការឯកភាពជាស្ថាពរនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០។

របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងនេះ មានចែងលម្អិតអំពីសកម្មភាពត្រួតពិនិត្យផ្ទៃក្នុងរបស់ ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ភីអិលស៊ី (តទៅនេះ ហៅកាត់ថា “ធនាគារ”) ក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុកន្លងទៅ និងមានរៀបរាប់អំពីប្រព័ន្ធសម្រាប់វាស់វែង តាមដាន និងបង្ហាញពីហានិភ័យដែលធនាគារបានប្រឈម។

របាយការណ៍នេះ ត្រូវបានរៀបចំឡើងស្របតាម ប្រកាសលេខ ធ៧.០១០.១៧២ ប្រ.ក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ របស់ធនាគារជាតិ នៃកម្ពុជា ដើម្បីជួយដល់ធនាគារក្នុងការរៀបចំប្រតិបត្តិការធនាគារដែលប្រកបដោយសុវត្ថិភាព និងភាពត្រឹមត្រូវ ព្រមទាំងបង្កើតនូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមួយ សម្រាប់ជួយគាំទ្រដល់ថ្នាក់គ្រប់គ្រង ក្នុងការអនុវត្តទំនួលខុសត្រូវរបស់ពួកគេ និងជួយដល់ការកំណត់ វាយតម្លៃ និងគ្រប់គ្រងហានិភ័យបានទាន់ពេលវេលា ព្រមទាំងជួយធនាគារក្នុងការអនុវត្តសកម្មភាពកែតម្រូវ។

## ១ រចនាសម្ព័ន្ធ នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

### ១.១. ក្របខណ្ឌទូទៅនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព គឺជាសមាសធាតុដ៏សំខាន់នៃការគ្រប់គ្រងធនាគារ និង ជាមូលដ្ឋានគ្រឹះសម្រាប់ប្រតិបត្តិការប្រកបដោយសុវត្ថិភាព និង ត្រឹមត្រូវរបស់ធនាគារ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដ៏រឹងមាំអាចជួយធានាថា គោលដៅ និង គោលបំណងរបស់ធនាគារនឹងត្រូវបានបំពេញ ហើយធនាគារនឹងសម្រេចបាននូវគោលដៅប្រាក់ចំណេញរយៈពេលវែង និងរក្សាបាននូវរបាយការណ៍ហិរញ្ញវត្ថុ និងការគ្រប់គ្រងដែលអាចទុកចិត្តបាន។ ប្រព័ន្ធនេះក៏អាចជួយធានាថា ធនាគារនឹងគោរពតាមច្បាប់និងបទប្បញ្ញត្តិនានា ក៏ដូចជាគោលនយោបាយ ផែនការ បទបញ្ជាផ្ទៃក្នុង និងនីតិវិធីទាំងឡាយ ព្រមទាំងកាត់បន្ថយហានិភ័យនៃការបាត់បង់ ឬ ការខូចខាតដែលមិនបានរំពឹងទុកដល់កេរ្តិ៍ឈ្មោះរបស់ធនាគារ ក៏ដូចជាម្ចាស់ភាគហ៊ុនរបស់ធនាគារ។ នៅក្នុងរបាយការណ៍នេះ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរួមមានគោលការណ៍គន្លឹះដូចខាងក្រោម៖

### ១.១.១. បរិយាកាសនៃការត្រួតពិនិត្យ

ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងនៃធនាគារ បានបង្កើតឡើងនូវគោលការណ៍ដឹកនាំពីថ្នាក់កំពូល លើស្តង់ដារដែលរំពឹងទុក និងសារៈសំខាន់នៃការត្រួតពិនិត្យផ្ទៃក្នុង។ តាមរយៈគោលការណ៍ទាំងនេះ គណៈកម្មាធិការគ្រប់គ្រង់ផ្សេងៗត្រូវបង្កើត ដើជួយដល់ក្រុមប្រឹក្សាភិបាលដើម្បីបំពេញភារកិច្ចរបស់ខ្លួន។ មូលដ្ឋានគ្រឹះនៃគោលការណ៍ត្រួតពិនិត្យផ្ទៃក្នុងទាំងអស់ គឺបរិយាកាសនៃការត្រួតពិនិត្យ ដែលផ្តល់នូវវិន័យដែលបានព្រមព្រៀង និងនីតិវិធីប្រតិបត្តិស្តង់ដារត្រឹមត្រូវ។ គោលការណ៍សំខាន់ៗទាក់ទងនឹងបរិយាកាសត្រួតពិនិត្យមានដូចខាងក្រោម៖:

- ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការទទួលខុសក្នុងការធ្វើសេចក្តីសម្រេច និងធ្វើការត្រួតពិនិត្យជាប្រចាំ លើយុទ្ធសាស្រ្តអាជីវកម្ម និងគោលនយោបាយសំខាន់ៗរបស់ធនាគារ។ ធ្វើការស្វែងយល់ពីហានិភ័យធំៗ ដែលអាចមានផលប៉ះពាល់ដល់ធនាគារ កំណត់កម្រិតដែលអាចទទួលយកបានចំពោះហានិភ័យទាំងនេះ និងធានាថាថ្នាក់ដឹកនាំចាត់វិធានការចាំបាច់ដើម្បីកំណត់ វាស់វែងតាមដាន និងគ្រប់គ្រងហានិភ័យទាំងនេះ។ អនុម័តលើរចនាសម្ព័ន្ធធនាគារ និងធានាថាគណៈគ្រប់គ្រងរបស់ធនាគារ បានបំពេញតួនាទីរបស់ខ្លួនក្នុងការតាមដានលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។ ក្រុមប្រឹក្សាភិបាលជាអ្នកទទួលខុសត្រូវចុងក្រោយ ក្នុងការធានាប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមានប្រសិទ្ធិភាពគ្រប់គ្រាន់។
- ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិកបង្ហាញនូវការប្តេជ្ញាចិត្ត ក្នុងការឆ្ពោះទៅរកភាពស្មោះត្រង់ប្រកបដោយសីលធម៌ និងគុណធម៌ខ្ពស់ ហើយព្រមទាំងបង្កើតបាននូវវប្បធម៌មួយ ដែលបង្ហាញពីសារៈសំខាន់ និងសង្កត់ធ្ងន់ទៅលើការត្រួតពិនិត្យផ្ទៃក្នុង ទៅដល់បុគ្គលិក គ្រប់ជាន់ថ្នាក់នៅក្នុងធនាគារ។ បុគ្គលិកទាំងអស់នៅធនាគារ ត្រូវតែយល់អំពីតួនាទីរបស់ខ្លួន ទៅលើដំណើរការនៃការត្រួតពិនិត្យផ្ទៃក្នុង ព្រមទាំងចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការនេះ។
- ដោយមានការត្រួតពិនិត្យពីក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងបង្កើតរចនាសម្ព័ន្ធ បណ្តាញរាយការណ៍ និងសិទ្ធិអំណាចស្វ័យតដែលសមស្រប ដើម្បីសម្រេចបាននូវគោលដៅជាយុទ្ធសាស្រ្ត យុទ្ធវិធី និងប្រតិបត្តិការ។
- គណៈគ្រប់គ្រង និងបុគ្គលិក ត្រូវអនុវត្តដើម្បីឆ្ពោះទៅ នឹងសម្រេចឱ្យបាន នូវប្រព័ន្ធត្រួតពិនិត្យ ផ្ទៃក្នុងដ៏ល្អត្រឹមត្រូវ នៅគ្រប់ផ្នែក គ្រប់ជាន់ថ្នាក់នៅក្នុងធនាគារ។
- គោលនយោបាយ និងនីតិវិធីទាំងឡាយ ត្រូវបានដាក់ចេញនៅក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីបង្ការហានិភ័យ។ ការបែងចែកភារៈកិច្ចត្រឹមត្រូវ និងការត្រួតពិនិត្យពីរជាន់ (Dual Control) មានន័យថា និយោជិកម្នាក់មិនអាចធ្វើប្រតិបត្តិការទាំងមូលបានទេ។ រាល់បុគ្គលិកទាំងអស់ត្រូវទទួលខុសត្រូវក្នុងការអនុវត្ត និងគោរពតាមគោលការណ៍ត្រួតពិនិត្យផ្ទៃក្នុង។ ទន្ទឹមនឹងនេះ ពួកគេត្រូវរាយការណ៍ទៅថ្នាក់លើ ប្រសិនបើមានការមិនគោរពតាមគោលការណ៍ ឬការបំពានណាមួយលើគោលនយោបាយទាំងនេះ។

### ១.១.២. ការវាយតម្លៃហានិភ័យ

ការវាយតម្លៃហានិភ័យ ត្រូវមានដំណើរការយ៉ាងស៊ីចង្វាក់ និងតឹងរ៉ឹង ក្នុងការកំណត់ វិភាគ និងគ្រប់គ្រងហានិភ័យក្នុងការបំពេញភារកិច្ចដើម្បីសម្រេចបាននូវគោលដៅជាយុទ្ធសាស្រ្ត និងប្រតិបត្តិការ។ គោលការណ៍សំខាន់ៗទាក់ទងនឹងការវាយតម្លៃហានិភ័យមានដូចខាងក្រោម៖

- គណៈគ្រប់គ្រងកំណត់ គោលដៅប្រតិបត្តិការច្បាស់លាស់ ដោយមានភាពច្បាស់លាស់គ្រប់គ្រាន់ដើម្បីជួយកំណត់ វិភាគ និង វាយតម្លៃហានិភ័យដែលអាចកើតមាន។
- គណៈគ្រប់គ្រងកំណត់ និងគ្រប់គ្រងហានិភ័យដែលអាចរារាំងដល់ការសម្រេចបាននូវគោលដៅជាយុទ្ធសាស្រ្ត និងប្រតិបត្តិការទាំងមូល។ និង
- គណៈគ្រប់គ្រង និងបុគ្គលិកត្រូវវាយតម្លៃ និងកែលម្អផ្នែកដែលអាចជះឥទ្ធិពលខ្លាំងទៅដល់ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

### ១.១.៣. សកម្មភាពត្រួតពិនិត្យ

សកម្មភាពត្រួតពិនិត្យអាចមានចារឹកលក្ខណៈជាការស៊ើបអង្កេត និងការបង្ការ ហើយរួមបញ្ចូលទាំងសកម្មភាពផ្សេងៗទាំងស្វ័យប្រវត្តិ និងមិនស្វ័យប្រវត្តិ ដូចជាការការអនុញ្ញាត តុល្យភាពនៃការពិនិត្យ ការអនុម័ត ការផ្ទៀងផ្ទាត់ ការផ្ទួរផ្ទងនឹងកែតម្រូវឡើងវិញ ការត្រួតពិនិត្យដោយផ្ទាល់ ការត្រួតពិនិត្យលក្ខណៈអធិការកិច្ច ការពិនិត្យលើការបំពេញមុខងារ។ ទន្ទឹមនឹងនេះ ការបែងចែកភារកិច្ចត្រូវបានធ្វើឡើងនៅក្នុងការជ្រើសរើស និងការអភិវឌ្ឍសកម្មភាពត្រួតពិនិត្យ។ គោលការណ៍សំខាន់ៗទាក់ទងនឹងសកម្មភាពត្រួតពិនិត្យមានដូចខាងក្រោម៖

- គណៈគ្រប់គ្រង និងបុគ្គលិកត្រូវបង្កើនសកម្មភាពត្រួតពិនិត្យ ដើម្បីកាត់បន្ថយហានិភ័យដល់កម្រិតអប្បបរមា។
- គណៈគ្រប់គ្រង និងបុគ្គលិកត្រូវអនុវត្តសកម្មភាពត្រួតពិនិត្យទូទៅលើប្រព័ន្ធ ដើម្បីគាំទ្រដល់ការសម្រេចគោលដៅ។ និង
- គណៈគ្រប់គ្រង និងបុគ្គលិកត្រូវពង្រឹងលើសកម្មភាពត្រួតពិនិត្យ ដើម្បីធានានូវភាពអាចជឿជាក់បាននៃរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍មិនមែនជាហិរញ្ញវត្ថុ ព្រមទាំងការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ។

### ១.១.៤. ព័ត៌មាន និងការទំនាក់ទំនង

ព័ត៌មានចាំបាច់សម្រាប់ធនាគារអនុវត្តទំនួលខុសត្រូវក្នុងការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន ដើម្បីកំណត់ តាមដាន និងសម្រេចបាននូវគោលដៅជាយុទ្ធសាស្រ្ត និងប្រតិបត្តិការ។ ការទំនាក់ទំនងកើតឡើងទាំងក្នុង ទាំងក្រៅធនាគារ និងផ្តល់ព័ត៌មានដែលធនាគារត្រូវការ ដើម្បីអនុវត្តសកម្មភាពត្រួតពិនិត្យផ្ទៃក្នុងប្រចាំថ្ងៃ។ ការទំនាក់ទំនងអាចឱ្យនិយោជិកទាំងអស់ទទួលស្គាល់នូវទំនួលខុសត្រូវត្រួតពិនិត្យផ្ទៃក្នុង។ គោលការណ៍សំខាន់ៗទាក់ទងនឹងព័ត៌មាននិងការទំនាក់ទំនងមានដូចខាងក្រោម៖

- ភាពទាន់ពេលវេលា និងគុណភាពព័ត៌មានដែលពាក់ព័ន្ធជួយគាំទ្រដល់ការអនុវត្តនូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ការទំនាក់ទំនងព័ត៌មានផ្ទៃក្នុង ចាំបាច់ក្នុងការជួយដល់ការបន្តដំណើរការនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។ និង
- ការទំនាក់ទំនងជាមួយភាគីខាងក្រៅទាក់ទងទៅនឹងច្បាប់ និងបទប្បញ្ញត្តិ ដែលប៉ះពាល់ដល់តម្រូវការនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

### ១.១.៥. សកម្មភាពតាមដាន

ការតាមដាន រួមមានដំណើរការវាយតម្លៃពីប្រសិទ្ធភាព និងសង្គតិភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ ដោយរាយការណ៍អំពីកង្វះខាតនៃការត្រួតពិនិត្យ និងធានាចំពោះថ្នាក់គ្រប់គ្រង និងក្រុមប្រឹក្សាភិបាល។ គោលការណ៍សំខាន់ៗទាក់ទងនឹងសកម្មភាពតាមដានរួមមាន៖

- ការវាយតម្លៃជាប់លាប់ ធានាថាប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងកំពុងដំណើរការ និងបំពេញមុខងារដូចបានកំណត់។ និង
- ការពិនិត្យឯករាជ្យលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ត្រូវបានវាយតម្លៃដោយសវនករផ្ទៃក្នុង និងសវនករខាងក្រៅ។ លទ្ធផលដែលរកឃើញ ឬកង្វះខាតក្នុងការត្រួតពិនិត្យ ត្រូវបានរាយការណ៍ទៅគណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល។

## ១.២. គោលនយោបាយ និងនីតិវិធីក្នុងការទទួលយកហានិភ័យ

ធនាគារបានធ្វើបច្ចុប្បន្នភាព និងបង្កើតគោលនយោបាយ និងនីតិវិធីគ្រប់គ្រងហានិភ័យរបស់ខ្លួនជាប្រចាំ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ និងការវិវត្តបរិយាកាសអាជីវកម្ម៖



- គោលនយោបាយសវនកម្មផ្ទៃក្នុង ត្រូវបានបង្កើតដំបូង និងអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧។ ក្រោយមកកំណែទី ២ និងទី ៣ នៃគោលនយោបាយ សវនកម្មផ្ទៃក្នុង ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ និងថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០។ ហើយកំណែទម្រង់ទី ៤ ចុងក្រោយនៃគោលនយោបាយសវនកម្មផ្ទៃក្នុង និងនីតិវិធីសវនកម្មប្រព័ន្ធព័ត៌មានវិទ្យាថ្មី កំណែទី ១ បានអនុម័តក្នុងថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ អោយសមស្របតាមគោលការណ៍ណែនាំការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យាដែលបានផ្សព្វផ្សាយដោយធនាគារជាតិនៃកម្ពុជា។
- គោលនយោបាយឥណទាន ត្រូវបានបង្កើតឡើងដំបូង និងអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៦។ ក្រោយមកត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នភាព ព្រមទាំងអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០២០។
- គោលនយោបាយគ្រប់គ្រងហានិភ័យសន្ទនីយភាព ត្រូវបានបង្កើតឡើង និងអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០កំណែលើកទី ២ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី ៥ ខែមករា ឆ្នាំ២០២២។
- គោលនយោបាយអភិបាលកិច្ចសាជីវកម្មត្រូវបានបង្កើត និងអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០២០ និងកំណែលើកទី ២ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី ៥ ខែមករា ឆ្នាំ២០២២។
- គោលនយោបាយប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) ត្រូវបានបង្កើតឡើង និងអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០។
- គោលនយោបាយឥណទានអ៊ីមភែរមិន (Loan Impairment Policy) ត្រូវបានបង្កើតឡើង និងអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០។

## ១.៣. គណៈកម្មាធិការសវនកម្ម

នៅថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០១៨ គណៈកម្មាធិការសវនកម្ម (Audit Board Committee (ABC)) ត្រូវបានបង្កើតឡើងជា អង្គភាពគ្រប់គ្រងតាមដានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ក្នុងអំឡុងពេលដែលធនាគាររបស់យើងនៅធ្វើប្រតិបត្តិការជាធនាគារឯកទេសមកម្ល៉េះ។ បន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណធនាគារពាណិជ្ជនៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៩ និងលិខិតអនុញ្ញាតលេខ ធ៧-០១៩-៧៦៦ ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១៩ ដើម្បីធ្វើប្រតិបត្តិការជាធនាគារពាណិជ្ជ គណៈកម្មាធិការសវនកម្មត្រូវបានប្តូរទៅជាគណៈកម្មាធិការសវនកម្ម និងប្រតិបត្តិតាម (Audit and Compliance Board Committee (ACBC)) ដើម្បីពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់យើងខ្ញុំ។

គោលបំណង សមាជិកភាព សិទ្ធិអំណាច ទំនួលខុសត្រូវ ការប្រជុំ និងការរាយការណ៍ របស់ ACBC មានដូចខាងក្រោម៖

### ១.៣.១.គោលបំណង

គោលបំណងរបស់ ACBC គឺជួយដល់ក្រុមប្រឹក្សាភិបាលក្នុងការបំពេញទំនួលខុសត្រូវត្រួតពិនិត្យលើ៖

#### មុខងារសវនកម្ម៖

- សុចរិតភាពនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។
- ធានាថាព័ត៌មានទាក់ទងនឹងហិរញ្ញវត្ថុ និងហានិភ័យមានភាពច្បាស់លាស់ និងវាយតម្លៃភាពពាក់ព័ន្ធនៃវិធីសាស្រ្តគណនេយ្យ និងវាយតម្លៃ ដែលត្រូវបានប្រើសម្រាប់ការបង្កើតគណនីដាច់ដោយឡែក និងគណនីរួម (តាមការណីជាក់ស្តែង) និងរបាយការណ៍ហិរញ្ញវត្ថុ។
- វាយតម្លៃគុណភាពនៃនីតិវិធីត្រួតពិនិត្យផ្ទៃក្នុង ជាពិសេសវាយតម្លៃថាតើប្រព័ន្ធវាស់ស្ទង់តាមដាន និងគ្រប់គ្រងហានិភ័យមានភាពស៊ីសង្វាក់គ្នា ឬយ៉ាងណា និងផ្តល់អនុសាសន៍ពីសកម្មភាពបន្ថែមទៀតនៅពេលណាដែលសមស្រប។
- តាមដានការអនុវត្តសកម្មភាពកែតម្រូវប្រកបដោយប្រសិទ្ធភាព ជាពិសេសតាមរយៈការតាមដានលើអនុសាសន៍ដែលកំពុងអនុវត្ត និងមិនទាន់អនុវត្ត ដែលចេញដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងគាំទ្របន្ថែមដល់ការងាររបស់សវនករផ្ទៃក្នុង។

#### មុខងារប្រតិបត្តិតាម៖

- អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន បទដ្ឋានវិជ្ជាជីវៈ និងក្រមសីលធម៌ បទប្បញ្ញត្តិជាក់លាក់ដែលចេញដោយអាជ្ញាធរទីផ្សារ ពាក់ព័ន្ធនឹងសកម្មភាពធនាគារ និងហិរញ្ញវត្ថុ ព្រមទាំងគោលនយោបាយ និងសេចក្តីណែនាំដែលចេញដោយស្ថាប័នធ្វើសេចក្តីសម្រេច។

## ១.៣.២. សមាជិកភាព

សមាសភាពនៃគណៈកម្មាធិការសវនកម្ម និងការប្រតិបត្តិតាម (ACBC) អនុលោមតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ដែលមានចែងដូចខាងក្រោម៖

- មានអភិបាលឯករាជ្យក្នុងក្រុមប្រឹក្សាភិបាលជាប្រធាន
- មានបុគ្គលឯករាជ្យយ៉ាងតិចមួយរូប ដែលមានជំនាញខាងហិរញ្ញវត្ថុ និងគណនេយ្យ
- មានបុគ្គលឯករាជ្យយ៉ាងតិចមួយរូប ដែលមានជំនាញផ្នែកច្បាប់ និងធនាគារ។

គណៈកម្មាធិការសវនកម្ម និងប្រតិបត្តិតាមមានសមាជិក បី(៣)រូប ពីក្រុមប្រឹក្សាភិបាល និងមានអភិបាលឯករាជ្យក្នុងក្រុមប្រឹក្សាភិបាលជាប្រធាន ដែលជំនាញផ្នែកគណនេយ្យ ធនាគារ សវនកម្ម និងច្បាប់៖

| លោក **Yu Yongshun** | លោក **វង្ស ពេជ្រ** | លោក **ឡាវ អៀវចុង** |
|---|---|---|
| អភិបាលឯករាជ្យ<br>ជាប្រធាន | ប្រធានក្រុមប្រឹក្សាភិបាល<br>ជាសមាជិក | អនុប្រធានក្រុមប្រឹក្សាភិបាល<br>ជាសមាជិក |

## ១.៣.៣. សិទ្ធិអំណាច

- គណៈកម្មាធិការសវនកម្ម និងប្រតិបត្តិតាម ទទួលបានសិទ្ធិអំណាចពីក្រុមប្រឹក្សាភិបាល។
- គណៈកម្មាធិការសវនកម្ម និងប្រតិបត្តិតាម ត្រូវបានអនុញ្ញាតដោយក្រុមប្រឹក្សាភិបាល ឱ្យ ទទួលបានព័ត៌មានទាំងអស់ពីនិយោជិក តាមសំណើដែលលើកឡើងដោយក្រុមប្រឹក្សាភិបាល។
- គណៈកម្មាធិការសវនកម្ម និងប្រតិបត្តិតាម មានសិទ្ធិជួលសារវាផ្នែកច្បាប់ ឬសេវាវិជ្ជាជីវៈផ្សេងៗពីខាងក្រៅ និងទទួលខុសត្រូវក្នុងការចាត់តាំងអ្នកពិគ្រោះយោបល់ណាមួយដោយគោរពតាមអនុសាសន៍របស់នាយកប្រតិបត្តិ។

## ១.៣.៤. ទំនួលខុសត្រូវ

### មុខងារសវនកម្ម៖

- ត្រួតពិនិត្យការងាររបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងធានាថាការងាររបស់នាយកដ្ឋានគាំទ្រដល់តម្រូវការប្រតិបត្តតាម និងគោលដៅជាយុទ្ធសាស្ត្ររបស់ធនាគារ អេភីឌី។
- ការវាយតម្លៃគុណភាពនៃនីតិវិធីត្រួតពិនិត្យផ្ទៃក្នុងជាពិសេសថាតើប្រព័ន្ធសម្រាប់វាស់វែង ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យ (រួមទាំងការសម្អាតប្រាក់ និងហានិភ័យហិរញ្ញប្បទានភេរវករ) មានភាពស៊ីសង្វាក់គ្នា និងផ្តល់អនុសាសន៍ឱ្យមានសកម្មភាពបន្ថែមទៀតនៅពេលសមស្រប។
- ធានាថារបាយការណ៍ត្រួតពិនិត្យផ្ទៃក្នុង និងរបាយការណ៍ពាក់ព័ន្ធផ្សេងទៀតដែលផ្តល់ទៅ ធនាគារជាតិនៃកម្ពុជា ស្ថាប័នរដ្ឋាភិបាលណាមួយ ឬសាធារណៈជនមានភាពច្បាស់លាស់ ត្រឹមត្រូវ និងអាចទុកចិត្តបាន។
- ជួយអ្នកគ្រប់គ្រងក្នុងការពិនិត្យឡើងវិញនូវលក្ខខណ្ឌនៃសេចក្តីយោង សម្រាប់សវនកម្មខាងក្រៅ។
- ផ្តល់អនុសាសន៍សម្រាប់ការតែងតាំង និងប្រាក់កម្រៃរបស់សវនករខាងក្រៅ។
- ត្រួតពិនិត្យការងារដែលអនុវត្តដោយសវនករខាងក្រៅ ដែលរក្សាទុកដើម្បីរៀបចំ ឬចេញរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម និងលិខិតទៅកាន់គណៈគ្រប់គ្រង។
- ទំនាក់ទំនងជាមួយសវនករខាងក្រៅ និងជំរុញការសន្ទនារវាងសវនករខាងក្រៅ និងក្រុមប្រឹក្សាភិបាល។
- ពិនិត្យ និងផ្តល់យោបល់លើគោលនយោបាយសម្រាប់ការអនុម័តរបស់ក្រុមប្រឹក្សាភិបាល។
- ការអនុម័តនីតិវិធី និងសៀវភៅណែនាំ ដើម្បីអនុវត្តគោលនយោបាយ។
- ការអនុម័តធម្មនុញ្ញសវនកម្មផ្ទៃក្នុង។
- ការអនុម័តផែនការសវនកម្មផ្អែកលើហានិភ័យ។
- ទទួលការទំនាក់ទំនងពីប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងលើការអនុវត្តសកម្មភាពសវនកម្មផ្ទៃក្នុង ទាក់ទងទៅនឹងផែនការរបស់ខ្លួន និងបញ្ហាផ្សេងៗទៀត។
- វាយតម្លៃភាពពាក់ព័ន្ធនៃវិធានគណនេយ្យ ដែលប្រើក្នុងការរៀបចំគណនីដោយឡែក និងគណនីរួមប្រសិនបើមាន។
- បង្កើតយន្តការសម្រាប់ដោះស្រាយបណ្តឹងទាក់ទងនឹងគណនេយ្យ ការត្រួតពិនិត្យផ្ទៃក្នុង និងសវនកម្ម។

### មុខងារប្រតិបត្តិតាម៖

- ត្រួតពិនិត្យការងាររបស់នាយកដ្ឋានប្រតិបត្តិតាម និងធានាថាធនាគារគោរពតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន បទដ្ឋានវិជ្ជាជីវៈ ក្រមសីលធម៌ លក្ខខណ្ឌប្រតិបត្តិតាមបទប្បញ្ញត្តិ និងរបាយការណ៍សំខាន់ៗ ឬការសាកសួរពីរដ្ឋាភិបាល ឬទីភ្នាក់ងារប្បញ្ញត្តិកម្ម។
- ត្រួតពិនិត្យការបង្កើត និងការអនុវត្តគោលនយោបាយ នីតិវិធី និងដំណើរការសម្រាប់វាយតម្លៃការប្រតិបត្តិតាម អនុម័តលក្ខណៈប្រព័ន្ធជាមុន លើផលិតផលថ្មី សកម្មភាពការអនុវត្ត ឬការផ្លាស់ប្តូរសំខាន់លើផលិតផល និងសេវាកម្មដែលកំពុងមាន ព្រមទាំងត្រួតពិនិត្យលើប្រតិបត្តិការដែលបានបញ្ចប់។
- បំពេញភារកិច្ចផ្សេងទៀតដែលចាត់តាំងដោយក្រុមប្រឹក្សាភិបាល។
- ការបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាពសម្រាប់ AML/CFT អនុលោមតាមតម្រូវការច្បាប់ និងបទប្បញ្ញត្តិ។
- ការយល់ដឹងអំពីវិធានការ AML/CFT ដែលតម្រូវដោយច្បាប់ស្តីពី AML/CFT បទប្បញ្ញត្តិពាក់ព័ន្ធ និងស្តង់ដារ និងការអនុវត្តល្អបំផុតរបស់ឧស្សាហកម្ម ព្រមទាំងសារៈសំខាន់នៃការអនុវត្តវិធានការ AML/CFT ដើម្បីការពារធនាគារពីការរំលោភបំពានដោយអ្នកសម្អាតប្រាក់ និងអ្នកផ្តល់ហិរញ្ញប្បទានភេរវកម្ម។
- ការវាយតម្លៃលើការអនុវត្តគោលនយោបាយ AML/CFT ដែលបានអនុម័តដោយគណៈគ្រប់គ្រងជាន់ខ្ពស់តាមរយៈរបាយការណ៍តាមកាលកំណត់។
- ការតែងតាំងមន្ត្រីប្រតិបត្តិតាម ដើម្បីធានាថាគោលនយោបាយ នីតិវិធី និងការគ្រប់គ្រងត្រូវតែមាននៅនឹងកន្លែង។
- ត្រូវប្រាកដថាតួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីប្រតិបត្តិតាម និងសវនករផ្ទៃក្នុងត្រូវបានកំណត់ និងចងក្រងជាឯកសារច្បាស់លាស់។

## ១.៣.៥.ការប្រជុំ

ACBC អាចប្រជុំបានញឹកញាប់តាមដែលសមរម្យ។ កូរ៉ុមសម្រាប់ការប្រជុំ ACBC ត្រូវមានអភិបាលយ៉ាងតិចពីររូប។ ក្នុងករណីប្រធានអវត្តមាន សមាជិកដែលមានវត្តមាននឹងជ្រើសរើសអភិបាលមួយរូបដើម្បីធ្វើជាអធិបតីនៃកិច្ចប្រជុំជំនួសប្រធាន។ សមាជិក ACBC នីមួយៗមានសិទ្ធិបោះឆ្នោតម្នាក់មួយសំឡេង ត្រូវបានតម្រូវឱ្យបោះឆ្នោត។ លេខាធិការនៃគណៈកម្មាធិការនេះមិនមានសិទ្ធិបោះឆ្នោតទេ។ ការសម្រេចនឹងត្រូវធ្វើឡើងដោយសំឡេងភាគច្រើន។ ប្រសិនបើមានការសំឡេងស្មើគ្នា ប្រធានគណៈកម្មាធិការមានសិទ្ធិបោះឆ្នោតមួយសំឡេងទៀតដើម្បីធ្វើការសម្រេចចុងក្រោយ។ ក្នុងករណីអវត្តមានពីសមាជិកណាមួយ ប្រធាន ACBC អាចតែងតាំងសមាជិកដទៃទៀតនៃក្រុមប្រឹក្សាភិបាល ឱ្យចូលរួមប្រជុំជាអ្នកតំណាងដើម្បីបំពេញកូរ៉ុមជាប្រូកស៊ីដើម្បីរក្សាចំនួនកូរ៉ុមដែលត្រូវការ។ សមាជិក ACBC គប្បីមានការប្រុងប្រយ័ត្ន ដើម្បីចៀសវាងទំនាស់ផលប្រយោជន៍ដែលអាចធ្វើឱ្យប៉ះពាល់ដល់វត្ថុបំណង និងឯករាជ្យភាពរបស់ពួកគេ។ ការប្រជុំនេះអាចមានការរៀបចំឡើងជាកិច្ចប្រជុំតាមប្រព័ន្ធអេឡិចត្រូនិក (ឧទាហរណ៍ អេឡិចត្រូនិក ឬទូរគមនាគមន៍) ដរាបណាអ្នកចូលរួមទាំងអស់អាចផ្លាស់ប្តូរយោបល់គ្នា និងពិភាក្សាលើសេចក្តីសម្រេច។

កំណត់ហេតុនៃកិច្ចប្រជុំ ACBC នឹងត្រូវកត់ត្រាដោយលេខាធិការ។ លេខាធិការចាំបាច់ត្រូវមានសីលធម៌ និងទំនួលខុសត្រូវផ្លូវច្បាប់ ដើម្បីធានាថាកំណត់ហេតុនោះ ឆ្លុះបញ្ចាំងត្រឹមត្រូវនូវកិច្ចពិភាក្សា និងសេចក្តីសម្រេចដែលបានលើកឡើងនៅក្នុងអង្គប្រជុំ។

នៅពេលចាប់ផ្តើមនៃការប្រជុំ លេខាធិការចាំបាច់ត្រូវធានាថា ប្រសិនបើមានទំនាស់ផលប្រយោជន៍ ត្រូវកត់ត្រាដោយគ្មានភាពលម្អៀង។ សេចក្តីព្រាងនៃកំណត់ហេតុអង្គប្រជុំ នឹងត្រូវចែកជូនសមាជិក ACBC ទាំងអស់ មុនពេលចែកជូនអ្នកចូលរួមដែលត្រូវបានអញ្ជើញ និងសមាជិកទាំងអស់នៃក្រុមប្រឹក្សាភិបាល។

នៅឆ្នាំនេះគណៈកម្មាធិការសវនកម្ម និងប្រតិបត្តិតាមបានបើកអង្គប្រជុំចំនួន៤លើក ក្នុងខែមីនា ខែកក្កដា ខែកញ្ញា និងដើមខែមករា ឆ្នាំ២០២២ ដើម្បីពិនិត្យ និងពិភាក្សាលើបញ្ហានានាទាក់ទងនឹងធនាគារ អេភីឌី។ សេចក្តីសង្ខេបនៃសកម្មភាពដែលបានធ្វើឡើងដោយ ACBC ក្នុងអំឡុងឆ្នាំ ២០២១ មានដូចខាងក្រោម៖

- បានពិនិត្យ និងពិភាក្សាលើរបាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ ២០២០ មុនពេលដាក់ជូន NBC
- បានពិនិត្យ និងពិភាក្សាអំពីរបាយការណ៍សវនកម្មឯករាជ្យសម្រាប់សារពើពន្ធឆ្នាំ ២០២០
- ពិនិត្យ និងអនុម័តផែនការសវនកម្ម និងកញ្ចប់ថវិកាសម្រាប់ឆ្នាំ ២០២១
- បានពិនិត្យរបាយការណ៍សវនកម្មផ្ទៃក្នុងប្រចាំត្រីមាសសម្រាប់ឆ្នាំ ២០២១
- បានពិនិត្យរបាយការណ៍អនុលោមភាពក្នុងកំឡុងឆ្នាំ ២០២១
- ពិនិត្យ និងអនុម័តផែនការសវនកម្ម និងកញ្ចប់ថវិកាក្នុងឆ្នាំ ២០២២
- បានអនុម័ត និងណែនាំលើនីតិវិធី និងគោលនយោបាយផ្សេងៗ។

### ១.៣.៦.ការរាយការណ៍

ប្រធានគណៈកម្មាធិការសវនកម្ម និងប្រតិបត្តិតាម នឹងធ្វើបច្ចុប្បន្នភាព ផ្តល់យោបល់ និងអនុសាសន៍ ដល់ក្រុមប្រឹក្សាភិបាលលើរាល់សកម្មភាព និងបញ្ហានានាក្រោមការទទួលខុសត្រូវរបស់ខ្លួន។ ការផ្តល់ យោបល់ទាំងនេះ អាចធ្វើឡើងក្នុងទម្រង់ជាកំណត់ហេតុអង្គប្រជុំជា របាយការណ៍លាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

## ការត្រួតពិនិត្យអចិន្ត្រៃយ៍

### ២.១. មុខងារត្រួតពិនិត្យអចិន្ត្រៃយ៍

ការគ្រប់គ្រងអចិន្ត្រៃយ៍ត្រូវបានបង្កើតឡើង ដើម្បីគ្រប់គ្រងការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានរបស់ធនាគារ នីតិវិធី និងដំណើរការប្រកបដោយប្រសិទ្ធភាពដើម្បីជៀសវាង ឬដោះស្រាយជាមួយស្ថានភាពជម្លោះផលប្រយោជន៍ ការបែងចែកភារកិច្ច និងការសម្រេចចិត្តឯករាជ្យក្នុងការអនុម័ត និងអនុវត្តគោលនយោបាយផ្ទៃក្នុង និងនីតិវិធីប្រកបដោយប្រសិទ្ធភាពទាក់ទងនឹងការគ្រប់គ្រងហានិភ័យក្នុងធនាគារ។

មុខងារត្រួតពិនិត្យអចិន្ត្រៃយ៍របស់ធនាគារគឺ ស្ថិតក្រោមការទទួលខុសត្រូវជាចម្បងរបស់៖

- ក្រុមប្រឹក្សាភិបាលក្នុងការអនុម័ត និងពិនិត្យគោលការណ៍ និងនីតិវិធី ដើម្បីធានាបាននូវការគ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារប្រកបដោយប្រសិទ្ធភាព។
- គណៈគ្រប់គ្រងមើលការខុសត្រូវដោយឈរលើមូលដ្ឋានបន្តប្រតិបត្តិការរបស់ធនាគារ និងធានាថាអ្វីៗទាំងអស់អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលអាចអនុវត្តបាន ទាំងក្នុងស្រុក និងអន្តរជាតិ ព្រមទាំងគោលនយោបាយ នីតិវិធី និងការណែនាំផ្ទៃក្នុងទាំងអស់។ និង
- នាយកដ្ឋានប្រតិបត្តិតាម ត្រូវពង្រឹងការគ្រប់គ្រងនេះ និងរក្សាការប្រុងប្រយ័ត្នចំពោះហានិភ័យនៃការមិនអនុលោមតាមច្បាប់។ ជាងនេះទៅទៀត ដើម្បីរក្សាបាននូវឯករាជ្យភាពនៃមុខងារប្រតិបត្តិតាម ទំនួលខុសត្រូវរបស់ខ្លួនមិនត្រូវប៉ះទង្គិចជាមួយមុខងារអាជីវកម្ម ឬកិច្ចការប្រតិបត្តិការឡើយ។

### ២.២. ការពិពណ៌នាសង្ខេបនៃគោលនយោបាយ និងនីតិវិធីនៃការត្រួតពិនិត្យអចិន្ត្រៃយ៍

ធនាគារបានបង្កើតគោលនយោបាយ និងនីតិវិធី ព្រមទាំងដាក់ឱ្យអនុវត្តដោយមានការតាមដាន ដើម្បីពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារដែលបំពេញតាមស្តង់ដារទទួលស្គាល់ដោយប្បញ្ញត្តិករ។ គោលនយោបាយ និងនីតិវិធីទាំងនេះ ត្រូវបានបង្កើតឡើង និងធ្វើវិសោធនកម្មឱ្យស្របទៅតាមការអភិវឌ្ឍន៍នៃប្រតិបត្តការធនាគារនិងការអនុវត្តបទប្បញ្ញត្តិ។គោលការណ៍និងនីតិវិធីទាំងនោះរួមបញ្ចូលដោយគ្មានដែនកំណត់ចំពោះដូចខាងក្រោម៖

- គោលនយោបាយប្រឆាំងការស៊ីសំណូក និងអំពើពុករលួយ ដើម្បីរំលឹកឡើងវិញនូវការប្តេជ្ញាចិត្តរបស់ធនាគារក្នុងការអនុលោមតាមច្បាប់អោយបានពេញលេញលើបទប្បញ្ញត្តិទាក់ទងនឹងការប្រឆាំងការស៊ីសំណូក និងអំពើពុករលួយ។
- គោលនយោបាយប្រឆាំងការសម្អាតប្រាក់ និងការប្រយុទ្ធប្រឆាំងនឹងការផ្តល់ហិរញ្ញប្បទានលើអំពើភេរវកម្ម (AML/CFT) ដើម្បីបម្រើជាគោលការណ៍ណែនាំសម្រាប់ធនាគារក្នុងការបំពេញតាមស្តង់ដារ AML/CFT ។
- គោលនយោបាយគ្រប់គ្រងការប្រតិបត្តិតាម ដើម្បីធ្វើជាការណែនាំជាមូលដ្ឋាន សម្រាប់ការគ្រប់គ្រងការប្រតិបត្តិតាមរបស់ធនាគារ។
- គោលនយោបាយដាក់ទណ្ឌកម្ម ដើម្បីធានាបាននូវការអនុលោមតាមបទប្បញ្ញត្តិ និងដើម្បីបង្កើត និងក្របខ័ណ្ឌផ្ទៃក្នុង ដែលការពារហានិភ័យនៃការបំពានទណ្ឌកម្ម។ និង
- គោលនយោបាយ វិស្សលប្លូវីង (Whistle blowing) ដើម្បីផ្តល់នូវយន្តការត្រឹមត្រូវ និងស្តង់ដារអប្បបរមាក្នុងការដោះស្រាយសកម្មភាពដែលអាចចោទសួរបាន ឬការធ្វើខុសដោយបុគ្គលិកណាមួយរបស់ធនាគារ។

### ២.៣. ការពិពណ៌នាសង្ខេបនៃរបាយការណ៍ស្តីពីការត្រួតពិនិត្យអចិន្ត្រៃយ៍

នៅក្រោមប្រព័ន្ធត្រួតពិនិត្យអចិន្ត្រៃយ៍ ក្រុមប្រឹក្សាភិបាលគឺជា ស្ថាប័នធ្វើសេចក្តីសម្រេចកំពូលរបស់ធនាគារ លើរបាយការណ៍ ឬអនុសាសន៍ទាំងអស់ពីគណៈគ្រប់គ្រង និងមុខងារប្រតិបត្តិតាមត្រូវបានធ្វើឡើង។

មុខងារប្រតិបត្តិតាម ជាធម្មតាជូនដំណឹងដល់អ្នកគ្រប់គ្រងអំពីហានិភ័យដែលអាចកើតមាន បញ្ហាដែលមិនប្រតិបត្តិតាមតាម ព្រមទាំងបញ្ហាថ្មី និងការធ្វើបច្ចុប្បន្នភាពបញ្ហាដែលប៉ះពាល់ដល់ការត្រួតពិនិត្យជាអចិន្ត្រៃយ៍ដល់គណៈគ្រប់គ្រងរបស់ធនាគារនៅក្នុងកិច្ចប្រជុំគ្រប់គ្រងប្រចាំសប្តាហ៍។ ផងដែរ បញ្ហាសំខាន់ៗត្រូវបានពិភាក្សា ដោះស្រាយ និងកត់ត្រាក្នុងកំណត់ហេតុកិច្ចប្រជុំ។

ក្រៅពីការរាយការណ៍ជូនគណៈគ្រប់គ្រង របាយការណ៍ទាក់ទងនឹងការគ្រប់គ្រងអចិន្ត្រៃយ៍ត្រូវបានរៀបចំ និងដាក់ជូនគណៈកម្មាធិការសវនកម្ម និងប្រតិបត្តិតាម(ACBC) ក្នុងអំឡុងពេលកិច្ចប្រជុំ។ របាយការណ៍ពិពណ៌នាអំពីសមិទ្ធផលការងារ បញ្ហាប្រឈម ការផ្តល់យោបល់ និងផែនការរបស់មុខងារប្រតិបត្តិតាម។

## ការត្រួតពិនិត្យតាមកាលកំណត់

### ៣.១. រចនាសម្ព័ន្ធសវនកម្មផ្ទៃក្នុង

លោក ចុល លីណា ត្រូវបានតែងតាំងជាប្រធានសវនកម្មផ្ទៃក្នុង នៅថ្ងៃទី ៦ ខែកក្កដា ឆ្នាំ២០១៩ និងទទួលបានការយល់ព្រមជាផ្លូវការពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ។ លោកមានបទពិសោធន៍ជាច្រើនឆ្នាំ ជាពិសេសក្នុងវិស័យធនាគារ។ លោកមានបទពិសោធន៏ច្រើនជាង ១០ ឆ្នាំ ក្នុងមុខតំណែងជាប្រធានផ្នែកបៀវត្សរ៍និងសារពើពន្ធ, ជាអ្នកគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងជាអ្នកគ្រប់គ្រងផ្នែកសវនកម្មផ្ទៃក្នុង និងជាសវនករជាន់ខ្ពស់ឯករាជ្យមកពីក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា ដែលជាក្រុមហ៊ុនសវនកម្មអន្តរជាតិមួយ។ លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រមកពី សាកលវិទ្យាល័យជាតិគ្រប់គ្រង ជាមួយនឹងកម្មវិធីសិក្សា អាហារូបករណ៍ពេញលេញរបស់អង្គការបារាំងនៅឆ្នាំ ២០១២។ លោកត្រូវបានទទួលស្គាល់ថាជាសវនករឈានមុខដែលទទួលបានវិញ្ញាបនបត្រស្តង់ដារអន្តរជាតិ ISO/IEC 27001:2013 ចេញដោយ Exemplar Global សហរដ្ឋអាមេរិចផងដែរ។ បច្ចុប្បន្នលោកកំពុងសិក្សា ដើម្បីទទួលសញ្ញាបត្រ ACCA Qualification គុណវុឌ្ឍិគណនេយ្យសម្រាប់កម្មវិធីអ្នកជំនាញហិរញ្ញវត្ថុពីសាលាធុរកិច្ច CamEd។

ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង រាយការណ៍ដោយផ្ទាល់ ឬដោយមុខងារទៅគណៈកម្មាធិការ សវនកម្ម និងប្រតិបត្តិតាម និងក្រុមប្រឹក្សាភិបាល ព្រមទាំងរាយការណ៍ដោយប្រយោល (reports with dotted line) ជូននាយកប្រតិបត្តិ។ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងទទួលបន្ទុកដឹកនាំចាត់ចែង និងសម្របសម្រួលក្រុមការងារសវនកម្មផ្ទៃក្នុងរបស់ធនាគារ ដើម្បីសំរេចគោលដៅរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធភាព និងសុខដុមភាព។ តួនាទីនិងទំនួលខុសត្រូវរបស់ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងគឺ៖

### ៣.១.១.ការវាយតម្លៃហានិភ័យ និងផែនការ

- ចូលរួមក្នុងការរៀបចំផែនការសកម្មភាព / ផែនការថវិកាយុទ្ធសាស្ត្រប្រចាំឆ្នាំ។
- រៀបរៀង / បង្ហាញតារាងកាលវិភាគសវនកម្ម / គំរោងថវិកាសម្រាប់សុំការអនុម័តពីគណៈកម្មាធិការសវនកម្ម និងប្រតិបត្តិតាម។
- អនុម័តបញ្ជីសវនកម្ម / ឯកសារសកម្មភាព កម្មវិធីសវនកម្មលើគ្រប់ផ្នែក តាមរយៈគន្លឹះពិសេស / អនុផែនការដំណើរការដែលរៀបរាប់លម្អិតក្នុងនីតិវិធីសវនកម្ម។
- អនុម័តផែនការ និងគំរូសកម្មភាពសវនកម្ម តាមផែនការសវនកម្មប្រចាំឆ្នាំដែលបានអនុម័ត។
- ចេញ / អនុម័តលិខិតបេសកកម្មការងារសម្រាប់រយៈពេលសវនកម្មនីមួយៗដល់សមាជិកសវនករ។
- តាមដានលទ្ធផលសវនកម្មប្រចាំត្រីមាស និងប្រចាំឆ្នាំធៀបនឹងផែនការ។
- អនុវត្តតាមគោលនយោបាយ និងនីតិវិធីសវនកម្ម ដូចដែលបានបញ្ជាក់ដោយមិនលំអៀងនិងដោយលម្អិត ព្រមទាំងពិនិត្យមើលថាបុគ្គលិកអនុវត្តតាមគោលនយោបាយ និងនីតិវិធីទាំងនោះ។

## ៣.១.២. ការប្រតិបត្តិសវនកម្ម

- ធានាថារាល់គោលនយោបាយ / និតិវិធី / អនុស្សរណៈ ទាំងអស់ត្រូវបានអនុវត្ត និងគោរពតាម។
- ធានាថា ហានិភ័យប្រតិបត្តិការ ហិរញ្ញវត្ថុ និងព័ត៌មានវិទ្យា ដែលធំៗ ត្រូវបានគ្រប់គ្រង និងកាត់បន្ថយ / ការពារ។

## ៣.១.៣. របាយការណ៍សវនកម្ម

- ធានាថា ក្រុមសវនករ រៀបចំរបាយការណ៍លើលទ្ធផលសវនកម្មសំខាន់ៗទាំងអស់ ស្របទៅតាមដំណើរការដែលបានកំណត់នៅក្នុងដំណើរការសវនកម្ម។
- ធានាថា របាយការណ៍សវនកម្មបង្ហាញពីលទ្ធផលដែលរកឃើញត្រឹមត្រូវហើយអនុសាសន៍ទាំងឡាយមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប។
- ផ្តល់ព័ត៌មានបន្ថែមដល់នាយកប្រតិបត្តិ និងប្រធាននាយកដ្ឋាន អំពីលទ្ធផលដែលរកឃើញសំខាន់ៗណាមួយនៅក្នុងរបាយការណ៍សវនកម្ម។
- សម្របសម្រួលរាល់សំណួរ / បញ្ហាទាំងអស់ពីនាយកដ្ឋានទាំងឡាយ សម្រាប់គោលបំណងធ្វើការឆ្លើយតបគ្រប់គ្រង / ផ្តល់មតិយោបល់លើរបាយការណ៍នោះ។
- ចេញ / បញ្ចប់របាយការណ៍សនវកម្មផ្ទៃក្នុង នៅក្នុងវិសាលភាពដែលបានកំណត់ ឱ្យបានទាន់ពេលវេលា និងធានាភាពត្រឹមត្រូវមុនពេលបញ្ជូនវាទៅគណៈកម្មាធិការសវនកម្ម និងប្រតិបត្តិតាម និងការគណៈគ្រប់គ្រងដែលពាក់ព័ន្ធ។
- ផ្តល់របាយការណ៍សង្ខេប / វឌ្ឍនភាពប្រចាំខែ ជូននាយកប្រតិបត្តិ ស្តីពីលទ្ធផលដែលរកឃើញសំខាន់ៗនៃសវនកម្ម។
- រៀបចំ / បង្ហាញរបាយការណ៍សវនកម្មប្រចាំត្រីមាស និងប្រចាំឆ្នាំជូនគណៈកម្មាធិការសវនកម្ម និងប្រតិបត្តិតាម។

## ៣.១.៤. ការអភិវឌ្ឍនីតិវិធីសវនកម្មនិងគោលនយោបាយផ្សេងទៀត

- ពិនិត្យ និងកែលម្អជានិច្ច សៀវភៅណែនាំសវនកម្មផ្ទៃក្នុង និងឯកសារសវនកម្ម។
- រៀបរៀងរបាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ តាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា។

## ៣.១.៥. ការអភិវឌ្ឍន៍វិជ្ជាជីវៈ

- ពិនិត្យ និងផ្តល់អនុសាសន៍ ថាតើការបណ្តុះបណ្តាលគ្រប់គ្រាន់ដល់បុគ្គលិក អំពីនីតិវិធីនិងគោលនយោបាយដែលបានធ្វើបច្ចុប្បន្នភាព។
- យោងតាមលទ្ធផលសវនកម្ម ផ្តល់ព័ត៌មានដល់ក្រុមការងារផ្នែកធនធានមនុស្ស ពីគម្លាតនៃជំនាញបុគ្គលិក និងការអនុវត្តមិនត្រឹមត្រូវនៃគោលនយោបាយរបស់ធនាគារ។
- ធ្វើការជាមួយថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងក្រុមការងារផ្នែកធនធានមនុស្ស ដើម្បីអប់រំដល់បុគ្គលិកអំពីគោលបំណងនៃការធ្វើសវនកម្មផ្ទៃក្នុង។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានសមាជិកគ្រប់គ្រាន់ ដើម្បីបំពេញសកម្មភាពរបស់ខ្លួនដោយមិនមានភាពរាំងស្ទះ សមស្របទៅតាមទំហំអាជីវកម្មរបស់ធនាគារ។ សមាជិកបន្ថែមកំពុងស្ថិតក្នុងដំណើរការជ្រើសរើសបុគ្គលិក ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនរបស់ធនាគារ។

ក្នុងការប្រកាសជ្រើសរើស និងជ្រើសរើសសវនករផ្ទៃក្នុងត្រូវបានចែងនៅក្នុងគោលនយោបាយធនធានមនុស្ស ប៉ុន្តែផ្នែកនេះបានរៀបរាប់យ៉ាងខ្លីអំពីលក្ខណៈសម្បត្តិ និងចំណេះដឹងសំខាន់ៗរបស់បុគ្គលិក អ្នកគ្រប់គ្រង និងប្រធានផ្នែកសវនកម្មផ្ទៃក្នុង។

- តម្រូវអោយមានចំណេះដឹងផ្នែកសវនកម្មផ្ទៃក្នុង និងគណនេយ្យ ហិរញ្ញវត្ថុ និងធនាគារ។
- ត្រូវមានចំណេះដឹងផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ និងវិស្វកម្មព័ត៌មានវិទ្យាសវនកម្ម។
- ត្រូវមានចំណេះដឹងជាមូលដ្ឋានអំពីប្រតិបត្តិការហិរញ្ញវត្ថុខ្នាតតូច ឬឧស្សាហកម្មធនាគារ ឬផ្នែកពាក់ព័ន្ធផ្សេងទៀត ប្រសិនបើអ្នកដាក់ពាក្យខាងក្នុង គាត់ត្រូវតែមានបទពិសោធន៍យ៉ាងតិច ៦ ខែ។
- បុគ្គលិកសវនកម្មផ្ទៃក្នុង ត្រូវដឹកនាំខ្លួនឯងដោយគោរពតាម "ក្រមសីលធម៌" របស់សវនកម្មផ្ទៃក្នុង នឹងប្រកាន់ខ្ជាប់នូវគោលការណ៍ និងនីតិវិធីរបស់ធនាគារអេភីឌី។
- ត្រូវដឹងពីអ្វីដែលល្អសម្រាប់អង្គភាព និងមានសមត្ថភាពបែងចែកចំណុចសំខាន់ៗ ចាប់ពីរឿងតូចតាចទៅ។ ទំនាក់ទំនង ការភ័យខ្លាច ឬការពេញចិត្តមិនគួរមានឥទ្ធិពលលើសកម្មភាពរបស់សវនករផ្ទៃក្នុងនោះទេ។
- ត្រូវមានទេពកោសល្យនៃការគិតទុកជាមុន និងមានចក្ខុវិស័យវែងឆ្ងាយនៅក្នុងផ្នែកសវនកម្ម ដើម្បីជាជំនួយអោយកាន់តែប្រសើរដល់ការគ្រប់គ្រង។
- មានជំនាញវិភាគ និងជំនាញទំនាក់ទំនងអោយកាន់តែប្រសើរ អ្នកកាន់តំណែងនេះ ត្រូវតែជាបុគ្គលដែលមានភាពម្ចាស់ការលើខ្លួនឯង ហើយមានសមត្ថភាពធ្វើសេចក្តីសន្និដ្ឋាន និងអនុសាសន៍អោយបានត្រឹមត្រូវ។
- ត្រូវមានភាពស្មោះត្រង់ ដែលអាចបំពេញការងាររបស់ខ្លួនដោយភាពស្មោះត្រង់ នាំមកនូវលទ្ធផលជាប្រយោជន៍រួមដល់គណៈគ្រប់គ្រង។

## ៣.២. ធនធានដែលបានផ្តល់ទៅឱ្យសវនកម្មផ្ទៃក្នុង

កញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់សវនកម្មផ្ទៃក្នុង ត្រូវបានរួមបញ្ចូលជាមួយផែនការសវនកម្មប្រចាំឆ្នាំដែលត្រូវបានអនុម័តដោយគណៈកម្មាធិការសវនកម្ម និងប្រតិបត្តិតាម។

សិទ្ធិអំណាចពេញលេញត្រូវបានផ្តល់ដល់សវនករផ្ទៃក្នុងដោយមិនមានការរាំងស្ទះ ទៅរាល់កំណត់ត្រារបស់ធនាគារ ទ្រព្យសម្បត្តិជាក់ស្តែង និងបុគ្គលដែលពាក់ព័ន្ធនឹងមុខងារណាមួយដែលកំពុងត្រួតពិនិត្យ។ បុគ្គលិកទាំងអស់ត្រូវបានស្នើសុំឱ្យជួយសវនកម្មផ្ទៃក្នុង ដើម្បីបំពេញមុខងាររបស់ពួកគេ។ សវនកម្មផ្ទៃក្នុងក៏មានសិទ្ធិចូលជួប ដោយគ្មានការរឹតត្បិតជាមួយ នាយកប្រតិបត្តិ ក៏ដូចជាប្រធានក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល។

ឯកសារ និងព័ត៌មានដែលផ្តល់ទៅឱ្យសវនកម្មផ្ទៃក្នុងកំឡុងពេលត្រួតពិនិត្យតាមកាលកំណត់ នឹងត្រូវបានចាត់ចែងក្នុងលក្ខណៈប្រុងប្រយ័ត្ន និងសម្ងាត់ដូចគ្នា ទៅនឹងបុគ្គលិកទាំងនោះជាធម្មតាទទួលខុសត្រូវចំពោះវា។

ដើម្បីធានាបាននូវគុណភាពនៃធនធាន និងបុគ្គលិករបស់សវនកម្មកិច្ចប្រជុំ ការត្រួតពិនិត្យផ្សេងៗត្រូវបានដាក់ឱ្យដំណើរការដើម្បីធានាឱ្យមានការកែលម្អ និងរក្សាបាននូវសក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃសកម្មភាពសវនកម្ម។

- ពិនិត្យអោយបានញឹកញាប់លើក្រមសីលធម៌របស់ សវនករផ្ទៃក្នុង
- ពិនិត្យមើលសមិទ្ធផលប្រចាំត្រីមាសធៀបនឹងផែនការដែលបានអនុម័ត
- លើកចំណុចខ្សោយទាក់ទងនឹងការងារសវនកម្មដែលបានបំពេញ
- បញ្ហាបានជួបប្រទះ និងកែលម្អ
- ចែករំលែកបទពិសោធន៍សវនកម្ម និងការពិភាក្សាទូទៅ។

## ៣.២.១. ការអភិវឌ្ឍ / ការបណ្តុះបណ្តាលបុគ្គលិក

បុគ្គលិកទទួលបានការបណ្តុះបណ្តាលបន្ថែម សញ្ញាបត្រ និងបទពិសោធន៍ ប៉ុន្តែពួកគេនឹងត្រូវបន្តបង្កើនសមត្ថភាពរបស់ពួកគេ ក្នុងការផ្តល់សេវាដែលត្រូវបានពង្រឹងគុណភាព និងមានគុណតម្លៃបន្ថែម។ ផែនការសវនកម្មឆ្នាំ ២០២១ ដែលត្រូវបានអនុម័ត បានលើកយកមកពិចារណានូវ ការបណ្តុះបណ្តាលជំនាញ ដែលចាំបាច់សម្រាប់បុគ្គលិកពង្រឹងជំនាញដែលពួកគេមាន និងរៀបចំផ្នែកថ្មីៗសម្រាប់ធ្វើវិសោធនកម្ម ក៏ដូចជា ការបណ្តុះបណ្តាលសញ្ញាបត្រដែលត្រូវមាន។ ការបណ្តុះបណ្តាលរបស់ពួកគេនឹងត្រូវបែងចែកជា៖

### ការបណ្តុះបណ្តាលខាងក្នុង

- គោលនយោបាយ និងនីតិវិធីចាំបាច់របស់ ធនាគារ អេភីឌី ក្រមសីលធម៌សម្រាប់សវនករផ្ទៃក្នុង ដំណើរការសវនកម្ម នីតិវិធីសវនកម្ម កម្មវិធីសវនកម្ម និងឯកសារការងារ (working paper) (រយៈពេល ១ សប្តាហ៍) សម្រាប់អ្នកជំនាញសវនកម្មថ្មី។
- ការបណ្តុះបណ្តាលការងារជាមួយសវនករជំនាញ (រយៈពេល ២ សប្តាហ៍) សម្រាប់អ្នកជំនាញសវនកម្មថ្មី។
- បណ្តុះបណ្តាលដោយរំលឹកឡើងវិញ (refreshing training) (ចំនួន ១ លើក) សម្រាប់អ្នកជំនាញសវនកម្មទាំងអស់។
- ការបង្វឹក និងត្រួតពិនិត្យគុណភាពសវនកម្ម (ចំនួន ១ លើក) សម្រាប់អ្នកជំនាញសវនកម្មថ្មីទាំងអស់។

### ការបណ្តុះបណ្តាលខាងក្រៅ

- មានវគ្គសិក្សាណាមួយមានដែលទាក់ទងនឹងចំណេះដឹងផ្នែកធនាគារ និងការពង្រឹងសមត្ថភាពបុគ្គលិក ដូចជាសវនកម្មផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព ការរៀបចំរបាយការណ៍សវនកម្ម គោលការណ៍ត្រួតពិនិត្យផ្ទៃក្នុង (COSO) ការគ្រប់គ្រងហានិភ័យសហគ្រាស ជំនាញទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពសម្រាប់អ្នកជំនាញសវនកម្មទាំងអស់។

### ៣.២.២.ការវាយតម្លៃលើការបំពេញការងារ

សូចនាករប្រតិបត្តិការសំខាន់ៗសម្រាប់សវនកម្មផ្ទៃក្នុងរបស់ធនាគារ អេភីឌី ត្រូវបានកំណត់សម្រាប់បុគ្គលិកសវនកម្មផ្ទៃក្នុង ដែលក្នុងនោះមានសូចនាករហិរញ្ញវត្ថុ ដំណើរការផ្ទៃក្នុង និងដើមទុនជាធនធានមនុស្សជាដើម ដើម្បីវាយតម្លៃគុណភាពការងារ និងការបំពេញការងាររបស់ពួកគេ។ សូចនាករប្រតិបត្តិការសំខាន់ៗរបស់ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង នឹងត្រូវពិនិត្យដោយគណៈកម្មាធិការសវនកម្ម និងប្រតិបត្តិតាម (ACBC) ។ លើសពីនេះទៀត រាល់តួនាទីរបស់សវនករក្រោមប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវពិនិត្យដោយប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង។

## ៣.៣. ការពិពណ៌នាអំពីវិន័យ

អនុវត្តតាមធម្មនុញ្ញសវនកម្មផ្ទៃក្នុងដែលត្រូវបានអនុម័តដោយគណៈកម្មាធិការសវនកម្ម និងប្រតិបត្តិតាម នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានសិទ្ធិឱ្យចូលមើល និងទាញយករបាយការណ៍ និងទិន្នន័យដើមទាំងអស់ចេញពីប្រព័ន្ធស្នូលរបស់ធនាគារ។

### ៣.៣.១.ក្រមសីលធម៌

កម្មវិធីសវនកម្មផ្ទៃក្នុងរបស់ធនាគារ អេភីឌី គឺអនុលោមតាមស្តង់ដារវិជ្ជាជីវៈរបស់សវនករផ្ទៃក្នុង និង ក្រមសីលធម៌។

បុគ្គលិកសវនកម្មផ្ទៃក្នុងត្រូវគ្រប់គ្រងខ្លួនឯងដោយប្រកាន់ខ្ជាប់នូវ "ក្រមសីលធម៌" របស់សវនករផ្ទៃក្នុង។ ធនាគារ អេភីឌី បានបង្កើតនីតិវិធីប្រតិបត្តិការសម្រាប់នាយកដ្ឋាននានា។ នីតិវិធីទាំងនេះ គឺសេចក្តីបន្ថែមទៅនឹងលក្ខន្តិកៈរបស់ពួកគេ។ ក្រៅពីនេះ សវនកម្មផ្ទៃក្នុងនឹងប្រកាន់ខ្ជាប់នូវគោលនយោបាយ និងនីតិ ព្រមទាំងគោលនយោបាយសវនកម្មផ្ទៃក្នុងរបស់ធនាគារ អេភីឌី។ គោលនយោបាយនេះរួមមានលក្ខណៈសម្បត្តិ នៃការបំពេញការងារ និងបទដ្ឋានអនុវត្តដើម្បីដឹកនាំនាយកដ្ឋានសវនកម្មផ្ទៃក្នុង។

បទដ្ឋានសីលធម៌ខាងក្រោម ដកស្រង់ពី ក្រមសីលធម៌ដែលសវនករផ្ទៃក្នុងត្រូវគោរពតាម៖

- ត្រូវមានកាតព្វកិច្ចសម្តែងភាពស្មោះត្រង់ សត្យានុភាព និងការយកចិត្តទុកដាក់ក្នុងការអនុវត្តមុខងារ និងទំនួលខុសត្រូវរបស់ពួកគេ។
- ដោយទទួលបានការជឿទុកចិត្តពីនិយោជករបស់ពួកគេ និងត្រូវបង្ហាញភក្តីភាពនៅលើគ្រប់បញ្ហាទាំងអស់ដែលទាក់ទងនឹងកិច្ចការរបស់ធនាគារ អេភីឌី ឬនរណាម្នាក់ដែលពួកគេកំពុងបម្រើសេវាកម្ម។ ប៉ុន្តែ សវនករផ្ទៃក្នុងមិនត្រូវចូលរួមក្នុងសកម្មភាពខុសច្បាប់ ឬសកម្មភាពមិនត្រឹមត្រូវណាមួយទាំងដោយខ្លួនបានដឹងនោះឡើយ។
- ចូលរួមចំណែកគោរពតាមច្បាប់ និងគោលបំណងនៃក្រមសីលធម៌របស់ធនាគារ អេភីឌី។
- មិនត្រូវទទួលយកកម្រៃ ឬអំណោយពីនិយោជិត អតិថិជន ឬអ្នកពាក់ព័ន្ធដទៃទៀតឡើយ លើកលែងតែមានការអនុញ្ញាតពីគណៈគ្រប់គ្រង។
- ត្រូវប្រយ័ត្នប្រយែងក្នុងការប្រើប្រាស់ព័ត៌មាន ដែលទទួលបានក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន។
- មិនត្រូវប្រើប្រាស់ព័ត៌មានសម្ងាត់ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនណាមួយឡើយ។
- ក្នុងការបញ្ចេញមតិ សវនករផ្ទៃក្នុងត្រូវប្រើប្រាស់រាល់ហេតុផលសមរម្យអាចទទួលយកបាន ក្នុងការប្រមូលបានភស្តុតាងជាក់ស្តែង គ្រប់គ្រាន់សម្រាប់បញ្ជាក់លើមតិនោះ។ នៅក្នុងរបាយការណ៍របស់ពួកគេសវនករផ្ទៃក្នុងត្រូវបង្ហាញអង្គហេតុសំខាន់ៗ ដែលពួកគេបានដឹង ហើយខណៈដែលមិនបង្ហាញអាចនឹងធ្វើឱ្យប៉ះពាល់ដល់របាយការណ៍លទ្ធផលនៃប្រតិបត្តិការកំពុងត្រូវបានពិនិត្យ ឬបិទបាំងការអនុវត្តខុសច្បាប់។
- បន្តខិតខំដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព និងប្រសិទ្ធភាពនៃសេវាកម្មរបស់ពួកគេ។

### ៣.៣.២.ឯករាជ្យភាព

សវនករផ្ទៃក្នុង មិនទទួលឥទ្ធិពលដោយប្រការណានៅក្នុងពីស្ថាប័ន មិនថាក្នុងការជ្រើសរើស វិសាលភាព នីតិវិធី ភាពញឹកញាប់ ពេលវេលា ឬខ្លឹមសារនៃរបាយការណ៍ឡើយ ដើម្បីអាចរក្សាបាននូវឥរិយាបថផ្លូវចិត្តដែលឯករាជ្យ និងមានសត្យានុភាព ដែលជាភាពចាំបាច់ក្នុងការធ្វើរបាយការណ៍។ ឯករាជ្យភាព នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង មានចែងនៅក្នុងគោលនយោបាយសវនកម្មផ្ទៃក្នុង និងក្នុងលក្ខន្តិកៈនៃគណៈ កម្មាធិការសវនកម្ម និងប្រតិបត្តិតាម។



### ៣.៣.៣.ទំនាស់ផលប្រយោជន៍

បុគ្គលិកទាំងអស់ត្រូវតែប្រកាសពីសាច់ញាតិដែលកំពុងធ្វើការនៅក្នុងធនាគារជាមួយគ្នា ហើយនៅក្នុងការអនុវត្តជាក់ស្តែង សមាជិកសវនកម្មផ្ទៃក្នុង នឹងត្រូវឱ្យទៅធ្វើសវនកម្មផ្ទៃក្នុងមួយទៀត ប្រសិនបើសកម្មភាព ឬប្រតិបត្តិការនៅក្នុងការពិនិត្យសវនកម្មនោះ ថាមានពាក់ព័ន្ធជាមួយសាច់ញាតិរបស់ពួកគេ ឬពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ជាមួយនឹងពួកគេ។

## ៣.៤. សកម្មភាពសវនកម្មផ្ទៃក្នុង

មុខងារសវនកម្មផ្ទៃក្នុង នឹងជួយដល់ស្ថាប័នក្នុងការបំពេញនូវចក្ខុវិស័យ បេសកកម្ម គំនិតផ្តួចផ្តើមយុទ្ធសាស្ត្រ និងគោលបំណងរបស់ខ្លួន ទន្ទឹមនឹងការប្រកាន់ខ្ជាប់នូវគុណតម្លៃស្នូលរបស់ខ្លួន តាមរយៈការនាំមកនូវវិធីសាស្ត្រប្រកបដោយវិន័យជាប្រព័ន្ធ ដើម្បីវាយតម្លៃ និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យទូទាំងសហគ្រាស ការត្រួតពិនិត្យផ្ទៃក្នុង និងប្រព័ន្ធនិងដំណើរការអភិបាលកិច្ច។

### ៣.៤.១. វិសាលភាពនៃសវនកម្មផ្ទៃក្នុងង

វិសាលភាពនៃសវនកម្មផ្ទៃក្នុងរួមមាន ការត្រួតពិនិត្យ និងវាយតម្លៃភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃអភិបាលកិច្ច ដំណើរការគ្រប់គ្រងហានិភ័យ ប្រព័ន្ធនៃរចនាសម្ព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងគុណភាពនៃការអនុវត្តទំនួលទទួលខុសត្រូវដែលបានកំណត់ ដើម្បីសម្រេចបាននូវគោលដៅ និងគោលបំណងដែលបានកំណត់របស់ធនាគារ។ វិសាលភាពនេះរួមមាន៖

ក). ហិរញ្ញវត្ថុ
ខ). ប្រតិបត្តិការ
គ). ប្រតិបត្តិតាម
ឃ). ពត៌មានវិទ្យា
ង). ការក្លែងបន្លំ និងភាពមិនប្រក្រតី

### ៣.៤.២. វិធីសាស្ត្រសវនកម្ម

វិធីសាស្ត្រសវនកម្មដំណាក់កាលនេះអនុញ្ញាតឱ្យសវនករផ្ទៃក្នុងអាច៖

- បង្កើតគោលការណ៍ណែនាំសម្រាប់ការបំពេញសវនកម្មផ្ទៃក្នុង
- កំណត់ដំណើរការសវនកម្មផ្ទៃក្នុងទាំងមូល ជាជាងការសង្កត់ធ្ងន់ទៅលើធាតុផ្សំនៃការស្រាវជ្រាវដល់កន្លែង ដែលជាវិសាលភាពនៃដំណើរការសវនកម្មផ្ទៃក្នុង
- បង្កើតទំនួលខុសត្រូវ និងលទ្ធផលសម្រាប់ដំណាក់កាលនីមួយៗ នៃដំណើរការសវនកម្មផ្ទៃក្នុង
- ផ្តល់ការប្រាស្រ័យទាក់ទងយ៉ាងទៀងទាត់ ដែលបម្រើក្នុងការត្រួតពិនិត្យ និងកត់ត្រាដំណើរការសវនកម្មផ្ទៃក្នុង។

វិធីសាស្ត្រសវនកម្មនេះ គឺជាយន្តការសម្រាប់រៀបចំផែនការប្រតិបត្តិ និងត្រួតពិនិត្យលើមុខងារសវនកម្មផ្ទៃក្នុងតាមរយៈរបាយការណ៍តាមកាលកំណត់។

### ៣.៤.៣. បច្ចេកទេសសវនកម្ម

ក្នុងអំឡុងពេលដំណើរការសវនកម្មផ្ទៃក្នុង សវនករផ្ទៃក្នុងអាចប្រើបច្ចេកទេសសវនកម្មមួយ ឬច្រើន ហើយបច្ចេកទេសបែបនេះរួមមាន ប៉ុន្តែមិនកំណត់ចំពោះ៖

- **ការសង្កេត និងការសាកសួរ៖**

សវនករផ្ទៃក្នុងអាចសង្កេតមើលប្រតិបត្តិការនៃមុខងារ សកម្មភាព នាយកដ្ឋាន ឬអង្គភាពរបស់ធនាគារ។ សវនករផ្ទៃក្នុងក៏អាចធ្វើការ សាកសួររកហេតុផលអំពីនិយោជិតរបស់ធនាគារ ក្នុងការប៉ុនប៉ងអនុវត្តដំណើរការសវនកម្មផ្ទៃក្នុងផងដែរ។

- **ការវិភាគ និងការពិនិត្យឡើងវិញ៖**

មុខងារសវនកម្មផ្ទៃក្នុងគឺជា ការវិភាគដោយប្រុងប្រយ័ត្ន និងការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ ទាំងទិន្នន័យហិរញ្ញវត្ថុ និងទិន្នន័យប្រតិបត្តិការ។ ក្នុងករណីខ្លះ វានឹងសម្រេចបានតាមរយៈការប្រៀបធៀបសមតុល្យបច្ចុប្បន្នជាមួយនឹងអំឡុងពេលពីមុន។ បច្ចេកទេសទូទៅផ្សេងទៀត ដែលនឹងត្រូវប្រើប្រាស់នៅពេលអនុវត្តការវិភាគ និងត្រួតពិនិត្យសកម្មភាព ដូចការបំបែកគណនីបុគ្គលនីមួយៗ ទៅក្នុងព័ត៌មានលម្អិតដែលជាធាតុសំខាន់ៗ ឬធម្មតាទំនងជាត្រូវបានគូសបញ្ជាក់ ដូច្នេះហើយទើបត្រូវបានជ្រើសរើសសម្រាប់ការស៊ើបអង្កេត។ បច្ចេកទេសផ្សេងទៀតនឹងត្រូវបានប្រើជាចាំបាច់ ដើម្បីសម្រេចបាននូវកម្រិតសមស្របនៃការវិភាគត្រួតពិនិត្យ ក្នុងអំឡុងពេលដំណើរការសវនកម្មផ្ទៃក្នុង។

- **អធិការកិច្ច៖**

សវនករផ្ទៃក្នុងមានសិទ្ធិអំណាចក្នុងការត្រួតពិនិត្យទ្រព្យសម្បត្តិរូបវន្ត ឯកសារ និងភស្តុតាងផ្សេងទៀត ដែលគាំទ្រទិន្នន័យពាក់ព័ន្ធរបស់សវនករកំពុងត្រួតពិនិត្យ។ ដំណើរការទាំងនេះជាធម្មតា ត្រូវបានសម្រេចដោយការផ្ទៀងផ្ទាត់ប្រតិបត្តិការ ដែលប្រើបច្ចេកទេសសវនកម្មមូលដ្ឋានដូចខាងក្រោម៖

- **សក្ខីកម្ម (Vouching)៖**

គឺជាការផ្ទៀងផ្ទាត់វត្ថុធាតុ ដោយប្រៀបធៀបពួកវាទៅនឹងឯកសារដើមដែលមានមូលដ្ឋាន ។ បច្ចេកទេសនេះជួយធានាបាននូវភាពត្រឹមត្រូវ ភាពស្មោះត្រង់ សុពលភាព ឬការពិតនៃវត្ថុធាតុដែលកំពុងត្រួតពិនិត្យ។

- **ការគណនាឡើងវិញ៖**

គឺជាដំណើរការនៃការគណនាឡើងវិញនូវការគណនាដែលបានជ្រើសរើសដើម្បីកំណត់ភាពត្រឹមត្រូវរបស់វា។

- **ការត្រួតពិនិត្យជាក់ស្តែងនៃនិតិវិធីការចុះបញ្ជីគណនេយ្យ៖**

ជាការរួមបញ្ចូលទាំងកការត្រួតពិនិត្យលើការចុះបញ្ជីរបាយការណ៍ទៅក្នុងបញ្ជីទិន្នានុប្បវត្ត និងផ្ទុយត្រឡប់ មកវិញ។

- **ការរាប់ដោយផ្ទាល់៖**

ដែលបច្ចេកទេសនេះ ត្រូវបានប្រើដើម្បីបញ្ជាក់ពីភាពជឿទុកចិត្តបាននៃកំណត់ត្រាដែលកំពុងពិនិត្យ។ ក្នុងការអនុវត្តបច្ចេកទេសនេះ សវនករផ្ទៃក្នុងត្រូវ៖ (១) កំណត់នូវអ្វីដែលកំពុងពិនិត្យ (២) កំណត់អត្ថិភាពនៃវត្ថុដែលកំពុងពិនិត្យ។ (៣) កំណត់លក្ខខណ្ឌនៃវត្ថុដែលកំពុងពិនិត្យ និង (៤) ផ្ទៀងផ្ទាត់បរិមាណនៃវត្ថុដែលកំពុងពិនិត្យ។

- **ការបញ្ជាក់៖**

សុពលភាពនៃវត្ថុធាតុ ដែលបង្ហាញនៅលើកំណត់ត្រា អាចត្រូវបានបង្កើតឡើង ដោយការទទួលបានការបញ្ជាក់ ដោយផ្ទាល់ពីភាគីទីបីនៅក្នុងទីតាំងមួយដើម្បីផ្ទៀងផ្ទាត់សុពលភាពនៃវត្ថុធាតុដែលបានផ្តល់ឱ្យ។ សំណើសម្រាប់ការបញ្ជាក់បែបនេះ ត្រូវតែធ្វើតាមប្រៃសណីយ៍ដោយសវនករផ្ទៃក្នុង ហើយត្រូវភ្ជាប់មកជាមួយនូវស្រោមសំបុត្រត្រឡប់មកវិញ ដែលផ្ញើទៅកាន់សវនករផ្ទៃក្នុង។

- **ការស្កេន៖**

គឺជាដំណើរការនៃការត្រួតពិនិត្យយ៉ាងឆាប់រហ័ស ប៉ុន្តែត្រូវធ្វើដោយប្រុងប្រយ័ត្ននូវគណនី បញ្ជីទិន្នានុប្បវត្ត ឯកសារ ឬកំណត់ត្រាផ្សេងទៀតសម្រាប់វត្ថុធាតុដែលគួរឱ្យសង្ស័យ មិនធម្មតា ឬមិនសមរម្យ។ ការស្កេននឹងត្រូវបានប្រើនៅក្នុងដំណើរការសវនកម្មផ្ទៃក្នុងនៅពេលណាដែលវាត្រូវបានគេកំណត់ថា ដំណើរការនេះមានឱកាសសមហេតុផលក្នុងការបន្ថែមតម្លៃ។

## ៣.៤.៤. របាយការណ៍សវនកម្មផ្ទៃក្នុង

របាយការណ៍ជាលាយលក្ខណ៍អក្សរនឹងត្រូវបានរៀបចំ និងចេញដោយប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ឬអ្នកចាត់តាំង បន្ទាប់ពីបញ្ចប់សវនកម្មនីមួយៗ ហើយនឹងត្រូវបានចែកចាយតាមភាពសមស្រប។ ច្បាប់ចម្លងនៃរបាយការណ៍សវនកម្មនីមួយៗ និងការសង្ខេបនឹងត្រូវបានបញ្ជូនបន្តទៅនាយកប្រតិបត្តិ និងប្រធានគណៈកម្មាធិការសវនកម្ម និងប្រតិបត្តិតាម។

របាយការណ៍សវនកម្មភ្លាមៗ និងទាន់ពេលវេលា មានសារៈសំខាន់ក្នុងដំណើរការកែលម្អ ឬសកម្មភាពកែតម្រូវសម្រាប់អនុសាសន៍សវនកម្មផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។ គោលការណ៍ណែនាំខាងក្រោមសម្រាប់ភាពទាន់ពេលនៃរបាយការណ៍សវនកម្មគួរតែអនុវត្តជាធម្មតា៖

- សេចក្តីព្រាងរបាយការណ៍សវនកម្មគួរតែ ត្រូវបានបញ្ចប់ក្នុងរយៈពេលមួយសប្តាហ៍គិតចាប់ពីថ្ងៃបញ្ចប់ការងារសវនកម្ម។
- រាល់ការកែប្រែចំពោះសេចក្តីព្រាងរបាយការណ៍សវនកម្ម ដំណោះស្រាយពីការប្រជុំបញ្ចប់ គួរតែត្រូវបានបញ្ចប់ក្នុងរយៈពេលមួយសប្តាហ៍ បន្ទាប់ពីកាលបរិច្ឆេទនៃកិច្ចប្រជុំចុងក្រោយ។
- របាយការណ៍សវនកម្មចុងក្រោយគួរតែត្រូវបានបញ្ចប់ និងដាក់ចេញក្នុងរយៈពេលមួយសប្តាហ៍នៃកាលបរិច្ឆេទនៃកិច្ចប្រជុំចុងក្រោយ។

ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ឬអ្នកចាត់តាំងអាចរួមបញ្ចូលនៅក្នុងរបាយការណ៍សវនកម្ម ការឆ្លើយតបរបស់នាយកដ្ឋានរងសវនកម្ម និងសកម្មភាពកែតម្រូវដែលបានធ្វើឡើង ឬត្រូវធ្វើឡើងទាក់ទងនឹងការរកឃើញចំណុចខ្វះខាត និងអនុសាសន៍ជាក់លាក់។ ការឆ្លើយតបរបស់គណៈគ្រប់គ្រងគួរតែរួមបញ្ចូលក្នុងតារាងពេលវេលាសម្រាប់ការបញ្ចប់សកម្មភាព ដូចដែលត្រូវបានរំពឹងទុក និងការពន្យល់អំពីអនុសាសន៍ណាមួយដែលមិនត្រូវបានដោះស្រាយ។

នៅក្នុងករណី ដែលការឆ្លើយតបមិនត្រូវបានរាប់បញ្ចូលក្នុងរបាយការណ៍សវនកម្ម គណៈគ្រប់គ្រងនៅក្នុងតំបន់ដែលធ្វើសវនកម្មគួរតែឆ្លើយតបជាលាយលក្ខណ៍អក្សរក្នុងរយៈពេលប្រាំថ្ងៃ គិតក្នុងថ្ងៃធ្វើការ។

សវនកម្មផ្ទៃក្នុងត្រួតពិនិត្យសកម្មភាព និងវឌ្ឍនភាពឆ្ពោះទៅតាមផែនការប្រតិបត្តិការ និងយុទ្ធសាស្ត្រប្រចាំឆ្នាំ ហើយការរាយការណ៍ព័ត៌មានដែលពាក់ព័ន្ធទៅគណៈកម្មាធិការសវនកម្មនិងប្រតិបត្តិតាមជាបន្តបន្ទាប់រយៈពេលពេញមួយឆ្នាំ។

ការរកឃើញកំហុសឆ្គងធ្ងន់ធ្ងរនឹងនៅតែស្ថិតក្នុងរបាយការណ៍របស់សវនកម្ម រហូតដល់មានការសម្រេចចិត្តដោយប្រធានសវនកម្មផ្ទៃក្នុង ឬគណៈកម្មាធិការសវនកម្ម និងនិងប្រតិបត្តិតាម។

ប្រធានសវនកម្មផ្ទៃក្នុង ត្រូវតែអនុវត្តសកម្មភាពតាមដានដើម្បីឆ្លុះបញ្ចាំងពីភាពទាន់ពេលនៃសកម្មភាពកែតម្រូវ ដែលធ្វើឡើងដោយគណៈគ្រប់គ្រងទាក់ទងនឹង លទ្ធផលសវនកម្មរកឃើញ និងអនុសាសន៍ដែលបានផ្តល់។ វិធានការដោះស្រាយត្រូវបានទទួលយក ហើយផែនការដែលបានស្នើឡើង ត្រូវបានរាយការណ៍ទៅគណៈកម្មាធិការសវនកម្ម និងនិងប្រតិបត្តិតាម។ របាយការណ៍សវនកម្មគឺសម្រាប់តែការប្រើប្រាស់ផ្ទៃក្នុងប៉ុណ្ណោះ ហើយត្រូវរក្សាជាការសម្ងាត់។

## ៣.៤.៥. គុណភាពនៃរបាយការណ៍សវនកម្ម

របាយការណ៍សវនកម្មផ្ទៃក្នុង គួរតែផ្អែកលើអង្គហេតុ ហើយគួរតែរួមបញ្ចូលតែព័ត៌មានដែលត្រូវបានគាំទ្រដោយភស្តុតាងសវនកម្ម។ ភាពត្រឹមត្រូវនៃរបាយការណ៍នឹងអាស្រ័យលើភាពជឿជាក់នៃភស្តុតាង។ ភាពត្រឹមត្រូវនៃរបាយការណ៍អាចត្រូវបាន ពង្រឹងបន្ថែមទៀតដោយការពិភាក្សាអំពីសេចក្តីព្រាងរបាយការណ៍ ជាមួយនឹងគណៈគ្រប់គ្រងសមស្របនៅក្នុងអង្គភាពដែលបានធ្វើសវនកម្ម។ របាយការណ៍គួរតែអានបាន ហើយងាយស្រួលយល់ ន័យត្រង់ និងសង្ខេប។ វាក្យសព្ទដែលបានប្រើត្រូវតែសមស្របទៅតាមបុគ្គលដែលត្រូវរាយការណ៍ ហើយខ្លឹមសារនៃរបាយការណ៍ត្រូវតែមានភាពច្បាស់លាស់ និងន័យពិតប្រាកដ។

គោលបំណងនៃរបាយការណ៍សវនកម្មគឺ ដើម្បីធានាឱ្យមានវិធានការកែតម្រូវ ដោយមន្ត្រីដែលទទួលបន្ទុក ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការអនុវត្តរបស់ធនាគារ អេភីឌី។ ហេតុនេះហើយ អនុសាសន៍ដែលបានផ្តល់ជូនគួរត្រូវបានស្រាវជ្រាវឱ្យបានល្អ។ ការចេញរបាយការណ៍ទាន់ពេលវេលាគឺមានសារៈសំខាន់ ពីព្រោះប្រសិនបើរបាយការណ៍ត្រូវចំណាយពេលយូរក្នុងការចេញអនុសាសន៍សវនកម្មប្រហែលជាលែងមានប្រយោជន៍ដូចចេញក្នុងពេលឆាប់រហ័ស។ របាយការណ៍គួរតែត្រូវបានបង្ហាញដោយការគោរព វិជ្ជាជីវៈ និងសម្លេងអព្យាក្រឹត។ ទាំងនេះនឹងបង្កើនភាពអាចទទួលយកបាននៃរបាយការណ៍ ហើយវាប្រហែលជាមានភាគរយតិចជាង ដែលសវនករនឹងត្រូវបានគេយល់ថាមានភាពលំអៀង។

ស្តង់ដារដែលវិទ្យាស្ថានសវនករផ្ទៃក្នុង បានប្រកាសឱ្យប្រើប្រាស់បានរៀបរាប់អំពីភាពត្រឹមត្រូវ គោលបំណង ភាពច្បាស់លាស់ សង្ខេប ស្ថាបនា ពេញលេញ និងទាន់ពេលវេលា ដែលជាគុណភាពនៃរបាយការណ៍សវនកម្ម។

- **ភាពត្រឹមត្រូវ៖**

របាយការណ៍ត្រឹមត្រូវគឺមិនមានកំហុស និងការបង្ខូចទ្រង់ទ្រាយ ហើយស្មោះត្រង់ឈរលើមូលដ្ឋានការពិត។ ភាពត្រឹមត្រូវនៃខ្លឹមសាររបាយការណ៍ បង្កើតភាពជឿជាក់លើរបាយការណ៍ និងលើកទឹកចិត្តពួកគេឱ្យអនុវត្តតាមអនុសាសន៍។

- **គោលបំណង៖**

កត្តាចាំបាច់ក្នុងវិជ្ជាជីវៈសវនកម្ម ហើយរបាយការណ៍សវនកម្មគួរតែមានភាពយុត្តិធម៌ និងមិនលំអៀង ហើយជាលទ្ធផលនៃការវាយតម្លៃដោយយុត្តិធម៌ និងមានតុល្យភាពនៃអង្គហេតុ និងកាលៈទេសៈដែលពាក់ព័ន្ធទាំងអស់។

- **ភាពច្បាស់លាស់៖**

ជាលក្ខណៈសំខាន់មួយនៃរបាយការណ៍សវនកម្ម ហើយរបាយការណ៍ត្រូវតែអានងាយស្រួលយល់ និងសមហេតុសមផលជៀសវាងភាសាបច្ចេកទេសដែលមិនចាំបាច់ និងផ្តល់ព័ត៌មានសំខាន់ៗ និងពាក់ព័ន្ធទាំងអស់។

- **សង្ខេប៖**

របាយការណ៍ដែលសង្ខេបជារបាយការណ៍ដែលចំគោលដៅ និងជៀសវាងការលម្អិតដែលមិនចាំបាច់ ឬព័ត៌មានលម្អិតហួសហេតុ ពាក្យដដែលៗ និងពាក្យពេចន៍។ សវនករគួរតែផ្តោតលើសារដែលត្រូវទំនាក់ទំនងតាមរយៈរបាយការណ៍ ព្រាងសារ ឬអត្ថបទនៃរបាយការណ៍ជាទម្រង់សង្ខេប។

- **ស្ថាបនា៖**

តួនាទីនៃសវនកម្មផ្ទៃក្នុង គឺដើម្បីជួយឱ្យអង្គភាពសម្រេចបាននូវគោលបំណងរបស់ខ្លួន ហើយរបាយការណ៍សវនកម្មផ្ទៃក្នុង គួរតែមានលក្ខណៈស្ថាបនាដែលជួយដល់អង្គភាព ទៅរកការកែលម្អតាមតម្រូវការ។

- **ពេញលេញ៖**
របាយការណ៍សវនកម្មពេញលេញមិនមានចំនុចខ្វះខាតសំខាន់សម្រាប់ទស្សនិកជនគោលដៅ ហើយរួមបញ្ចូលព័ត៌មាន និងការសង្កេតសំខាន់ៗ និងពាក់ព័ន្ធទាំងអស់ ដើម្បីគាំទ្រអនុសាសន៍ និងការសន្និដ្ឋាន។
- **ទាន់ពេលវេលា៖**
របាយការណ៍ទាន់ពេលវេលាគឺជាឱកាស និងភាពសមស្រប ដែលអាស្រ័យលើសារៈសំខាន់នៃបញ្ហា ដែលអនុញ្ញាតឱ្យមានចាត់វិធាន ការកែតម្រូវសមស្រប របាយការណ៍គួរតែត្រូវបានចេញតាមកាលបរិច្ឆេទ ដែលបានគ្រោងទុក និងរៀបរាប់នៅក្នុងផែនការសវនកម្ម ហើយការពន្យាពេលណាមួយទាមទារហេតុផល និងការយល់ព្រមពីប្រធានសវនកម្មផ្ទៃក្នុង។

## សកម្មភាព និងសេវាកម្ម របស់តតិយភាគី

បច្ចុប្បន្ន ធនាគារបានប្រើប្រាស់សេវាកម្មរបស់តតិយភាគី ដែលមានកេរ្តិ៍ឈ្មោះល្អនៅក្នុងឧស្សាហកម្មនីមួយៗរបស់គេដូចខាងក្រោម៖

- ការគណនាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំត្រូវបានផ្តល់ជូនទៅក្រុមហ៊ុន VDB Loi Limited ដែលជាក្រុមហ៊ុនក្នុងតំបន់ដែលមានការិយាល័យរបស់ខ្លួនមានវត្តមាននៅក្នុងប្រទេសកម្ពុជា ឡាវ វៀតណាម ឥណ្ឌូនេស៊ី និងមីយ៉ាន់ម៉ា។ ដូច្នេះ VDB Loi លីមីធីត ទទួលខុសត្រូវក្នុងការរៀបចំ និងដាក់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំទៅអគ្គនាយកដ្ឋានពន្ធដារក្នុងនាមធនាគារ។
- គម្រោងរៀបចំបម្លែងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិកម្ពុជា ជាមួយក្រុមហ៊ុន Deloitte Cambodia ដើម្បីជួយធនាគារបំប្លែងពីក្របខណ្ឌគណនេយ្យ CAS ទៅជាក្របខណ្ឌគណនេយ្យ CIFRS។ ក្រុមហ៊ុន Deloitte Cambodia ទទួលខុសត្រូវក្នុងការកំណត់គម្លាតរវាងក្របខ័ណ្ឌទាំងពីរ ក៏ដូចជាការផ្តល់ការប្រឹក្សាដល់ធនាគារអំពីរបៀបអនុវត្តវា។ ជាមួយនឹងជំនាញ និងបទពិសោធន៍របស់ពួកគេ ធនាគារអាចទទួលបានគុណប្រយោជន៍ជាច្រើនតាមរយៈ សេវាកម្មស្តង់ដារអន្តរជាតិ និងការធ្វើតេស្តដែលមានទំនុកចិត្ត និងការអនុវត្តតាមស្តង់ដារ។
- ការវាយតម្លៃភាពងាយរងគ្រោះ និងការធ្វើតេស្តការជ្រៀតចូល (VAPT) ជាមួយក្រុមហ៊ុន KPMG (Cambodia) ជួយការពារប្រព័ន្ធព័ត៌មានវិទ្យារបស់ធនាគារ រួមទាំងកម្មវិធីទូរស័ព្ទ និងកម្មវិធីគេហទំព័រ ដោយចង្អុលបង្ហាញភាពទន់ខ្សោយផ្នែកសុវត្ថិភាព និងការណែនាំដើម្បីដោះស្រាយភាពទន់ខ្សោយទាំងនោះ។
- របាយការណ៍វាយតម្លៃគម្លាតជាមួយក្រុមហ៊ុន Deloitte (Cambodia) ដើម្បីផ្តល់នូវការវាយតម្លៃឯករាជ្យលើការវាយតម្លៃដោយខ្លួនឯងដែលធ្វើឡើងដោយធនាគារ លើគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហានិភ័យផ្នែកបច្ចេកវិទ្យា ("TRMG") ដែលចេញដោយធនាគារជាតិនៃកម្ពុជា ដើម្បីធានាថាតម្រូវការរបស់ TRMG ត្រូវបានបំពេញប្រកបដោយប្រសិទ្ធភាព។

ការរប្រើប្រាស់សេវាកម្មរបស់តតិយភាគីមិនបានផ្ទេរហានិភ័យទេ ដូច្នេះហើយគណៈគ្រប់គ្រងរបស់ធនាគារ នៅតែតម្រូវអោយយកចិត្តទុកដាក់បន្ថែមទៀតចំពោះការគ្រប់គ្រងលើសកម្មភាពសេវាកម្មរបស់តតិយភាគី។ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ត្រូវតែធានាថាហានិភ័យនៃសេវាកម្មរបស់តតិយភាគីត្រូវបានគ្រប់គ្រង ដូច្នេះការសម្រេចបាននូវគោលបំណង យុទ្ធសាស្ត្ររបស់ធនាគារមិនត្រូវបានរំខានដោយប្រការណាឡើយ។

សវនកម្មផ្ទៃក្នុងក៏ត្រូវបានចូលរួមផងដែរ ក្នុងតួនាទីសំខាន់ក្នុងការបន្ថែមតម្លៃ ដោយពិនិត្យមើលប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រងទាំងសម្រាប់ដំណើរការសេវាកម្មរបស់តតិយភាគីទាំងមូល និង កម្រិតកិច្ចសន្យាបុគ្គល។ សវនកម្មផ្ទៃក្នុងផ្តល់នូវការវាយតម្លៃលើ ការអនុវត្តរបស់ទីប្រឹក្សា /អ្នកផ្តល់សេវា ដើម្បីជំរុញការធ្វើឱ្យប្រសើរឡើង ជារួមតាមរយៈការវាយតម្លៃ ការអនុវត្តរបស់អ្នកផ្តល់សេវាទាំងអស់ និងការកំណត់អត្តសញ្ញាណ និងការចែករំលែកផ្នែកនៃការអនុវត្តឆ្នើម និងវិធីសាស្ត្រប្រកបដោយភាពច្នៃប្រឌិត។





# នាយកដ្ឋានប្រតិបត្តិតាម

## ៥.១. រចនាសម្ព័ន្ធមុខងារនៃនាយកដ្ឋានប្រតិបត្តិតាម

ក្រុមប្រឹក្សាភិបាល បានតែងតាំង លោកស្រី សាំង ម៉ានីតា ជាប្រធាននាយកដ្ឋានប្រតិបត្តិតាមរបស់ធនាគារ ដែលនឹងមានតួនាទីជាមន្ត្រីប្រតិបត្តិតាមរបស់ធនាគារចំពោះធនាគារជាតិនៃកម្ពុជា (NBC) និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (CAFIU)។ បន្ទាប់ពីរាល់ឯកសារពាក់ព័ន្ធទាំងអស់ត្រូវបានដាក់ជូនធនាគារជាតិនៃកម្ពុជា ប្រធាននាយកដ្ឋានប្រតិបត្តិតាមត្រូវទទួលការវាយតម្លៃតាមរយៈការធ្វើតេស្តិ៍ភាពសក្តិសមនឹងមុនតំណែងនេះ ពីធនាគារជាតិនៃកម្ពុជា។ ជាចុងក្រោយ ធនាគារជាតិនៃកម្ពុជា បានចេញលិខិតអនុញ្ញាតលើការតែងតាំងនេះ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩។ ក្នុងឆ្នាំ២០២០ ធនាគារបានប្តូរនាយកដ្ឋានប្រតិបត្តិតាម ទៅជានាយកដ្ឋានប្រតិបត្តិតាម និងច្បាប់ ហើយបានជ្រើសរើសធនធានមនុស្សបន្ថែម ដើម្បីបំពេញតម្រូវការនៃការពង្រីកអាជីវកម្ម និងដើម្បីឱ្យសមស្របទៅនឹងទ្រង់ទ្រាយធនាគារពាណិជ្ជ។

ប្រធាននាយកដ្ឋានប្រតិបត្តិតាម មានតួនាទីសំខាន់ក្នុងធនាគារ ក្នុងការតាមដាន និងរាយការណ៍លទ្ធផលនៃការប្រតិបត្តិតាម/ការខិតខំប្រឹងប្រែងរបស់ធនាគារ ព្រមទាំងការផ្តល់ការណែនាំដល់ក្រុមប្រឹក្សាភិបាល និងថ្នាក់គ្រប់គ្រងជាន់ខ្ពស់ លើបញ្ហានានាដែលពាក់ព័ន្ធនឹងការប្រតិបត្តិតាម។ ប្រធាននាយកដ្ឋានប្រតិបត្តិតាម ត្រូវរាយការណ៍ផ្ទាល់ជូនគណៈកម្មាធិការសវនកម្ម និងប្រតិបត្តិតាម។ ប្រធាននាយកដ្ឋានប្រតិបត្តិតាម ទទួលបន្ទុកអនុវត្តគោលនយោបាយ និងនីតិវិធីប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម និងមានទំនួលខុសត្រូវដូចខាងក្រោម៖

- ធានាការអនុវត្តយ៉ាងមានប្រសិទ្ធភាពនូវគោលនយោបាយប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម របស់ធនាគារ។
- ធានាថា នីតិវិធីប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម ដែលរួមមានគោលការណ៍ទទួលស្គាល់អតិថិជន ការយកចិត្តទុកដាក់ស្គាល់អតិថិជន ការរក្សាទុកឯកសារ និងកំណត់ត្រា ការតាមដានបន្ត ការរាយការណ៍ប្រតិបត្តិការសង្ស័យ និងការប្រយុទ្ធប្រឆាំងហិរញ្ញប្បទានភេរវកម្ម ត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព។
- ចាត់ចែង រៀបចំរបាយការណ៍ប្រតិបត្តិការសាច់ប្រាក់ និងរបាយការណ៍ប្រតិបត្តិការសង្ស័យ និងដាក់ ជូនអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (CAFIU)។
- ធ្វើការវាយតម្លៃជាប្រចាំលើយន្តការប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម ដើម្បីធានាភាពគ្រប់គ្រាន់ក្នុងការឆ្លើយតបទៅនឹងនិន្នាការបម្រែបម្រួល។
- រក្សាបណ្តាញរាយការណ៍ពីនិយោជិត ទៅមន្ត្រីប្រតិបត្តិតាម ដើម្បីធានាបាននូវព័ត៌មានសម្ងាត់ និងមានសុវត្ថិភាព។
- ធានាការប្រតិបត្តិតាមលក្ខខណ្ឌតម្រូវនៃច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីការប្រឆាំងការសម្អាតប្រាក់ / ហិរញ្ញប្បទានភេរវកម្ម។
- ផ្តល់ការបណ្តុះបណ្តាលដល់និយោជិត ស្តីពីវិធានប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម ដែលរួមមានគោលនយោបាយ យន្តការត្រួតពិនិត្យ និងបណ្តាយរាយការណ៍ ដើម្បីធានាប្រសិទ្ធភាពនៃយន្តការទាំងនោះ។
- កំណត់ហានិភ័យនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលជាប់ពាក់ព័ន្ធជាមួយនឹងផលិតផល ឬសេវាកម្មថ្មី ឬដែលកើតចេញពីការប្រែប្រួលនៃប្រតិបត្តិការរបស់ធនាគារ រួមទាំងការណែនាំអំពីបច្ចេកវិទ្យា និងដំណើរការថ្មីៗ។
- ដើរតួជាអ្នកសម្របសម្រួលរវាងធនាគារ និងប្បញ្ញត្តិករ (ដូចជា ធនាគារជាតិនៃកម្ពុជា អង្គភាពស៊ើប ការណ៍ហិរញ្ញវត្ថុកម្ពុជា ជាដើម)។
- ធ្វើការជាមួយនឹងបុគ្គលិកនៃនាយកដ្ឋានផ្សេងទៀត និងប្បញ្ញត្តិករពាក់ព័ន្ធ ដើម្បីធានាការប្រតិបត្តិតាម ច្បាប់ស្តីពីអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់អាមេរិក (Foreign Account Tax Compliance Act (FATCA))។
- ធ្វើបច្ចុប្បន្នអំពីច្បាប់ នីតិ បទប្បញ្ញត្តិ និងលក្ខខណ្ឌប្រតិបត្តិតាមថ្មីៗ។ ផ្តល់អនុសាសន៍ និងធ្វើបច្ចុប្បន្នភាពលើទម្រង់ឯកសារការងារដែលចាំបាច់ ដើម្បីធានាថា គោលនយោបាយផ្ទៃក្នុងរបស់ធនាគារត្រូវបានធ្វើបច្ចុប្បន្នភាពទាន់ពេលវេលា និងដើម្បីសម្របសម្រួលដល់ការអនុវត្តត្រួតពិនិត្យផ្ទៃក្នុង។

## ៥.២. ធនធានដែលបានផ្តល់

នាយកដ្ឋានប្រតិបត្តិតាម និងច្បាប់ បានបង្កើនធនធានរបស់ខ្លួន ដើម្បីឱ្យសក្តិសមទៅនឹងទំហំប្រតិបត្តិការរបស់ធនាគារ។ បច្ចុប្បន្ន មាននិយោជិត ៤(បួន) រូបក្នុងនាយកដ្ឋានប្រតិបត្តិតាម និងច្បាប់។ មុខងារប្រតិបត្តិតាមខិតខំដើម្បីធានាថា ការអនុវត្តបច្ចុប្បន្នគឺអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ព្រមទាំងស្តង់ដារវិជ្ជាជីវៈ និងសីលធម៌ ហើយនិងបទប្បញ្ញត្តិនានាដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច ពាក់ព័ន្ធនឹងសកម្មភាពធនាគារ និងហិរញ្ញវត្ថុ ហើយស្របតាមគោលនយោបាយ និងនីតិវិធីដែលចេញដោយធនាគារ។

កិច្ចការងារសំខាន់បំផុត គឺធានាថា បុគ្គលិកពាក់ព័ន្ធមានការយល់ដឹងអំពីលក្ខខណ្ឌតម្រូវនៃច្បាប់ប្បញ្ញត្តិនានា ក៏ដូចជាគោលនយោបាយ និងនីតិវិធីផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម ដូចជាការបំពេញការយកចិត្តទុកដាក់ស្គាល់អតិថិជន ការកត់សម្គាល់ប្រតិបត្តិការសង្ស័យ និងការរាយការណ៍ឱ្យបានទាន់ពេលវេលា និងដោយរក្សាការសម្ងាត់។

ក្នុងអំឡុងឆ្នាំ២០២១ ធនាគារបានផ្តល់ការបណ្តុះបណ្តាលផ្ទៃក្នុង ស្តីពី ការប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម ដល់បុគ្គលិកទាំងអស់ ដោយស្របតាមលក្ខខណ្ឌតម្រូវនៃប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ដែលតម្រូវឱ្យ បុគ្គលិកទាំងអស់ចូលរៀនវគ្គរំលឹកឡើងវិញយ៉ាងតិចម្តងក្នុងមួយឆ្នាំ។ ជាងនេះទៅទៀត វគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាខាងក្រៅមួយចំនួន ត្រូវបានធ្វើឡើងដោយអ្នកបណ្តុះបណ្តាលក្នុងស្រុក និងអន្តរជាតិ ពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម ដោយមានការចូលរួមពីបុគ្គលិកយើងក្នុងឆ្នាំនេះផងដែរ។

## ៥.៣. សកម្មភាពនៃមុខងារប្រតិបត្តិតាម

មុខងារប្រតិបត្តិតាម ជាមុខងារឯករាជ្យក្នុងធនាគារ។ មុខងារនេះមានទំនួលខុសត្រូវត្រួតពិនិត្យការប្រតិបត្តិរបស់ធនាគារ ទៅតាមគោលនយោបាយ និងនីតិវិធីផ្ទៃក្នុង ក៏ដូចជាច្បាប់ និងបទប្បញ្ញត្តិនានារបស់អាជ្ញាធរពាក់ព័ន្ធ។ ក្នុងអំឡុងឆ្នាំ២០២១ មុខងារប្រតិបត្តិតាម បានបំពេញការងារជាច្រើន ដើម្បីលើកកម្ពស់ជាអតិបរមានូវការអនុវត្តការប្រតិបត្តិតាមរបស់ធនាគារ។

### ៥.៣.១. ការប្រតិបត្តិតាមក្នុងការប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម (AML/CFT)

- **របាយការណ៍ប្រតិបត្តិការ**

យោងតាមប្រកាសលេខ ធ៧.០៨.០៨៩ ប្រ.ក ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ធនាគារមានកាតព្វកិច្ចដាក់របាយការណ៍ប្រតិបត្តិការជូន អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។ ដូច្នេះ ចាប់ពី ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៨ មកធនាគារបានចាប់ផ្តើមដាក់របាយការណ៍ប្រតិបត្តិការដូចជា របាយការណ៍ប្រតិបត្តិការសាច់ប្រាក់ (CTR) របាយការណ៍ប្រតិបត្តិការសង្ស័យ និងរបាយការណ៍គ្មានប្រតិបត្តិការ (NTR) ក្នុងករណីគ្មាន CTR និង STR ត្រូវរាយការណ៍ ។

នាយកដ្ឋានប្រតិបត្តិតាម ទទួលខុសត្រូវរៀបចំរបាយការណ៍ទាំងនេះឱ្យបានត្រឹមត្រូវ និងដាក់ ជូន CAFIU ឱ្យបានទាន់ពេលវេលា។

- **ការវាយតម្លៃហានិភ័យនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម**

យោងតាមការណែនាំ និងលិខិតរបស់ CAFIU ធនាគារត្រូវរៀបចំរបាយការណ៍វាយតម្លៃហានិភ័យ ជូន CAFIU ឱ្យជាប្រចាំតាមពេលកំណត់។

  - **របាយការណ៍វាយតម្លៃហានិភ័យនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ប្រចាំឆ្នាំ៖**

  របាយការណ៍នេះត្រូវរៀបចំ និងដាក់ជូន CAFIU រៀងរាល់ ២ ឆ្នាំម្តង ត្រឹមខែមិថុនា នៃឆ្នាំបន្ទាប់។ ធនាគារបានដាក់របាយការណ៍សម្រាប់ឆ្នាំ២០១៧-២០១៨ ក្នុងឆ្នាំ២០១៩ ដាក់របាយការណ៍សម្រាប់ឆ្នាំ២០១៩-២០២០ ក្នុងឆ្នាំ២០២១ ដូចនេះ របាយការណ៍សម្រាប់ឆ្នាំ២០២១-២០២២ នឹងត្រូវដាក់ជូន CAFIU ក្នុងឆ្នាំ២០២៣។

  - **របាយការណ៍វាយតម្លៃហានិភ័យនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មប្រចាំត្រីមាស៖**

  ធនាគារពាណិជ្ជទាំងអស់ត្រូវរៀបចំ និងដាក់របាយការណ៍នេះជូន CAFIU រៀងរាល់ ត្រីមាស ត្រឹមថ្ងៃទី១៥ នៃត្រីមាសបន្ទាប់។ ធនាគារបានដាក់របាយការណ៍ចុងក្រោយជូន CAFIU ក្នុងខែមករា ឆ្នាំ២០២២ ។

  - **កម្រងសំណួរសម្រាប់ការគ្រប់គ្រងហានិភ័យនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ប្រចាំត្រីមាស៖**

  កម្រងសំណួរនេះ ត្រូវរៀបចំ និងដាក់ជូន CAFIU ស្របពេលជាមួយគ្នានឹង របាយការណ៍វាយតម្លៃហានិភ័យនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មប្រចាំត្រីមាស។

- **គោលនយោបាយ និងនីតិវិធីនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលបានធ្វើបច្ចុប្បន្នភាព**

ដោយបានព្យាករណ៍ឃើញនូវការកើនឡើងនៃភាពស្មុគស្មាញនៃអាជីវកម្មរបស់ធនាគារ នាយកដ្ឋានប្រតិបត្តិតាម បានបង្កើតនីតិវិធីប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវាកម្មថ្មី ដោយច្របាច់បញ្ចូលគ្នានូវរាល់នីតិវិធីពាក់ព័ន្ធនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដែលមានស្រាប់ និងដោយពិចារណាលើការកែប្រែនៃច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ ព្រមទាំងផលិតផល និងសេវាកម្មថ្មីៗដែលធនាគារនឹងដំណើរការក្នុងឆ្នាំ២០២២នេះ។

ដោយលក្ខខណ្ឌតម្រូវ និយតករទាំងឡាយពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវាកម្ម នាយកដ្ឋានប្រតិបត្តិតាម បានរៀបចំ និងកែប្រែគោលនយោបាយប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវាកម្មដែលមានស្រាប់ និងទទួលបានការអនុម័តដោយក្រុមប្រឹក្សាភិបាលកាលពីដើមខែមករា ឆ្នាំ២០២២។

### ៥.៣.២. ការប្រតិបត្តិតាមផ្សេងទៀត

- **សំណើសុំបើកសាខាថ្មី**

ដោយហេតុថា មុខងារប្រតិបត្តិតាម មានតួនាទីជាបណ្តាញទំនាក់ទំនងរវាងធនាគារ និងនិយតករ ហើយមុខងារនេះមានចំណេះអំពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់ ទើបគណៈគ្រប់គ្រងបានចាត់ឱ្យមុខងារប្រតិបត្តិតាមរៀបចំពាក្យសុំបើកសាខាថ្មីដូចខាងក្រោម៖

  - សាខាអូឡាំព្យារ មានទីតាំងស្ថិតនៅ អគារលេខ S3-17 ផ្លូវ ១៨២ សង្កាត់វាលវង់ ខណ្ឌប្រាំពីរមករា រាជធានីភ្នំពេញ និង
  - សាខាម៉ៅសេទុង មានទីតាំងស្ថិតនៅ អគារ Royal K Plaza មហាវិថីម៉ៅសេទុង សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

ពាក្យសុំត្រូវបានទទួលយកដោយធនាគារជាតិនៃកម្ពុជា ហើយធនាគារជាតិនៃកម្ពុជាបានចេញលិខិតអនុញ្ញាតជាគោលការណ៍នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១។ បច្ចុប្បន្ន នាយកដ្ឋានប្រតិបត្តិតាមកំពុងធ្វើការរៀបចំពាក្យសុំអាជ្ញាប័ណ្ណសម្រាប់សាខាទាំងពីរនេះ។

## ៥.៤. សកម្មភាព និងផលិតផលថ្មីៗ

បន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណធនាគារពាណិជ្ជពីធនាគារជាតិនៃកម្ពុជា ធនាគារបានបង្កើតផលិតផល និងសេវាកម្មជាច្រើន ដើម្បីសម្រេចកម្មវត្ថុអាជីវកម្មរបស់ខ្លួន និងបំពេញតម្រូវការរបស់អតិថិជន។ មុននឹងដាក់ឱ្យដំណើរការនូវផលិតផល ឬសេវាកម្មណាមួយ ធនាគារបានបង្កើតក្រុមការងារដែលមានសមាសភាពអង្គភាពអាជីវកម្មពាក់ព័ន្ធ និងអញ្ជើញមុខងារឯករាជ្យ ដូចជា មុខងារគ្រប់គ្រងហានិភ័យ និងមុខងារប្រតិបត្តិតាម ឱ្យជួយវាយតម្លៃ និងពិនិត្យលើលក្ខខណ្ឌតម្រូវ ដើម្បីឱ្យអនុលោមតាមបទប្បញ្ញត្តិដែលពាក់ព័ន្ធ។

## ៥.៥. ទំនាស់ផលប្រយោជន៍

ធនាគារបានបង្កើតគណៈកម្មាធិការតម្លៃការ និងតែងតាំង (Remuneration and Nomination Committee (RNBC))។ RNBC ត្រូវរាយការណ៍ផ្ទាល់ទៅក្រុមប្រឹក្សាភិបាល និងត្រូវជួយក្រុមប្រឹក្សាភិបាលក្នុងការតាមដានការអនុវត្តគោលនយោបាយ និងការគោលការណ៍ណែនាំសម្រាប់បុគ្គលិកធនាគារ រួមមានការវាយតម្លៃប្រាក់ឈ្នួលសរុបរបស់បុគ្គលិក និងការបង្កើនសមត្ថភាពរបស់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងបុគ្គលិក ព្រមទាំងផ្តល់អនុសាសន៍នៅពេលមានការកែប្រែណាមួយលើគោលនយោបាយទាំងនោះ។

ធនាគារ ត្រូវធានាថា រាល់ទំនាស់រវាងផលប្រយោជន៍ឯកជនរបស់និយោជិត និងផលប្រយោជន៍ពាណិជ្ជកម្មរបស់ធនាគារ ត្រូវបានជៀសវាង។ ក្នុងករណីនិយោជិតណាមួយបានដឹងថាខ្លួនមានទំនាស់ផលប្រយោជន៍ជាមួយនឹងធនាគារ ពួកគេចាំបាច់ត្រូវជូនដំណឹងដល់អ្នកគ្រប់គ្រងផ្ទាល់របស់ពួកគេ ឬអ្នកគ្រប់គ្រងផ្នែកធនធានមនុស្ស ឬនាយកដ្ឋានធនធានមនុស្ស ដើម្បីសុំយោបល់ពីចំណាត់ការបន្ទាប់។

# ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធព័ត៌មាន

## ៦.១. សង្ខេបនៃការត្រួតពិនិត្យ បង្កើតឡើងដើម្បីវាយតម្លៃប្រសិទ្ធិភាពនៃការអនុវត្តតាមច្បាប់

យោងតាមលក្ខខណ្ឌច្បាប់ និងបទប្បញ្ញត្តិ ធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមហ៊ុនធានារ៉ាប់រង មានកាតព្វកិច្ចអនុវត្តតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជា (CIFRS) ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ តទៅ សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

ដោយបានអនុវត្តជាប់លាប់ នៅក្នុងឆ្នាំ ២០២១ របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (CIFRS) និងគោលការណ៍ណែនាំរបស់ ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ។ ជារៀងរាល់ឆ្នាំ របាយការណ៍ហិរញ្ញវត្ថុទាំងនេះត្រូវបានពិនិត្យ និងធ្វើសវនកម្មដោយក្រុមហ៊ុនសវនកម្មឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំ ២០២១ ត្រូវបានពិនិត្យ និងធ្វើសវនកម្មដោយ ក្រុមហ៊ុន អឺនស្ទ៍ អ៊ែន យ៉ាំង (ខេមបូឌា)។

## ៦.២. ការពិពណ៌នាសង្ខេបនៃច្បាប់គណនេយ្យជាក់លាក់

### ៦.២.១. ប្លង់គណនី

ធនាគារប្រើប្រាស់ប្លង់គណនី ដែលណែនាំដោយធនាគារជាតិនៃកម្ពុជា។ ប្លង់គណនីនេះ បែងចែកប្រភេទ និងបទបង្ហាញទាំងអស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ មានលេខ ៩ ខ្ទង់ហើយវាស្របនឹងប្លង់គណនីឯកភាពសម្រាប់ធនាគារពាណិជ្ជកម្ម។

ខ្ទង់ដើមគេ តំណាងឱ្យប្រភេទសំខាន់ៗក្នុងប្លង់គណនី ហើយមានលក្ខណៈដូចខាងក្រោម៖

- លេខ ១ សម្រាប់ទ្រព្យសកម្ម
- លេខ ២ សម្រាប់ទ្រព្យសកម្ម
- លេខ ៣ សម្រាប់បំណុល
- លេខ ៤ សម្រាប់ដើមទុន និងទុនបម្រុង
- លេខ ៥ សម្រាប់ចំណូល
- លេខ ៦ សម្រាប់ចំណាយ
- លេខ ៧ សម្រាប់ប្រភេទដែលមិនបង្ហាញលើតារាងតុល្យការ

### ៦.២.២. រូបិយប័ណ្ណដំណើរការ

រូបិយប័ណ្ណជាតិរបស់កម្ពុជា គឺប្រាក់រៀល (KHR)។ ប៉ុន្តែ ដោយសារធនាគារធ្វើប្រតិបត្តិការ និងធ្វើកំណត់ត្រាគណនេយ្យរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិក (USD) គណៈគ្រប់គ្រង បានកំណត់យក ដុល្លារអាមេរិកជារូបិយប័ណ្ណដំណើរការរបស់ធនាគារ ព្រោះវាឆ្លុះបញ្ចាំងពីខ្លឹមសារសេដ្ឋកិច្ចនៃព្រឹត្តិការណ៍និងកាលៈទេសៈរបស់ធនាគារ។

រាល់ប្រតិបត្តិការរូបិយប័ណ្ណបរទេស ត្រូវប្តូរទៅជាប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់ដែលកំណត់នៅកាលបរិច្ឆេទដែលធ្វើប្រតិបត្តិការនោះ។ ទ្រព្យសកម្ម និងបំណុលដែលគិតជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិកនៅកាលបរិច្ឆេទនៃរបាយការណ៍ ត្រូវបានប្តូរទៅជាដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់ដែលបានកំណត់នៅកាលបរិច្ឆេទនោះ។ ភាពល្អៀងនៃអត្រាប្តូរប្រាក់ដែលកើតឡើងដោយការប្តូររូបិយប័ណ្ណ នឹងមានកត់ត្រាក្នុងរបាយការណ៍ចំណូលចម្រុះ។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាដុល្លារអាមេរិក ដែលជារូបិយប័ណ្ណដំណើរការរបស់ធនាគារ។ ទឹកប្រាក់ទាំងអស់ ត្រូវបានបង្គត់ជាដុល្លារអាមេរិក លើកលែងតែមានការបញ្ជាក់ផ្សេង។ ភាពល្អៀងនៃអត្រាប្តូរប្រាក់ មានកត់ត្រានៅក្នុងរបាយការណ៍ចំណូល-ចំណាយ។



### ៦.២.៣. ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

នៅពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតដែលប៉ះពាល់ដល់ការអនុវត្តគោលនយោបាយគណនេយ្យ និងចំនួនទឹកប្រាក់នៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសគ្នាពីការប៉ាន់ស្មានទាំងនេះ។

ការប៉ាន់ស្មាន និងការសន្មតមូលដ្ឋាន ត្រូវបានពិនិត្យឡើងវិញជាប្រចាំ។ ការកែប្រែលើការប៉ាន់ស្មានគណនេយ្យនឹងត្រូវបានបង្ហាញនៅក្នុងឆ្នាំដែលការប៉ាន់ស្មាននោះត្រូវបានកែប្រែ និងក្នុងរយៈពេលណាមួយដែលរងផលប៉ះពាល់។

ការប៉ាន់ស្មាន និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ ដែលត្រូវបានអនុវត្តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដូចជាការប៉ាន់ស្មានចំនួនទឹកប្រាក់ដែលអាចប្រមូលបានសម្រាប់ប្រាក់កម្ចី ត្រូវបានកំណត់ដោយប្រើគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

## ៦.៣. ការត្រួតពិនិត្យដោយសវនកម្មផ្ទៃក្នុង

ទំនួលខុសត្រូវសំខាន់ៗរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង គឺត្រូវរាយការណ៍ទៅគណៈកម្មាធិការសវនកម្ម និងប្រតិបត្តិតាម នូវលទ្ធផលនៃការវាយតម្លៃលើការត្រួតពិនិត្យផ្ទៃក្នុង កំណត់ត្រាហិរញ្ញវត្ថុ និងគណនេយ្យ ការគ្រប់គ្រងការប្រតិបត្តិតាម និងប្រព័ន្ធដំណើរការទិន្នន័យ។

ចំពោះរបាយការណ៍ហិរញ្ញវត្ថុ និងគណនេយ្យ នាយកដ្ឋានសវនកម្មផ្ទៃក្នុងធ្វើការពិនិត្យលើផ្នែកសំខាន់ៗ ដែលរួមមាន៖

- ការបញ្ចូលគណនេយ្យ និងប្រតិបត្តិការចំណាយ
- ប្រព័ន្ធស្នូលធនាគារ
- ការផ្ទៀងផ្ទាត់គណនីតារាងតុល្យការ
- ការផ្ទៀតផ្ទាត់ចំនួនសាច់ប្រាក់របស់ធនាគារ
- ការគណនាឡើងវិញលើតារាងតុល្យការ និងគណនីចំណូល-ចំណាយ
- ធាតុក្នុងតារាងតុល្យការ និងគណនីចំណូល-ចំណាយ
- ចំណាត់ថ្នាក់នៃប្រាក់កម្ចី និងបុរេប្រទាន
- របាយការណ៍តាមកាលកំណត់ដែលបានដាក់ជូនធនាគារជាតិនៃកម្ពុជា។

លើសពីនេះ នាយកដ្ឋានសវនកម្មផ្ទៃក្នុង ធ្វើការត្រួតពិនិត្យលើការគ្រប់គ្រងទ្រព្យអសកម្ម ការគ្រប់គ្រងសាច់ប្រាក់ ការគ្រប់គ្រងការប្រតិបត្តិ និងប្រព័ន្ធដំណើរការទិន្នន័យ។

# គោលនិយោបាយ និតិវិធី និង ដំណើរការនៃការគ្រប់គ្រងហានិភ័យ

## ៧.១. គណៈកម្មាធិការហានិភ័យ

ធនាគារបានបង្កើតគណៈកម្មាធិការគ្រប់គ្រងហានិភ័យ (Risk Management Committee (RMC)) កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ ហើយបានប្តូរទៅជា គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម បំណុល និងហានិភ័យ (Asset & Liability and Risk Board Committee (ARBC)) កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៩ ដើម្បីធានាថា កម្មវត្ថុរួមក្នុងការរក្សាភាពត្រឹមត្រូវនៃហិរញ្ញវត្ថុ និងប្រតិបត្តិការ និងដើម្បីជៀសវាងសកម្មភាពណាមួយដែលអាចនឹងគំរាមកំហែងដល់កេរ្តិ៍ឈ្មោះរបស់ធនាគារ។

### ៧.១.១. គោលបំណង

គោលបំណងរបស់ ARBC គឺដើម្បី៖

- ជួយដល់ក្រុមប្រឹក្សាភិបាល ក្នុងការត្រួតពិនិត្យលើក្របខណ្ឌគ្រប់គ្រងហានិភ័យរបស់ធនាគារ និងតាមដានការគ្រប់គ្រង

ហានិភ័យប្រតិបត្តិការក្នុងធនាគារទាំងមូល។

- តាមដានការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល ឬកិច្ចការផ្សេងពីនេះដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។ គណៈគ្រប់គ្រងអាចសួរយោបល់ពី ARBC ឬសមាជិករបស់ ARBC ក្នុងការរៀបចំកិច្ចការណាមួយដាក់ជូនក្រុមប្រឹក្សាភិបាល។
- រក្សាភាពត្រឹមត្រូវផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការ ព្រមទាំងលើកកម្ពស់កេរ្តិ៍ឈ្មោះរបស់ធនាគារ។

## ៧.១.២. សមាជិកភាព

ក្រុមប្រឹក្សាភិបាលបង្កើត ARBC ដោយតែងតាំងអភិបាលឯករាជ្យមួយរូបឱ្យធ្វើជាប្រធាន។ សមាជិកថ្នាក់គ្រប់គ្រងជាន់ខ្ពស់មួយរូប ធ្វើជាលេខាធិការរបស់ ARBC។ ប៉ុន្តែ លេខាធិការពុំមានសិទ្ធិបោះឆ្នោតឡើយ។ គណៈកម្មាធិការនេះមានសមាជិកដូចខាងក្រោម៖

| លោក **ឡូញ ហៃ** | លោក **វង្ស ពេជ្រ** | លោក **ឡាវ អៀវចុង** |
| --- | --- | --- |
| អភិបាលឯករាជ្យ<br>ជាប្រធាន | ប្រធានក្រុមប្រឹក្សាភិបាល<br>ជាសមាជិក | អនុប្រធានក្រុមប្រឹក្សាភិបាល<br>ជាសមាជិក |

## ៧.១.៣. សិទ្ធិអំណាច

- ARBC ទទួលសិទ្ធិអំណាចពីក្រុមប្រឹក្សាភិបាលក្នុងការ៖
- ធ្វើការស៊ើបអង្កេតលើបញ្ហាណាមួយក្នុងធនាគារ ដូចមានចែងក្នុងលក្ខន្តិកៈរបស់គណៈកម្មាធិការនេះ។
- សាកសួរព័ត៌មានដែលខ្លួនត្រូវការ ពីនិយោជិតរបស់ធនាគារ។
- ទទួលបានយោបល់ផ្នែកច្បាប់ និង/ឬ វិជ្ជាជីវៈផ្សេងៗពីខាងក្រៅ និងតែងតាំងអ្នកពិគ្រោះយោបល់ណាមួយ តាមអនុសាសន៍ ឬការផ្តល់យោបល់របស់នាយកប្រតិបត្តិ លើកិច្ចការណាមួយដែលមានចែងក្នុងលក្ខន្តិកៈរបស់គណៈកម្មាធិការនេះ។

## ៧.១.៤. ទំនួលខុសត្រូវ

យោងតាមគោលបំណង និងសិទ្ធិអំណាចរបស់ ARBC ដែលបានចែងខាងលើ ភារកិច្ចរបស់ ARBC រួមមានជាអាទិ៍៖

### មុខងារគ្រប់គ្រងទ្រព្យសកម្ម និងបំណុល៖

- ពិនិត្យគោលនយោបាយទ្រព្យសកម្ម/បំណុល របស់ធនាគារ និងធានាថា មូលនិធិរបស់ធនាគារ ត្រូវបានគ្រប់គ្រងដោយស្របតាមគោលនយោបាយរបស់ធនាគារ។
- ពិនិត្យគោលការណ៍ណែនាំ ស្តីពីកម្រិត/អនុបាតនៃការទទួលយកហានិភ័យហិរញ្ញវត្ថុរបស់ធនាគារ (ដូចជា LCR អសាធនភាព LDR....) និងមុខងាររតនាគារ ព្រមទាំងតាមដានស្ថានភាពនៃអនុបាតទាំងនេះដោយធៀបទៅនឹងកម្រិតកំណត់។
- ពិនិត្យនិន្នាការទីផ្សារ ពាក់ព័ន្ធនឹងការបង្កើតផលិតផល និងអត្រានៅលើទីផ្សារ (ដូចជា អត្រាការប្រាក់កម្ចី និងបញ្ញើ ថ្លៃសេវាធ្វើប្រតិបត្តិការ និងសោហ៊ុយផ្សេងៗ) ដែលមានផលប៉ះពាល់លើការប្រកបអាជីវកម្មរបស់ធនាគារ។
- ពិនិត្យផែនការថវិការបស់ធនាគារ និងការបំពេញការងារ/សមិទ្ធផល ធៀបនឹងផែនការថវិកា។
- ពិនិត្យ និងតាមដាន ផលប៉ះពាល់លើតារាងតុល្យការ គណនីចំណូល-ចំណាយ និងលើសន្ទនីយភាព ដែលជាលទ្ធផលនៃការផ្លាស់ប្តូរយុទ្ធសាស្ត្រវិនិយោគ និងឥរិយាបថរបស់អតិថិជន ក៏ដូចជា ការឡើងចុះនៃតម្លៃ និងទំហំផលិតផលរបស់ធនាគារ រួមទាំងផលិតផលឥណពន្ធ និងឥណទាន។
- ពិនិត្យ និងតាមដាន ស្ថានភាពអនុវត្តរបស់ធនាគារ ដើម្បីធានាការប្រតិបត្តិយ៉ាងពេញលេញ តាមលក្ខខណ្ឌតម្រូវនិយតករ និងលក្ខខណ្ឌរបស់បុគ្គលពាក់ព័ន្ធផ្សេងទៀត។

### មុខងារគ្រប់គ្រងហានិភ័យ៖

- កំណត់ ពិនិត្យ និងវាយតម្លៃហានិភ័យរបស់ធនាគារ ព្រមទាំងប៉ាន់ស្មានផលប៉ះពាល់នៃហានិភ័យនោះមកលើធនាគារ។ ហានិភ័យដែលមានភាគរយអាចកើតមានខ្ពស់ និងអាចមានផលប៉ះពាល់ខ្លាំងដល់ធនាគារ ត្រូវមានការយកចិត្តទុកដាក់បន្ថែម។
- ពិនិត្យរបាយការណ៍នៃមុខងារគ្រប់គ្រងហានិភ័យរបស់ធនាគារ និងការអនុវត្តដោយគណៈគ្រប់គ្រង របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុង និងអនុសាសន៍នានា ដើម្បីធានាភាពប្រសិទ្ធភាពគ្រប់គ្រាន់ជារួម។
- ធានាថា ហានិភ័យដែលពាក់ព័ន្ធ ត្រូវបានវាស់វែង និងតាមដានសម្រាប់សកម្មភាពអាជីវកម្មគ្រប់បែបផែន។
- ធានាថា នៅពេលដែលមានការមិនបំពេញតាមកម្រិតដែលបានកំណត់ ត្រូវមានសកម្មភាពកែតម្រូវជាបន្ទាន់។
- ពិនិត្យលើ ទស្សនៈ យុទ្ធសាស្ត្រ និងគោលនយោបាយហានិភ័យ ដែលបានបង្កើតឡើង និងផ្តល់អនុសាសន៍ដោយគណៈគ្រប់គ្រង ព្រមទាំងធានាថា ទស្សនៈ យុទ្ធសាស្ត្រ និងគោលនយោបាយទាំងនោះអនុលោមតាមគោលនយោបាយ និងស្ថានភាពហានិភ័យជារួមរបស់ធនាគារ។ ហានិភ័យ ក្នុងន័យទូលំទូលាយបំផុត គឺរាប់បញ្ចូលទាំង ហានិភ័យទីផ្សារ ហានិភ័យឥណទាន ហានិភ័យសន្ទនីយភាព ហានិភ័យប្រតិបត្តិការ និងហានិភ័យប្រតិបត្តិតាម ដែលទាំងនេះបញ្ចូលគ្នា មានវិសាលភាពគ្របដណ្តប់លើហានិភ័យខាងក្រោម៖
    - ហានិភ័យអត្រាការប្រាក់
    - ហានិភ័យរូបិយប័ណ្ណ និងអត្រាប្តូរប្រាក់
    - ហានិភ័យបច្ចេកវិទ្យា
    - ហានិភ័យក្នុងការស្តារឡើងវិញពីគ្រោះមហន្តរាយ
    - ហានិភ័យប្រតិបត្តិការ
    - ហានិភ័យកេរ្តិ៍ឈ្មោះ
    - ហានិភ័យនៃភាពប្រកួតប្រជែង
    - ហានិភ័យផ្នែកច្បាប់
    - ហានិភ័យក្នុងការប្រតិបត្តិតាម និងការត្រួតពិនិត្យ
    - ហានិភ័យសុវត្ថិភាព សុខភាព បរិស្ថាន
    - ហានិភ័យវិនិយោគ
    - ហានិភ័យក្នុងការវាយតម្លៃទ្រព្យសកម្ម
    - ហានិភ័យផ្សេងៗទៀតដែលអាចកើតមានលើអាជីវកម្ម និងដែលអាចរកឃើញម្តងម្កាល។
- ពិនិត្យវិធីសាស្ត្រកំណត់ និងវាស់វែងហានិភ័យ។
- គោរពដោយយកចិត្តទុកដាក់លើគោលការណ៍អភិបាលកិច្ច និងក្រមប្រតិបត្តិដែលល្អបំផុត។
- រៀបរាប់លម្អិតនៅចំណុចដែលគប្បីចុះផ្សាយក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារ ពាក់ព័ន្ធសកម្មភាពរបស់ ARBC។

## ៧.១.៥. ការប្រជុំ

ក្នុងឆ្នាំ ២០២១ ARBC បានបើកិច្ចប្រជុំចំនួន ៣(បី) លើក ដើម្បីអនុម័តលើ អត្រាការប្រាក់ថ្មី ថ្លៃផលិតផល និងសេវាកម្ម ប្រធានបទស្តីពីទ្រព្យសកម្ម និងបំណុល និងកិច្ចការពាក់ព័ន្ធនឹងហានិភ័យ។ ប្រធាន ARBC បានកោះប្រជុំ ARBC ដើម្បីពិភាក្សា និងពិនិត្យលើកិច្ចការមួយចំនួនដែលពាក់ព័ន្ធនឹងបញ្ហាហានិភ័យ ដូចជាហានិភ័យឥណទាន ហានិភ័យសន្ទនីយភាព ហានិភ័យទីផ្សារ ហានិភ័យប្រតិបត្តិការ និងហានិភ័យក្នុងការប្រតិបត្តិតាម ព្រមទាំងកិច្ចការស្តីពីទ្រព្យសកម្ម និងបំណុល ដូចជាស្ថានភាពហិរញ្ញវត្ថុប្រចាំឆ្នាំ និងលក្ខណៈនៃផលិតផល និងការកំណត់តម្លៃ។ គណៈកម្មាធិការនេះ បានកត់ត្រាទុកនូវរបាយការណ៍ និងបានផ្តល់អនុសាសន៍ឱ្យគណៈគ្រប់គ្រងតាមដានឱ្យបានជាប់លាប់លើកិច្ចការនីមួយៗ និងជូនដំណឹងអំពីកិច្ចការសំខាន់ៗដល់ ARBC ក្នុងការប្រជុំលើកក្រោយ។

## ៧.១.៦. ការធ្វើរបាយការណ៍

ប្រធាន ARBC ត្រូវធ្វើបច្ចុប្បន្នភាព ផ្តល់យោបល់ និងអនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល លើរាល់សកម្មភាព និងកិច្ចការដែលស្ថិតក្រោមទំនួលខុសត្រូវត្រួតពិនិត្យរបស់ខ្លួន។ យោបល់ទាំងនោះអាចក្នុងទម្រង់ជាកំណត់ហេតុកិច្ចប្រជុំជាលាយលក្ខណ៍អក្សរ ឬជាការរាយការណ៍ដោយផ្ទាល់មាត់នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

## ៧.២. បញ្ជីនៃគោលនយោបាយ និងនីតិវិធីគ្រប់គ្រងហានិភ័យ

ធនាគារ បានបង្កើតគោលនយោបាយគ្រប់គ្រងហានិភ័យ ដែលផ្តល់ជា ក្របខណ្ឌទូទៅ នៃស្តង់ដារ ត្រួតពិនិត្យ សម្រាប់ជាមូលដ្ឋានដែលត្រូវ

ផ្អែកលើក្នុងការធ្វើសកម្មភាពប្រចាំថ្ងៃ ដើម្បីសម្រេចនូវគោលបំណងរបស់ធនាគារយើងខ្ញុំ ក្នុងការកំណត់ វាយតម្លៃ តាមដាន ត្រួតពិនិត្យ និង កាត់បន្ថយហានិភ័យ និងការខាតបង់ផ្នែកប្រតិបត្តិការ។ វិធីសាស្ត្រគ្រប់គ្រងហានិភ័យត្រូវបានបង្កើតឡើងដោយអនុលោមតាមច្បាប់ និង បទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។

គោលនយោបាយគ្រប់គ្រងហានិភ័យរបស់ធនាគារ ដោះស្រាយនូវហានិភ័យដូចខាងក្រោម៖

### ៧.២.១. ហានិភ័យទីផ្សារ

ហានិភ័យនៃការខាតបង់ផ្នែកហិរញ្ញវត្ថុ ដោយសារការប្រែប្រួលនៃទ្រព្យសកម្ម ជាប្រាក់ ដើមទុន និងទីផ្សារហិរញ្ញវត្ថុ។ ហានិភ័យទីផ្សារ រួមមាន ហានិភ័យអត្រាការប្រាក់ ហានិភ័យអត្រាប្តូរប្រាក់ ហានិភ័យភាគទុន (equity risk) និងហានិភ័យផលិតផលទំនិញ។

### ៧.២.២. ហានិភ័យសន្ទនីយភាព

ក្នុងស្ថានភាពទីផ្សារណាមួយ ហានិភ័យសន្ទនីយភាព ជាហានិភ័យដែលអាចធ្វើឱ្យធនាគារមិនអាចបំពេញកាតព្វកិច្ចរបស់ខ្លួនបាន ឬមិនអាចឆ្លងផុតដំណាក់កាលដែលមិនបំពេញកាតព្វកិច្ចនោះឬអាចប្រឈមនឹងស្ថានភាពមួយដែលអាចនាំឱ្យធនាគារត្រូវអ្នកចូលរួមក្នុងទីផ្សារផ្សេងទៀតចាត់ទុកថាបំពានកាតព្វកិច្ចរបស់ខ្លួន។

### ៧.២.៣. ហានិភ័យឥណទាន

ហានិភ័យឥណទាន ជាហានិភ័យនៃការខាតបង់ ដែលបណ្តាលមកពីអ្នកខ្ចី ឬភាគីដៃគូ មិនបានបំពេញកាតព្វកិច្ចបំណុល ឬកាតព្វកិច្ចនៃកិច្ចសន្យារបស់ខ្លួន។

### ៧.២.៤. ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការ ជាហានិភ័យដែលកើតឡើងដោយសារភាពមិនគ្រប់គ្រាន់ ឬ ភាពបរាជ័យ នៃនីតិវិធីផ្ទៃក្នុង បុគ្គលិក ប្រព័ន្ធផ្ទៃក្នុង ឬព្រឹត្តិការណ៍ពីខាងក្រៅ។

### ៧.២.៥. ហានិភ័យនៃការមិនប្រតិបត្តិតាម

ហានិភ័យនៃការមិនប្រតិបត្តិតាម ជាហានិភ័យផ្លូវតតិយុត្ត រដ្ឋបាល ឬទណ្ឌកម្មវិន័យ ដែលនាំឱ្យខាតបង់ខ្លាំងផ្នែកហិរញ្ញវត្ថុ ឬខូចខាតកេរ្តិ៍ឈ្មោះ ដោយសារការមិនអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានបទដ្ឋានវិជ្ជាជីវៈ និងសីលធម៌ ព្រមទាំងបទប្បញ្ញត្តិជាក់លាក់ណាមួយដែលចេញដោយអាជ្ញាធរទីផ្សារ ពាក់ព័ន្ធនឹងសកម្មភាពធនាគារ និងហិរញ្ញវត្ថុ ព្រមទាំងមិនអនុលោមតាមគោលនយោបាយ និងការណែនាំរបស់អង្គភាពធ្វើសេចក្តីសម្រេច។

ដោយសារធនាគារធ្វើប្រតិបត្តិការតូចៗ និងមិនស្មុគស្មាញ បញ្ហាហានិភ័យទាំងអស់ត្រូវបានយកមកពិភាក្សាផ្ទាល់រវាងសមាជិកប្រតិបត្តិទាំងអស់ ក្រោមការតាមដានរបស់ ARBC។





# ៨ ប្រព័ន្ធឯកសារ

## ៨.១. ការពិពណ៌នាសង្ខេបនៃវិធានផ្ទៃក្នុង

ដើម្បីគ្រប់គ្រងប្រព័ន្ធឯកសារផ្ទៃក្នុងរបស់ធនាគារ នីតិវិធីដំណើរការឯកសារ ត្រូវបានបង្កើតឡើងក្រោមគោលនយោបាយរដ្ឋបាល និងលទ្ធកម្ម។ គោលនយោបាយនេះ មានរៀបរាប់ច្បាស់លាស់នូវឋានានុក្រមក្នុងការអនុម័តឯកសារ កម្រិតសុវត្ថិភាព បញ្ជីរក្សាទុក និងវិធីសាស្ត្រកំទេចចោល។

គោលនយោបាយទាំងអស់របស់ធនាគារ ត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល មុននឹងចេញជាផ្លូវការ និងដាក់ឱ្យអនុវត្តក្នុងធនាគារ។ ក្នុងករណីមានការប្រែប្រួលអាជីវកម្ម ឬមានបច្ចុប្បន្នភាពបទប្បញ្ញត្តិ ដែលតម្រូវឱ្យមានការធ្វើវិសោធនកម្ម ឬនិរាករណ៍នូវគោលនយោបាយណាមួយ ត្រូវស្នើសុំការអនុម័តពីក្រុមប្រឹក្សាភិបាល។

ដើម្បីធ្វើប្រតិបត្តិការប្រចាំថ្ងៃប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធភាព នាយកដ្ឋានពាក់ព័ន្ធទាំងឡាយ ត្រូវរៀបចំនីតិវិធី វិធានប្រតិបត្តិ ក្របខណ្ឌ និងគោលការណ៍ណែនាំនានា ដើម្បីគ្រប់គ្រងលំហូរការងាររបស់ពួកគេឱ្យកាន់តែប្រសើរឡើង និងដើម្បីបំពេញតម្រូវការរបស់អតិថិជន។ នីតិវិធី វិធានប្រតិត្តិ និងក្របខណ្ឌទាំងអស់ ត្រូវអនុម័តដោយគណៈកម្មាធិការពាក់ព័ន្ធ ចំណែកគោលការណ៍ណែនាំ ត្រូវអនុម័តដោយគណៈកម្មការប្រតិបត្តិ មុននឹងដាក់ចេញឱ្យអនុវត្ត។

ឯកសារប្រភេទទាំងនេះ ត្រូវពិនិត្យ និងធ្វើបច្ចុប្បន្នភាពឱ្យបានទាន់ពេលវេលា ដោយផ្អែកលើការចែងនៅក្នុងឯកសារនីមួយៗ។

## ៨.២. ការពិពណ៌នាដោយសង្ខេបពីសកម្មភាពបណ្តុះបណ្តាល

ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវនិយតករ ឬតម្រូវការអាជីវកម្ម បុគ្គលិកទាំងឡាយ ត្រូវទទួលការបណ្តុះបណ្តាលសំខាន់ៗដើម្បីធ្វើឱ្យពួកគេក្លាយជាធនធានមានប្រយោជន៍ចំពោះធនាគារ។ បន្ទាប់ពីគោលនយោបាយនីតិវិធី និងគោលការណ៍ណែនាំទាំងឡាយត្រូវបានអនុម័ត វគ្គបណ្តុះបណ្តាលនឹងត្រូវបានរៀបចំឡើងសម្រាប់បុគ្គលិកពាក់ព័ន្ធ។ លើសពីនេះទៅទៀត មានការបណ្តុះបណ្តាលមួយចំនួនដែលជាកាតព្វកិច្ចតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិនានា ត្រូវផ្តល់ជូនបុគ្គលិកជាប្រចាំតាមពេលកំណត់។ ដូច្នេះ ធនាគារ បានរៀបចំវគ្គបណ្តុះបណ្តាល និងកាលវិភាគសម្រាប់បុគ្គលិក ដូចខាងក្រោម៖

- បុគ្គលិកថ្មី ត្រូវចូលរួមវគ្គណែនាំ ដែលរួមមាន ការយល់ដឹងត្រួសៗ អំពីប្រវត្តិរបស់ធនាគារ គោលនយោបាយធនធានមនុស្ស ការណែនាំអំពីសុវត្ថិភាពព័ត៌មានវិទ្យា និងសេចក្តីណែនាំ អំពី ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។
- បន្ទាប់ពីគោលនយោបាយ នីតិវិធី ឬគោលការណ៍ណែនាំទាំងឡាយ ត្រូវបានអនុម័ត នាយកដ្ឋានទទួលខុសត្រូវ នឹងរៀបចំវគ្គបណ្តុះបណ្តាល ឬចែករំលែក សម្រាប់និយោជិតទាំងអស់ ដើម្បីឱ្យពួកគេបានយល់ដឹងអំពីបច្ចុប្បន្នភាពនៃអាជីវកម្ម នឹងពង្រឹងសមត្ថភាពក្នុងការបំពេញមុខងាររបស់ពួកគេដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុង។
- នាយកដ្ឋានទទួលខុសត្រូវ នឹងផ្តល់វគ្គរំលឹកឡើងវិញ លើប្រធានបទពិសេសៗ ដូចជាការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងផែនការនិរន្តរភាពអាជីវកម្ម (BCP) មួយឆ្នាំម្តងជារៀងរាល់ឆ្នាំ ឬក្នុងករណីមានការកែប្រែ ឬធ្វើបច្ចុប្បន្នភាពនៃគោលនយោបាយប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬផែនការ BCP។ ផែនការបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងដើម្បីធានាការអនុលោមជាអតិបរមាតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។

# ផែនការយថាភាពនិង ការសាកល្បង

## ៩.១. បញ្ជីឈ្មោះការរកឃើញសំខាន់ៗនៃការវាយតម្លៃហានិភ័យ

ធនាគារបានបង្កើតគោលនយោបាយ និងនីតិវិធីដើម្បីសម្រេចបាននូវការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព។ ការរកឃើញសំខាន់ៗដែលធនាគារប្រឈមមុខក្នុងអាជីវកម្ម អាចរួមមាន ប្រព័ន្ធធនាគារស្នូលមិនដំណើរការ ដាច់ចរន្តអគ្គិសនី គ្រោះមហន្តរាយធម្មជាតិ បញ្ហាសុវត្ថិភាព និងបញ្ហាសុខាភិបាល ដែលអាចបង្កភាពបរាជ័យ ឬការរំខាន ដល់អាជីវកម្ម។ តាមរយៈការរកឱ្យឃើញនូវហានិភ័យចម្បងៗទាំងនេះនៅក្នុងអាជីវកម្មធនាគារបានបង្កើតផែនការយុទ្ធសាស្ត្រត្រឹមត្រូវ ក៏ដូចជាសកម្មភាពបង្ការ និងឆ្លើយតប ដើម្បីកាត់បន្ថយហានិភ័យនៅក្នុងប្រតិបត្តិការធនាគារ។

មិនមានបញ្ហាទាក់ទងទៅនឹងផែនការយថាភាពសម្រាប់ឆ្នាំ ២០២១ ទេ។ ធនាគារបានធ្វើការសាកល្បងម្តងក្នុងមួយឆ្នាំជារៀងរាល់ឆ្នាំ ហើយមិនបានរកឃើញនូវបញ្ហាដែលគួរឱ្យព្រួយបារម្ភនោះទេ ពាក់ព័ន្ធនឹងការខកខានមិនបានបង់ ឬអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

## ៩.២. បញ្ជីនៃគោលនយោបាយ

ដើម្បីការរីកចម្រើន និងនិរន្តរភាពរបស់ធនាគារ គោលនយោបាយគន្លឹះ នីតិវិធី គោលការណ៍ណែនាំនិងផែនការសំខាន់ៗមួយចំនួន ត្រូវបានរៀបចំ និងបង្កើតឡើងដើម្បីទប់ទល់នឹងហានិភ័យដែលបានលើកឡើង និងដើម្បីធានានិរន្តរភាពអាជីវកម្មរបស់ធនាគារ។ នៅ APD គោលនយោបាយពាក់ព័ន្ធមានដូចខាងក្រោម៖

- គោលនយោបាយគ្រប់គ្រងនិរន្តភាពអាជីវកម្ម កំណែ ០៣
- នីតិវិធីស្តីពីការត្រួតពិនិត្យផ្ទៃក្នុង កំណែ ០៣
- សកម្មភាពត្រៀមសម្រាប់ការឆ្លើយតបទៅនឹងវីរុស កូរ៉ូណា កំណែ ០១
- គោលនយោបាយគ្រប់គ្រងហានិភ័យសន្ទនីយភាព កំណែ ០២
- សេចក្តីណែនាំ ស្តីពីការគ្រប់គ្រងសុវត្ថិភាពសាច់ប្រាក់ កំណែ ០៣
- ផែនការ និងនីតិវិធីស្តារឡើងវិញពីគ្រោះមហន្តរាយព័ត៌មានវិទ្យា
- នីតិវិធីបម្រុង និងស្តារទិន្នន័យ

ធនាគារក៏កំពុងស្ថិតក្នុងដំណើរការបង្កើតគោលនយោបាយនិង នីតិវិធីផ្សេងទៀតដើម្បីតម្រង់ការត្រួតពិនិត្យផ្ទៃក្នុង និងឧបករណ៍ដើម្បីគ្រប់គ្រងព្រឹត្តិការណ៍ដែលមិនបានរំពឹងទុក។

## ៩.៣. ផែនការនិរន្តភាពអាជីវកម្ម

ធនាគារបានបង្កើតផែនការនិរន្តរភាពអាជីវកម្ម (BCP) ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩។ BCP មានគោលបំណងធានាការបន្តអាជីវកម្មរបស់ធនាគារក្នុងអំឡុង និងក្រោយស្ថានភាពសន្ទនីយភាពដែលគ្រោះថ្នាក់ ការរំខានគួរឱ្យកត់សម្គាល់ ភាពបរាជ័យនៃ ឬគ្រោះមហន្តរាយ ដែលអាចប៉ះពាល់ដល់ប្រតិបត្តិការធម្មតារបស់ធនាគារ។ BCP មានផែនការសំខាន់ៗចំនួន ៣ ដែលរួមមាន ផែនការយថាភាពសន្ទនីយភាព ផែនការយថាភាពថវិកា និងផែនការដោះស្រាយវិបត្តិ និងយថាភាពព័ត៌មានវិទ្យា។

### ក្នុងឆ្នាំ២០២១ មានសេណារីយ៉ូចំនួន ៦ ដូចខាងក្រោម ត្រូវបានដាក់សាកល្បងសម្រាប់ដំណើរការ៖

- ធ្វើតេស្តសាលល្បង់ស្តារឡើងវិញនូវទិន្នន័យបំរុង
- ផែនការជន្លៀសពីអគ្គិភ័យ
- ភាពចលចល / ភាពរឹករវផ្ទែកស៊ីវិល
- ការមិនអាចចូលទៅទីស្នាក់ការកណ្តាលបាន
- អំពើប្លន់
- ការផ្ទុះឡើងនៃជំងឺកូវីដ-១៩។

ឆ្នាំ២០២១ គឺជាឆ្នាំដ៏លំបាកសម្រាប់គ្រប់វិស័យទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា មិនមែនតែវិស័យធនាគារនោះទេ ដោយសារតែការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ វិស័យធនាគារដើរតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់ដល់សេដ្ឋកិច្ចកម្ពុជា និងក្នុងការគាំទ្រដល់យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។ ដូចនេះ ធនាគារ អេភីឌី បានចាត់វិធានការសកម្ម និងប្រុងប្រយ័ត្នក្នុងការកាត់បន្ថយ និងគ្រប់គ្រងការឆ្លងរាលដាល ព្រមទាំងហានិភ័យនៃការឆ្លង និងធានាការបន្តផ្តល់នូវសេវាចាំបាច់ និងសុវត្ថិភាពរបស់អតិថិជន និងបុគ្គលិក ធនាគារបានដំណើរការយុទ្ធសាស្ត្រទប់ទល់ជំងឺឆ្លងក្រោមផែនការ BCP សម្រាប់គ្រប់មុខងារអាជីវកម្មក្នុងធនាគារ ដោយរួមមាន ទីតាំងធ្វើការផ្សេង ការរៀបចំបែងចែកការធ្វើការពីផ្ទះ និងក្នុងការិយាល័យ ការប្រើប្រាស់វេទិកាឌីជីថលសម្រាប់រាល់ការប្រជុំ និងបានផ្តល់ដំបូន្មាន និងបច្ចុប្បន្នភាពនៃនីតិវិធីប្រតិបត្តិការស្តង់ដារក្នុងការទប់ស្កាត់ជំងឺកូវីដ-១៩ ដល់បុគ្គលិកធនាគារ អេភីឌី ទាំងអស់។

APD BANK
ASIA-PACIFIC DEVELOPMENT BANK

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល និង
របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម
ស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់

# របាយការណ៍ហិរញ្ញវត្ថុ
# ដែលបានធ្វើសវនកម្ម

# របាយការណ៍ របស់ក្រុម ប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ធ្វើការបង្ហាញជូននូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក ហៅកាត់ថា (“ធនាគារ”) នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទបញ្ចប់។

## ធនាគារ

ធនាគារ ត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងទម្រង់ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ក្រោមអាជ្ញាប័ណ្ណពាណិជ្ជកម្មលេខ ០០០០៧៥១៤ នាថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦។

ធនាគារ ទទួលបានអាជ្ញាប័ណ្ណ ធនាគារឯកទេស ពីធនាគារជាតិនៃកម្ពុជា (“NBC”) នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ដើម្បីធ្វើប្រតិបត្តិការជាធនាគារឯកទេស ដោយមានសុពលភាពអចិន្ត្រៃយ៍ និងចាប់ផ្តើមប្រតិបត្តិការជាផ្លូវការនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦។ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ ធនាគារ ទទួលបានអាជ្ញាប័ណ្ណ ធនាគារពាណិជ្ជ ពីធនាគារជាតិនៃកម្ពុជា និងបានផ្លាស់ប្តូរឈ្មោះពីធនាគារឯកទេស អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ភីអិលស៊ី ទៅជាធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក។

សកម្មភាពចម្បងរបស់ធនាគារ រួមមានការធ្វើប្រតិបត្តិការលើសកម្មភាពអាជីវកម្មធនាគារពាណិជ្ជ និងការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុដែលពាក់ព័ន្ធផ្សេងៗទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅ អគារលេខ ១៣២ ផ្លូវលេខ២៩៤ (កែងមហាវិថី ព្រះនរោត្តម) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងចំណូលសរុបផ្សេងៗ។

## ភាគលាភ

ពុំមានការប្រកាស ឬ ការបែងចែកភាគលាភ ហើយក្រុមប្រឹក្សាភិបាលពុំបានផ្តល់អនុសាសន៍ឲ្យមានការទូទាត់ភាគលាភសម្រាប់ការិយបរិច្ឆេទនេះទេ (២០២០៖ គ្មាន)។

## ការខាតបង់រំពឹងទុកលើឥណទាន និងបុរេប្រទាន

នៅមុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា វិធានការទាក់ទងទៅនឹងការលុបចោលនៃឥណទានអាក្រក់ ឬការទទួលស្គាល់សំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុក ហើយមានការជឿជាក់ថារាល់ឥណទានអាក្រក់ត្រូវបានលុបចោលហើយសំវិធានធនគ្រប់គ្រាន់ត្រូវបានធ្វើឡើងសម្រាប់ការខាតបង់រំពឹងទុកលើឥណទាន និងបុរេប្រទាន។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាលឲ្យ ចំនួននៃការលុបចោលលើឥណទានអាក្រក់ ឬការខាតបង់ឥណទានរំពឹងទុក នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានលក្ខណៈមិនគ្រប់គ្រាន់រហូតដល់កម្រិតជាសារវន្តណាមួយនោះទេ។

## ទ្រព្យសកម្ម

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាល ធានាថាគណៈគ្រប់គ្រងបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងអស់ ដែលមិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងអំពីហេតុការណ៍ណាមួយ ដែលអាចធ្វើឲ្យតម្លៃសន្មតនៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានការភាន់ច្រឡំ ឬភាពមិនសមស្របជាសារវន្តនោះទេ។

## វិធីសាស្រ្តកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីស្ថានភាពណាមួយ ដែលបានកើតឡើង និងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្រ្តដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងទ្រព្យអសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ។



## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (តពីទំព័រមុន)

## បំណុលយថាភាព និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ធនាគារ ដែលកើតមានឡើងចាប់តាំងពីចុងការិយបរិច្ឆេទមក ក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះធនាគា ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារ ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ធនាគារ ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចបានកំណត់ និងដល់ថ្ងៃកំណត់សង។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលរបស់ធនាគារពុំបានដឹងពីហេតុការណ៍ណាមួយ ដែលពុំទាន់បានដោះស្រាយនៅក្នុងរបាយការណ៍នេះ ឬ របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលនឹងអាចបណ្តាលឲ្យចំនួនតួលេខណាមួយ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទ ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (តពីទំព័រមុន)

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

ពុំមានព្រឹត្តិការណ៍ជាសារវន្តកើតឡើងក្រោយកាលបរិច្ឆេទរាយការណ៍ ដែលតម្រូវឲ្យមានការលាតត្រដាង ឬ និយ័តភាព ក្រៅពីព្រឹត្តិការណ៍ដែលបានលាតត្រដាងរួចហើយ នៅក្នុងកំណត់សម្គាល់ដែលភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុនោះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលមានតំណែងក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទរបាយការណ៍នេះមាន៖

| ឈ្មោះ | មុខតំណែង |
|---|---|
| លោក វង្ស ពេជ្រ | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក ឡាវ អៀវចុង | អនុប្រធានក្រុមប្រឹក្សាភិបាល |
| លោក ឡូញ ហៃ | សមាជិក |
| លោក Yu Yongshun | សមាជិក |
| លោក Zhao Wenqing | សមាជិក (លាលែងពីតំណែងនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១) |

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

អភិបាលដែលមានតំណែងនាចុងការិយបរិច្ឆេទ និងកាន់កាប់ភាគហ៊ុនរបស់ធនាគារមានដូចខាងក្រោម៖

| | ៣១ ធ្នូ ២០២១ | | | ៣១ ធ្នូ ២០២០ | | |
|---|---|---|---|---|---|---|
| | % កាន់កាប់ | ចំនួន ភាគហ៊ុន | ទឹកប្រាក់ ដុល្លារអាមេរិក | % កាន់កាប | ចំនួន ភាគហ៊ុន | ទឹកប្រាក់ ដុល្លារអាមេរិក |
| លោក វង្ស ពេជ្រ | 94.19% | 4,866 | 72,990,000 | 94.19% | 4,866 | 72,990,000 |
| លោក ឡាវ អៀវចុង | 5.81% | 300 | 4,500,000 | 5.81% | 300 | 4,500,000 |
| | 100% | 5,166 | 77,490,000 | 100% | 5,166 | 77,490,000 |

ក្រៅពីអភិបាលដែលបានបង្ហាញខាងលើនេះ ពុំមានអភិបាលផ្សេងទៀតដែលបានកាន់កាប់ភាគហ៊ុនដោយផ្ទាល់ របស់ធនាគារនោះទេ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនាចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលធនាគារជាគូភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬ លិខិតបំណុលរបស់ធនាគារ ឬ សាជីវកម្មដទៃទេ។

នៅក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុ ពុំមានអភិបាលណាម្នាក់បានទទួល ឬ មានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានទទួលដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយធនាគារ ឬ ដោយក្រុមហ៊ុនពាក់ព័ន្ធមួយជាមួយនឹងក្រុមហ៊ុនដែលអភិបាលនោះជាសមាជិក ឬ ក៏ជាមួយក្រុមហ៊ុនដែលអភិបាលនោះមានផលប្រយោជន៍ច្រើនផ្នែកហិរញ្ញវត្ថុ លើកលែងអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល លើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវដោយអះអាងថា របាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ លើស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរ សាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលរៀបចំឡើងដោយគណៈគ្រប់គ្រងដែលចាំបាច់ត្រូវ ៖

- អនុម័តនូវគោលនយោបាយគណនេយ្យ ដែលសមស្របដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តន៍ប្រកបដោយសង្គតិភាព។
- គោរពតាមតម្រូវការលាតត្រដាងព័ត៌មានតាមស្តង់ដាររបាយការណ៍



## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (តពីទំព័រមុន)

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល លើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា ("CIFRSs") ឬប្រសិនបើមានគំលាតពីស្តង់ដារ និងដើម្បីបង្ហាញភាពពិត និងត្រឹមត្រូវ គឺត្រូវធានាថា គំលាតទាំងនោះត្រូវបានបង្ហាញ ពន្យល់ និងកំណត់បរិមាណនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវ ដើម្បីធានាថាបញ្ជីគណនេយ្យត្រឹមត្រូវ ហើយត្រូវបានរក្សាទុក និង លាតត្រដាងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារឲ្យបានត្រឹមត្រូវសមហេតុផលគ្រប់ពេល ហើយនិងធានាថាបញ្ជីគណនេយ្យស្របតាមប្រព័ន្ធគណនេយ្យដែលកំពុងប្រើប្រាស់។ គណៈគ្រប់គ្រង ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសកម្មរបស់សាខា ហើយម្យ៉ាងទៀតក៏ត្រូវចាត់វិធានការសមស្រប ដើម្បីទប់ស្កាត់ និងស្វែងរកកំហុសចេតនា ហើយនិងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលអះអាងថា បានអនុវត្ត និងអនុលោមតាមតម្រូវការលើការទទួលខុសត្រូវខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់នេះ ថាបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ធនាគារសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាម CIFRSs។

តំណាងឲ្យក្រុមប្រឹក្សាភិបាល




**លោក វង្ស ពេជ្រ**
ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

២៥ មីនា ២០២២

# របាយការណ៍របស់ សវនករឯករាជ្យ

Building a better working world

យោង៖ ៦១៥៥២១៦០/២២៧៧៣៤៦៣

ជូនចំពោះ ៖ ភាគទុនិករបស់ ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក

## មតិយោបល់

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក ហៅកាត់ថា (“ធនាគារ”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងរបាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុដែលរួមមានសេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់ៗ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់ផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRSs”)។

## មូលដ្ឋានក្នុងការផ្តល់មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា (“CISAs”)។ ការទទួលខុសត្រូវរបស់យើងខ្ញុំ យោងតាមស្តង់ដារទាំងនោះ ត្រូវបានបរិយាយបន្ថែមនៅក្នុងផ្នែក “ការទទួលខុស ត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ” នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានភាពឯករាជ្យពីធនាគារ ដោយ អនុលោមទៅតាមក្រមសីលធម៌វិជ្ជាជីវៈរបស់គណនេយ្យករ និងសវនករជំនាញ ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃកម្ពុជា រួមជា មួយតម្រូវការផ្នែកសីលធម៌ ដែលពាក់ព័ន្ធនឹងការងារសវនកម្មរបស់យើង ខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំក៏បានបំពេញនូវទំនួលខុសត្រូវផ្នែកសីលធម៌ផ្សេងទៀតរបស់យើងខ្ញុំ ដោយស្របទៅតាមតម្រូវការទាំងនេះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែល យើងខ្ញុំបានទទួល គឺគ្រប់គ្រាន់ និងសមស្របដើម្បីជាមូលដ្ឋានសម្រាប់ មតិយោបល់របស់យើងខ្ញុំ។

## ព័ត៌មានផ្សេងក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍របស់សវនករ

ព័ត៌មានផ្សេងៗទៀត ដែលទទួលបាននាកាលបរិច្ឆេទរបាយការណ៍សវនករ រួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ដែលបានបរិយាយ នៅទំព័រទី ៥៨ ដល់ទី ១១៧។ គណៈគ្រប់គ្រងមានទំនួលខុសត្រូវចំពោះព័ត៌មានផ្សេងៗទៀត។

មតិយោបល់របស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុមិនគ្របដណ្តប់លើព័ត៌មានផ្សេងៗទេ ហើយយើងខ្ញុំក៏មិនបង្ហាញសេចក្តីសន្និដ្ឋានធានាអះអាងក្នុងទម្រង់ណាមួយទៅលើព័ត៌មានផ្សេងៗនេះដែរ។

ទាក់ទិននឹងការធ្វើសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុទំនួលខុសត្រូវរបស់យើងខ្ញុំ គឺការអានព័ត៌មានផ្សេងៗនេះ ហើយពិចារណាថាតើព័ត៌មានទាំងនេះមានភាពខុសគ្នាជាសារវន្ត ឬទេ ជាមួយនឹងរបាយការណ៍ ហិរញ្ញវត្ថុ ឬ ចំណេះដឹង ដែលទទួលបានក្នុងការធ្វើសវនកម្ម ឬ ថាតើព័ត៌មានផ្សេងៗ នេះមានកំហុសឆ្គងជាសារវន្ត ឬទេ។ យោងតាមការងារដែលយើងខ្ញុំបានធ្វើ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្ត ចំពោះព័ត៌មានផ្សេងៗនេះ យើងខ្ញុំតម្រូវឲ្យរាយការណ៍ពីភាពពិតជាក់ស្តែង។ យើងខ្ញុំពុំមានហេតុការណ៍អ្វីដែលតម្រូវឲ្យរាយការណ៍ ចំពោះព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវដោយអនុលោមទៅតាម CIFRSs ហើយនិង ទទួលខុសត្រូវដូចគ្នាផងដែរ ចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែល គណៈគ្រប់គ្រងគិតថា មានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលពុំមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវក្នុងការវាយតម្លៃលើនិរន្តរភាពអាជីវកម្មរបស់ធនាគារ និងធ្វើការលាតត្រដាង (ប្រសិនបើមាន) នូវបញ្ហាទាំងឡាយណា ដែលទាក់ទងនឹងនិរន្តរភាពអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មតាមវិធានគណនេយ្យរបស់ធនាគារ លើកលែងតែក្នុងករណីគណៈគ្រប់គ្រងមានបំណងរំលាយ ឬ បញ្ឈប់ប្រតិបត្តិការធនាគារ ឬ ក៏គ្មានមធ្យោបាយជាក់លាក់ណាមួយទៀតក្រៅពីនេះ។

អ្នកទទួលបន្ទុកលើអភិបាលកិច្ច មានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យមើលលើដំណើរការនៃការរាយការណ៍ អំពីហិរញ្ញវត្ថុរបស់ធនាគារ។

## របាយការណ៍របស់សវនករឯករាជ្យ (តពីទំព័រមុន)

## ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ ហើយធ្វើការចេញផ្សាយរបាយការណ៍របស់សវនករដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ការធានាដែលសមហេតុផល គឺជាការធានាអះអាងកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថាការងារសវនកម្មដែលប្រព្រឹត្តទៅ ដោយអនុលោមតាមស្តង់ដារអន្តរជាតិ ស្តីពីសវនកម្មនៃកម្ពុជា តែងតែរកឃើញជានិច្ច នូវកំហុសឆ្គងជាសារវន្តដែលមាននោះទេ។ កំហុសឆ្គងអាចកើតចេញពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ និងត្រូវបានចាត់ទុកថាជាសារវន្ត ប្រសិនបើកំហុសឆ្គងទាំងអស់នោះ (តែមួយ ឬ បញ្ចូលគ្នាជារួម) អាចមានឥទ្ធិពលលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយផ្អែកលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ជាផ្នែកមួយនៃការងារសវនកម្ម ដែលអនុលោមតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា យើងខ្ញុំបានធ្វើការវិនិច្ឆ័យ និងរក្សានូវចម្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងដំណើរការសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្តនៃរបាយការណ៍ ហិរញ្ញវត្ថុដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំផ្សេងៗ ដោយបង្កើត និងអនុវត្តនីតិវិធីសវនកម្ម ដែលឆ្លើយតបទៅនឹង ហានិភ័យទាំងនោះ ហើយប្រមូលភស្តុតាងសវនកម្មឲ្យបានគ្រប់គ្រាន់ និងសមស្របសម្រាប់ផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំមានកម្រិតខ្ពស់ជាងហានិភ័យដែល មិនអាចរកឃើញកំហុសឆ្គងដែលបណ្តាលមកពីការភាន់ច្រឡំ ព្រោះថាការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការបន្លំ ការលុបចោលដោយចេតនា ការរាយការណ៍មិនត្រឹមត្រូវ ឬ មិនគោរពតាមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការងារសវនកម្ម ដើម្បីបង្កើតជានីតិវិធីសវនកម្ម ដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារទេ។
- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលជាប់ទាក់ទងផ្សេងទៀត ដែលធ្វើឡើងដោយគណៈគ្រប់គ្រង។
- ធ្វើសេចក្តីសន្និដ្ឋាន ទៅលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្ម នៅក្នុងប្រព័ន្ធគណនេយ្យដោយគណៈគ្រប់គ្រង និងតាមរយៈភស្តុតាងសវនកម្មដែលទទួលបាន យើងខ្ញុំធ្វើការសន្និដ្ឋាន ថាតើមានវត្តមាននៃភាពមិនប្រាកដប្រជា ជាសារវន្តទាក់ទងនឹងព្រឹត្តិការណ៍ ឬ កាលៈទេសៈទាំងឡាយណាដែលនាំឲ្យមានការសង្ស័យជាសារវន្ត ទៅលើនិរន្តរភាពនៃដំណើរការអាជីវកម្មរបស់ធនាគារ ឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំតម្រូវឲ្យទាញចំណាប់អារម្មណ៍ ក្នុងរបាយការណ៍សវនករ លើកំណត់សម្គាល់ពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬ ប្រសិនបើកំណត់សម្គាល់នេះពុំមានលក្ខណៈគ្រប់គ្រាន់ទេនោះ យើងខ្ញុំនឹងធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺពឹងផ្អែកលើភស្តុតាងសវនកម្ម ដែលទទួលបានរហូតដល់កាលបរិច្ឆេទ នៃរបាយការណ៍របស់សវនករ។ តែទោះជាយ៉ាងនេះក្តី ព្រឹត្តិការណ៍ ឬកាលៈទេសៈនាពេលអនាគត ក៏អាចបង្កឲ្យធនាគារមិនអាចបន្តនិរន្តរភាពអាជីវកម្មបានផងដែរ។
- វាយតម្លៃការបង្ហាញទូទៅមាតិកា និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងកំណត់សម្គាល់ផ្សេងៗ និងវាយតម្លៃថារបាយការណ៍ហិរញ្ញវត្ថុ តំណាងឲ្យប្រតិបត្តិការ និងព្រឹត្តិការណ៍ដែលជាមូលដ្ឋានដើម្បីសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវ។
- ក្នុងចំណោមបញ្ហាដទៃទៀត យើងខ្ញុំបានធ្វើការទំនាក់ទំនងជាមួយអ្នកទទួល បន្ទុកលើអភិបាលកិច្ចអំពីវិសាលភាព ដែលបានគ្រោងទុក និងពេលវេលានៃការងារសវនកម្ម និងរបកគំហើញសំខាន់ៗ រួមបញ្ចូលផងដែរនូវកង្វះខាតសំខាន់ៗទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំរកឃើញក្នុងពេលធ្វើសវនកម្ម។

**Maria Cristina M. Calimbas**
ដៃគូសវនករ

**អឺនស្ទ៍ អែន យ៉ាំង (ខេមបូឌា)**

ក្រុមហ៊ុនគណនេយ្យករជំនាញ

សវនករប្រតិស្រុត

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២

| | កំណត់សម្គាល់ | នាថ្ងៃទី៣១ ខែធ្នូ ២០២១ | | នាថ្ងៃទី៣១ ខែធ្នូ ២០២០ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| **ទ្រព្យសកម្ម** | | | | | |
| មូលប្បទានប័ត្រ និង សាច់ប្រាក់ក្នុងដៃ | 5 | 7,080,305 | 28,845,163 | 13,618,358 | 55,086,258 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 6 | 5,572,085 | 22,700,674 | 13,115,754 | 53,053,225 |
| សមតុល្យនៅធនាគារដទៃ | 7 | 10,644,159 | 43,364,304 | 7,902,968 | 31,967,506 |
| ឥណទាន និងបុរេប្រទានទៅអតិថិជន-សុទ្ធ | 8 | 248,046,097 | 1,010,539,799 | 129,655,784 | 524,457,646 |
| មូលបត្រដែលត្រូវទទួល | 9 | 1,017,202 | 4,144,081 | - | - |
| ទ្រព្យសកម្មផ្សេងៗ | 10 | 816,819 | 3,327,721 | 128,053 | 517,974 |
| ប្រាក់តម្កល់តាមច្បាប់ | 11 | 16,965,601 | 69,117,858 | 10,959,938 | 44,332,949 |
| សូហ្វវែរ | 12 | 3,063,455 | 12,480,516 | 410,226 | 1,659,364 |
| ទ្រព្យ និងបរិក្ខារ | 13 | 1,153,707 | 4,700,202 | 260,963 | 1,055,595 |
| សិទ្ធិលើការប្រើប្រាស់ទ្រព្យសកម្ម | 14 | 11,260,239 | 45,874,214 | 115,413 | 466,846 |
| ពន្ធពន្យារជាទ្រព្យសកម្ម | 15 | 276,900 | 1,128,091 | 181,933 | 735,919 |
| **ទ្រព្យសកម្មសរុប** | | **305,896,569** | **1,246,222,623** | **176,349,390** | **713,333,282** |
| **ទ្រព្យអសកម្ម និងមូលធនម្ចាស់ភាគហ៊ុន** | | | | | |
| **ទ្រព្យអសកម្ម** | | | | | |
| ប្រាក់បញ្ញើពីគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | 16 | 67,114,757 | 273,425,520 | 10,934,383 | 44,229,579 |
| ប្រាក់បញ្ញើពីអតិថិជន | 17 | 138,887,712 | 565,828,539 | 80,775,991 | 326,738,884 |
| ប្រាក់កម្ចីពីធនាគារផ្សេង | 18 | 800,750 | 3,262,256 | 1,002,524 | 4,055,210 |
| បំណុលពន្ធលើប្រាក់ចំណូល | 15 | 1,023,684 | 4,170,489 | 741,924 | 3,001,083 |
| ទ្រព្យអសកម្មផ្សេងៗ | 19 | 927,821 | 3,779,943 | 449,756 | 1,819,262 |
| ទ្រព្យអសកម្មភតិសន្យា | 14 | 10,871,117 | 44,288,931 | 136,286 | 551,277 |
| **ទ្រព្យអសកម្មសរុប** | | **219,625,841** | **894,755,678** | **94,040,864** | **380,395,295** |
| **មូលធនម្ចាស់ភាគហ៊ុន** | | | | | |
| ដើមទុន | 20 | 77,490,000 | 309,960,000 | 77,490,000 | 309,960,000 |
| ប្រាក់ចំណេញរក្សាទុក | | 6,241,132 | 25,402,143 | 3,360,560 | 13,690,465 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 21 | 2,539,596 | 10,316,704 | 1,457,966 | 5,910,143 |
| លម្អៀងបង្គរពីបកប្រែរូបិយប័ណ្ណ | | - | 5,788,098 | - | 3,377,379 |
| **មូលធនម្ចាស់ភាគហ៊ុនសរុប** | | **86,270,728** | **351,466,945** | **82,308,526** | **332,937,987** |
| **មូលធនម្ចាស់ភាគហ៊ុន និងទ្រព្យអសកម្មសរុប** | | **305,896,569** | **1,246,222,623** | **176,349,390** | **713,333,282** |

កំណត់សម្គាល់លេខ ១ ដល់ ៣១ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។





| | កំណត់សម្គាល់ | សម្រាប់ការិយបរិច្ឆេទបញ្ចប់ នាថ្ងៃទី៣១ ខែធ្នូ ២០២១ | | សម្រាប់ការិយបរិច្ឆេទបញ្ចប់ នាថ្ងៃទី៣១ ខែធ្នូ ២០២០ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| **ចំណូលប្រតិបត្តិការ** | | | | | |
| ចំណូលការប្រាក់ | 22 | 16,995,707 | 69,138,536 | 6,486,915 | 26,447,152 |
| ចំណាយការប្រាក់ | 22 | (7,104,885) | (28,902,672) | (416,215) | (1,696,909) |
| **ចំណូលពីការប្រាក់សុទ្ធ** | | **9,890,822** | **40,235,864** | **6,070,700** | **24,750,243** |
| ចំណូលប្រតិបត្តិការផ្សេងៗ | 23 | 193,601 | 787,569 | 131,583 | 536,464 |
| ចំណាយបុគ្គលិក | 24 | (2,650,781) | (10,783,377) | (1,444,255) | (5,888,228) |
| រំលស់ | 12,13,14 | (612,711) | (2,492,508) | (526,017) | (2,144,571) |
| ចំណាយប្រតិបត្តិការផ្សេងៗ | 25 | (1,675,103) | (6,814,319) | (634,918) | (2,588,561) |
| សំវិធានធនលើការខាតបង់ឥណទានរំពឹងទុក | 26 | (100,663) | (409,497) | (13,225) | (53,918) |
| **ចំណេញមុនគិតពន្ធ** | | **5,045,165** | **20,523,732** | **3,583,868** | **14,611,429** |
| ចំណាយពន្ធលើប្រាក់ចំណូល | 15 | (1,082,963) | (4,405,493) | (727,158) | (2,964,623) |
| **ចំណេញសុទ្ធ** | | **3,962,202** | **16,118,239** | **2,856,710** | **11,646,806** |
| **ចំណូលលម្អិតផ្សេងៗ៖** | | | | | |
| ភាពខុសគ្នានៃការបកប្រែរូបិយប័ណ្ណ | | - | 2,410,719 | - | (2,474,969) |
| **ចំណេញសរុបប្រចាំឆ្នាំ** | | **3,962,202** | **18,528,958** | **2,856,710** | **9,171,837** |

កំណត់សម្គាល់លេខ ១ ដល់ ៣១ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម

| | ដើមទុន | | ប្រាក់ចំណេញរក្សាទុក | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ភាពខុសគ្នាបង្គរពីការបកប្រែរូបិយប័ណ្ណ | សរុប | |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| សមតុល្យនាថ្ងៃទី1 ខែមករា ឆ្នាំ2021 | 77,490,000 | 309,960,000 | 3,360,560 | 13,690,465 | 1,457,966 | 5,910,143 | 3,377,379 | 82,308,526 | 332,937,987 |
| ចំណេញសុទ្ធប្រចាំឆ្នាំ | - | - | 3,962,202 | 16,118,239 | - | - | - | 3,962,202 | 16,118,239 |
| ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | (1,081,630) | (4,406,561) | 1,081,630 | 4,406,561 | - | - | - |
| ភាពខុសគ្នាពីការបកប្រែរូបិយប័ណ្ណ | - | - | - | - | - | - | 2,410,719 | - | 2,410,719 |
| **នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2021** | **77,490,000** | **309,960,000** | **6,241,132** | **25,402,143** | **2,539,596** | **10,316,704** | **5,788,098** | **86,270,728** | **351,466,945** |
| | | | | | | | | | |
| សមតុល្យនាថ្ងៃទី1 ខែមករា ឆ្នាំ2020 | 77,490,000 | 309,960,000 | 1,259,662 | 5,100,919 | 702,154 | 2,852,883 | 5,852,348 | 79,451,816 | 323,766,150 |
| ចំណេញសុទ្ធប្រចាំឆ្នាំ | - | - | 2,856,710 | 11,646,806 | - | - | - | 2,856,710 | 11,646,806 |
| ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | (755,812) | (3,057,260) | 755,812 | 3,057,260 | - | - | - |
| ភាពខុសគ្នាពីការបកប្រែរូបិយប័ណ្ណ | - | - | - | - | - | - | (2,474,969) | - | (2,474,969) |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020** | **77,490,000** | **309,960,000** | **3,360,560** | **13,690,465** | **1,457,966** | **5,910,143** | **3,377,379** | **82,308,526** | **332,937,987** |

កំណត់សម្គាល់លេខ ១ ដល់ ៣១ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។





APD BANK
ASIA-PACIFIC DEVELOPMENT BANK

| | កំណត់សម្គាល់ | សម្រាប់ការិយបរិច្ឆេទ បញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | សម្រាប់ការិយបរិច្ឆេទ បញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណេញមុនគិតពន្ធ | | 5,045,165 | 20,523,732 | 3,583,868 | 14,611,429 |
| ការធ្វើនិយ័តកម្ម៖ | | | | | |
| រំលស់ | 12,13,14 | 612,711 | 2,492,508 | 526,017 | 2,144,571 |
| (ការកត់ត្រាបញ្ច្រាស់នៃ)សំវិធានធន លើការខាតបង់ឥណទានរំពឹងទុកនៃ៖ | | | | | |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា និង ធនាគារដទៃ | 26 | (5,414) | (22,024) | 6,160 | 25,114 |
| មូលបត្រនឹងត្រូវទទួល | 26 | 127 | 517 | - | - |
| ឥណទាន និងបុរេប្រទាន | 26 | 105,883 | 430,732 | 6,012 | 24,511 |
| ធាតុដែលក្រៅតារាងតុល្យការ | 26 | 67 | 272 | 1,054 | 4,298 |
| ខាតលើការលក់ទ្រព្យ និងហត្ថូបករណ៍ | 25 | 320,113 | 1,302,220 | 2,669 | 10,882 |
| ចំណាយហិរញ្ញវត្ថុលើបំណុលភតិសន្យា | 14 | 68,246 | 277,625 | 9,334 | 38,055 |
| សំវិធានធនលើអត្ថប្រយោជន៍បុគ្គលិក | 19 | 191 | 777 | (18,564) | (75,685) |
| បម្រែបម្រួល៖ | | | | | |
| ប្រាក់តម្កល់តាមច្បាប់ | | (6,005,663) | (24,431,037) | (3,209,938) | (13,086,917) |
| មូលបត្រអាចជួញដូរបាន | | 4,001,186 | 16,276,826 | (4,050,852) | (16,515,324) |
| សមតុល្យនៅធនាគារដទៃ | | (1,726,501) | (7,023,406) | (1,009,192) | (4,114,476) |
| មូលបត្រដែលត្រូវទទួល | | (1,017,329) | (4,138,494) | - | - |
| ឥណទាន និងបុរេប្រទានទៅអតិថិជន | | (118,496,196) | (482,042,525) | (59,303,114) | (241,778,796) |
| ទ្រព្យសកម្មផ្សេងៗ | | (1,227,240) | (4,992,412) | (105,908) | (431,787) |
| ប្រាក់បញ្ញើពីគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | | 56,180,374 | 228,541,761 | 10,934,383 | 44,579,479 |
| ប្រាក់បញ្ញើពីអតិថិជន | | 58,111,721 | 236,398,481 | 80,775,991 | 329,323,715 |
| ទ្រព្យអសកម្មផ្សេងៗ | | 477,808 | 1,943,723 | 272,940 | 1,112,776 |
| សាច់ប្រាក់ (ប្រើក្នុង) ទទួលបានពីប្រតិបត្តិការ | | (3,554,751) | (14,460,724) | 28,420,860 | 115,871,845 |
| ពន្ធលើប្រាក់ចំណេញដែលបានទូទាត់ | 15 | (896,170) | (3,645,620) | (635,234) | (2,589,849) |
| **សាច់ប្រាក់សុទ្ធ (ប្រើក្នុង) ទទួលបានពីសកម្មភាពប្រតិបត្តិការ** | | **(4,450,921)** | **(18,106,344)** | **27,785,626** | **113,281,996** |
| **សកម្មភាពវិនិយោគ** | | | | | |
| ការទិញនូវ៖ | | | | | |
| សូហ្វវែរ | 12 | (3,151,059) | (12,818,508) | (209,759) | (855,187) |
| ទ្រព្យ និងហត្ថូបករណ៍ | 13 | (1,109,470) | (4,513,324) | (77,348) | (315,348) |
| សាច់ប្រាក់ពីការលក់ទ្រព្យ និងហត្ថូបករណ៍ | | - | - | 127 | 518 |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ** | | **(4,260,529)** | **(17,331,832)** | **(286,980)** | **(1,170,017)** |
| **សកម្មភាពហិរញ្ញប្បទាន** | | | | | |
| ការទូទាត់លើភតិសន្យា | 14 | (158,035) | (642,886) | (120,000) | (489,240) |
| (ការទូទាត់សង) សាច់ប្រាក់កម្ចីទទួលបានពីធនាគារផ្សេង | | (201,774) | (820,817) | 1,002,524 | 4,087,290 |
| **សាច់ប្រាក់សុទ្ធ (ប្រើក្នុង) បានពីសកម្មភាពហិរញ្ញប្បទាន** | | **(359,809)** | **(1,463,703)** | **882,524** | **3,598,050** |
| (តំហយ) កំណើនសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល | | (9,071,259) | (36,901,879) | 28,381,170 | 115,710,029 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ | | 29,601,667 | 119,738,743 | 1,220,497 | 4,973,526 |
| ភាពខុសគ្នាពីការបកប្រែរូបិយប័ណ្ណ | | - | 804,019 | - | (944,812) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ** | | **20,530,408** | **83,640,883** | **29,601,667** | **119,738,743** |

កំណត់សម្គាល់លេខ ១ ដល់ ៣១ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# អំពីធនាគារ

ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក ហៅកាត់ថា (“ធនាគារ”) បានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ក្រោមបញ្ជីពាណិជ្ជកម្មលេខ ០០០០៧៥១៤ ចេញដោយក្រសួងពាណិជ្ជកម្ម។

ធនាគារ ទទួលបានអាជ្ញាប័ណ្ណ ធនាគារឯកទេស ពីធនាគារជាតិនៃកម្ពុជា (“NBC”) នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ដើម្បីធ្វើប្រតិបត្តិការជាធនាគារឯកទេស ដោយមានសុពលភាពអចិន្ត្រៃយ៍ និងចាប់ផ្តើមប្រតិបត្តិការជាផ្លូវការនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦។ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ ធនាគារ ទទួលបានអាជ្ញាប័ណ្ណ ធនាគារពាណិជ្ជ ពីធនាគារជាតិនៃកម្ពុជា និងបានផ្លាស់ប្តូរឈ្មោះពីធនាគារឯកទេស អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ភីអិលស៊ី ទៅជាធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក។

សកម្មភាពចម្បងរបស់ធនាគារ រួមមានការធ្វើប្រតិបត្តិការលើសកម្មភាពអាជីវកម្មធនាគារពាណិជ្ជ និងការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុដែលពាក់ព័ន្ធផ្សេងៗទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅ អគារលេខ ១៣២ ផ្លូវលេខ ២៩៤ (កែងមហាវិថីព្រះនរោត្តម) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ធនាគារមានបុគ្គលិកចំនួន ១១០ នាក់ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ (២០២០៖ ៤៩ នាក់)។

### ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតិឲ្យចេញ ដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២។

# មូលដ្ឋាន នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក និងរៀបចំឡើងដោយផ្អែកលើមូលដ្ឋានថ្លៃដើមប្រវត្តិសាស្ត្រ លើកលែងតែមានការចង្អុលបង្ហាញផ្សេងពីនេះ។

## ២.១. មូលដ្ឋាន នៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើង ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRSs”)។

## ២.២. ឆ្នាំសារពើពន្ធ

ឆ្នាំសារពើពន្ធរបស់ធនាគារចាប់ផ្តើមនៅថ្ងៃទី១ ខែមករា និងបញ្ចប់ នៅថ្ងៃទី៣១ ខែធ្នូ។

## ២.៣. រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

### រូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជា ប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងារ និងសម្រាប់ធ្វើការបង្ហាញរបស់ធនាគារ។

### ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀត ក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ។ សមតុល្យនៃទ្រព្យសកម្ម និងបំណុល រូបិយវត្ថុនាកាលបរិច្ឆេទរាយការណ៍ ដែលជារូបិយប័ណ្ណផ្សេងទៀត ក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រានាកាលបរិច្ឆេទរាយការណ៍នោះ។ ភាពលម្អៀងពីការប្តូររូបិយប័ណ្ណ ដែលកើតឡើងនោះត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត។

### ការបកប្រែពីទឹកប្រាក់ដុល្លារអាមេរិក ទៅជាប្រាក់រៀល

ការបកប្រែពីប្រាក់ដុល្លារអាមេរិក ទៅជាប្រាក់រៀល (“សមមូលពាន់រៀល”) ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីអនុលោមតាមច្បាប់គណនេយ្យនិង សវនកម្មចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដោយប្រើអត្រាចុងគ្រានិងអត្រាមធ្យមភាគ





APD BANK
ASIA-PACIFIC DEVELOPMENT BANK

# ២. មូលដ្ឋាន នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

## ២.៣. រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ (តពីទំព័រមុន)

### ការបកប្រែពីទឹកប្រាក់ដុល្លារអាមេរិក ទៅជាប្រាក់រៀល (តពីទំព័រមុន)

សម្រាប់ការិយបរិច្ឆេទបញ្ចប់។

ទ្រព្យសកម្ម និងទ្រព្យអសកម្មដែលមាននៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ត្រូវបានប្តូរតាមអត្រាចុងគ្រា នៃកាលបរិច្ឆេទរាយការណ៍នីមួយៗ ចំណែកឯចំណូល និងចំណាយដែលបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ ត្រូវបានបកប្រែតាមអត្រាមធ្យមសម្រាប់ការិយបរិច្ឆេទបញ្ចប់។ រាល់ភាពខុសគ្នានៃលទ្ធផលនៃការបកប្រែត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិតផ្សេងៗ។ ការបកប្រែនេះមិនមែនជាការបកស្រាយ ថាបរិមាណជាប្រាក់ដុល្លារអាមេរិកទាំងអស់នេះ ត្រូវបានប្រែសម្រួលជាប្រាក់ដុល្លារអាមេរិកលើអត្រាប្តូរប្រាក់ដទៃទេ។ រាល់តម្លៃទាំងអស់ ដែលបង្ហាញជាប្រាក់រៀល ត្រូវបានបង្គត់ជា (“សមមូលពាន់រៀល”) លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់រៀលដោយផ្អែកលើអត្រាប្តូរប្រាក់ដែលត្រូវអនុវត្តក្នុង ១ ដុល្លារអាមេរិកដូចខាងក្រោម៖

| | ២០២១ | ២០២០ |
|---|---|---|
| អត្រាចុងគ្រា | 4,074 | 4,045 |
| អត្រាមធ្យមភាគ | 4,068 | 4,077 |

## ២.៤. ការបង្គត់បរិមាណ

លើកលែងតែបានបញ្ជាក់ផ្សេងពីនេះ បរិមាណនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្គត់ទៅប្រាក់ដុល្លារអាមេរិក និងសមមូលពាន់រៀល។

## ២.៥. ស្តង់ដារដែលបានចេញផ្សាយ និងធ្វើវិសោធនកម្មដែលបានអនុម័តដោយធនាគារ

ធនាគារបានអនុម័តវិសោធនកម្មជាលើកដំបូងតាមដែលអាចអនុវត្តបានសម្រាប់រយៈពេលរាយការណ៍ប្រចាំឆ្នាំ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២១ ដូចខាងក្រោម៖

- វិសោធនកម្មចំពោះ CIFRS ១៦៖ សម្បទានជួលពាក់ព័ន្ធនឹងកូវីដ19 និង
- វិសោធនកម្មចំពោះ CIFRS ៩ CIAS ៣៩ CIFRS ៧ CIFRS ៤ និង CIFRS ១៦៖ កំណែទម្រង់អត្រាការប្រាក់ ៤ ដំណាក់កាលទី ២

វិសោធនកម្ម ខាងលើមិនមានផលប៉ះពាល់ដល់ចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ក្នុងរយៈពេលឆ្នាំមុនឡើយ ហើយមិនត្រូវបានរំពឹងថានឹងប៉ះពាល់យ៉ាងខ្លាំងដល់រយៈពេលបច្ចុប្បន្ន ឬ នាពេលអនាគតឡើយ ។

## ២.៦. ស្តង់ដារបោះផ្សាយតែពុំទាន់មានប្រសិទ្ធភាព

ស្តង់ដារ និងការធ្វើវិសោធនកម្មដែលបានបោះផ្សាយ ប៉ុន្តែពុំទាន់មានប្រសិទ្ធភាព រហូតដល់កាលបរិច្ឆេទ នៃរបាយការណ៍រហិរញ្ញវត្ថុរបស់ធនាគារ មានបង្ហាញដូចខាងក្រោម។ ស្តង់ដារទាំងនេះ និងវិសោធនកម្មលើ CIFRSs ដែលបានបោះផ្សាយ ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព និងពុំមានផលប៉ះពាល់ខ្លាំងលើស្ថានភាព ឬលទ្ធផលហិរញ្ញវត្ថុ របស់ធនាគារទេ។

- យោងទៅក្របខ័ណ្ឌគំនិត-វិសោធនកម្មចំពោះCIFRS៣
- ទ្រព្យសកម្ម គ្រឿងចក្រ និងបរិក្ខារ៖ ការទទួលបានមុនពេលប្រើប្រាស់- វិសោធនកម្ម CIAS ១៦
- កិច្ចសន្យាជាបណ្តុំ - ការចំណាយលើការបំពេញកិច្ចសន្យា -វិសោធនកម្ម CIAS ៣៧
- CIFRS ១ ការអនុម័តជាលើកដំបូងនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ - ក្រុមហ៊ុនបុត្រសម្ព័ន្ធជាអ្នកអនុម័តលើកដំបូង
- CIFRS ៩ ឧបករណ៍ហិរញ្ញវត្ថុ - ថ្លៃសេវាក្នុងការធ្វើតេស្ត ‘១០ ភាគរយ’ សម្រាប់ការឈប់ទទួលស្គាល់ទ្រព្យអសកម្មហិរញ្ញវត្ថុ
- CIAS ៤១ កសិកម្ម - ការយកពន្ធក្នុងការវាស់វែងតម្លៃសមស្រប
- CIFRS ១៧ កិច្ចសន្យាធានារ៉ាប់រង

## ២. មូលដ្ឋាន នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

## ២.៦. ស្តង់ដារបោះផ្សាយតែពុំទាន់មានប្រសិទ្ធភាព (តពីទំព័រមុន)

- វិសោធនកម្មចំពោះ CIAS ១៖ ការចាត់ថ្នាក់នៃបំណុលជាចរន្ត ឬអចរន្ត
- និយមន័យនៃការប៉ាន់ស្មានគណនេយ្យ - វិសោធនកម្មចំពោះ CIAS ៨
- ការបង្ហាញគោលនយោបាយគណនេយ្យ - វិសោធនកម្មចំពោះ CIAS ១ និង CIFRS ការអនុវត្តរបាយការណ៍ ២
- វិសោធនកម្មចំពោះ CIAS ១២៖ ពន្ធពន្យារពាក់ព័ន្ធនឹងទ្រព្យសកម្ម និង ទ្រព្យអសកម្ម កើតពីប្រតិបត្តិការទោល
- វិសោធនកម្មចំពោះ CIFRS ១០ និង CIAS ២៨៖ ការលក់ ឬ ការបរិច្ចាក នៃទ្រព្យសកម្មរវាងវិនិយោគិន និងសម្ព័ន្ធញាតិ ឬ ក្រុមហ៊ុនរួមទុន

# គោលនយោបាយគណនេយ្យសំខាន់ៗ

## ៣.១. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសមតុល្យសាច់ប្រាក់ក្នុងដៃ និងសមតុល្យនៅធនាគារជាតិនៃកម្ពុជាដែលមិនមានកំហិត ប្រាក់បញ្ញើចរន្តនៅធនាគារដទៃ និងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានកាលវសានដំបូងរយៈពេល ៣ខែ ឬ តិចជាង ហើយដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បានដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ និងត្រូវបានប្រើប្រាស់ដោយធនាគារក្នុងការគ្រប់គ្រងកាតព្វកិច្ចសាច់ប្រាក់រយៈពេលខ្លីរបស់ខ្លួន។

## ៣.២. ឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុនិងទ្រព្យអសកម្មហិរញ្ញវត្ថុរបស់ធនាគារ រួមមានមូលប្បទានប័ត្រសាច់ប្រាក់ក្នុងដៃ សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា (លើកលែងតែប្រាក់តម្កល់តាមច្បាប់) សមតុល្យជាមួយធនាគារដទៃ ឥណទាន និងបុរេប្រទានទៅអតិថិជន មូលបត្រដែលត្រូវទទួល ទ្រព្យសកម្មផ្សេងទៀត (លើកលែងតែប្រាក់តម្កល់មិនទាមទារមកវិញ និងចំណាយបង់មុន) ប្រាក់បញ្ញើពីស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត ប្រាក់បញ្ញើពីអតិថិជន កម្ចីពីធនាគារផ្សេងទៀត និងទ្រព្យអសកម្មផ្សេងទៀត (លើកលែងបំណុលពន្ធកាត់ទុក) ត្រូវបានវាស់វែងដោយវិធីតម្លៃរំលស់បង្គរ អនុលោមតាមគំរូអាជីវកម្ម (កំណត់សម្គាល់លេខ ៣.២.១)។

### ការទទួលស្គាល់ និងវាស់វែងជាលើកដំបូង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យអសកម្មហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាពេលដែលធនាគារ ក្លាយជាភាគីម្ខាង តាមលក្ខខណ្ឌនៃកិច្ចសន្យា។

ទ្រព្យសកម្ម និងទ្រព្យអសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងជាលើកដំបូងតាមតម្លៃជាក់ស្តែង។ ចំណាយប្រតិបត្តិការ ដែលបណ្តាលមកពីការទិញ ឬ បោះផ្សាយនៃទ្រព្យសកម្ម និងទ្រព្យអសកម្មហិរញ្ញវត្ថុដោយផ្ទាល់ (ក្រៅពីទ្រព្យសកម្ម និងទ្រព្យអសកម្មហិរញ្ញវត្ថុ ទទួលស្គាល់នៅតម្លៃជាក់ស្តែងក្នុងរបាយការណ៍ចំណេញ ឬ ខាត) ត្រូវបានបន្ថែម ឬ ដក ពីតម្លៃជាក់ស្តែងនៃទ្រព្យសកម្ម ឬ ទ្រព្យអសកម្មហិរញ្ញវត្ថុ សមស្របតាមការទទួលស្គាល់ដំបូង។

ប្រសិនបើតម្លៃប្រតិបត្តិការ ខុសពីតម្លៃដើមនៅពេលទទួលស្គាល់ដំបូង ធនាគារនឹងទទួលស្គាល់ចំនួនខុសគ្នាដូចខាងក្រោម៖

- ប្រសិនបើតម្លៃជាក់ស្តែង ត្រូវបានបញ្ជាក់ដោយតម្លៃដកស្រង់នៅក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ឬ អសកម្មដូចគ្នាណាមួយ ឬ ក៏ផ្អែកលើបច្ចេកទេសវាយតម្លៃដែលប្រើទិន្នន័យពី ទីផ្សារដែលអាចអង្កេតបាន នោះតម្លៃខុសគ្នាត្រូវទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតលើការទទួលស្គាល់ដំបូង (ឧទាហរណ៍៖ ការចំណេញ ឬ ខាតនៃថ្ងៃទី១)
- គ្រប់ករណីទាំងអស់ សម្រាប់តម្លៃជាក់ស្តែងនឹងត្រូវបានកែតម្រូវ ដើម្បីធ្វើឲ្យសមស្របនឹងតម្លៃប្រតិបត្តិការ (ឧទាហរណ៍៖ ការចំណេញ ឬ ខាតនៃថ្ងៃទី១ នឹងត្រូវបានពន្យារពេលទទួលស្គាល់ដោយរាប់បញ្ចូលក្នុងបរិមាណយោងដំបូងនៃទ្រព្យសកម្ម ឬ ទ្រព្យអសកម្ម)។





## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

## ៣.២. ឧបករណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

### ៣.២.១.គំរូអាជីវកម្ម

ធនាគារវាស់វែង សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា (លើកលែងតែប្រាក់តម្កល់តាមច្បាប់) សមតុល្យជាមួយធនាគារដទៃ ឥណទាន និងបុរេប្រទានទៅអតិថិជន ទ្រព្យសកម្មផ្សេងទៀត (លើកលែងតែប្រាក់តម្កល់មិនទាមទារមកវិញ និងចំណាយបង់មុន) តាមវិធីតម្លៃរំលស់បង្គរផ្អែកតាមគំរូអាជីវកម្ម ឬ លក្ខខណ្ឌគ្រប់គ្រងទ្រព្យសកម្មនៃកិច្ចសន្យា នៅពេលលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ៖

- ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានធ្វើឡើងតាមគំរូអាជីវកម្មក្នុងគោលបំណងរក្សាទុក ដើម្បីប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា
- លក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុ បង្កើតឡើងនូវកាលបរិច្ឆេទជាក់លាក់នៃលំហូរសាច់ប្រាក់ដែលសម្រាប់តែទូទាត់តែលើប្រាក់ដើមនិងការប្រាក់តែប៉ុណ្ណោះ ទៅលើចំនួនដើមដែលសល់។

ចំណុចលម្អិតនៃលក្ខខណ្ឌទាំងនោះបានបង្ហាញដូចខាងក្រោម ៖

ធនាគារធ្វើការវាយតម្លៃអំពីគោលបំណងនៃគំរូអាជីវកម្មដែលទ្រព្យសកម្ម ត្រូវបានគ្រប់គ្រងនៅកម្រិតបណ្តុំទ្រព្យសកម្មដែលឆ្លុះបញ្ចាំងពីការគ្រប់គ្រងទ្រព្យសកម្មដោយជាក់ស្តែងបំផុត។ កត្តាពិចារណារួមមាន៖

- គោលការណ៍ និងគោលបំណងដែលបានចែងសម្រាប់បណ្តុំទ្រព្យសកម្ម និងការអនុវត្តជាក់ស្តែងលើគោលការណ៍ទាំងនោះ។ ជាពិសេសយុទ្ធសាស្រ្តរបស់អ្នកគ្រប់គ្រងគឺ ផ្តោតលើការទទួលបានជាចំណូលការប្រាក់តាមកិច្ចសន្យា ដោយរក្សានូវអត្រាការប្រាក់ជាក់លាក់មួយដែលត្រូវគ្នានឹងរយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុទៅនឹងរយៈពេលនៃទ្រព្យអសកម្ម ដែលយកមកប្រើប្រាស់សំរាប់បង្វិលទ្រព្យសកម្មទាំងនោះ ឬការទទួលស្គាល់ជាលំហូរសាច់ប្រាក់តាមរយៈ ការលក់ទ្រព្យសកម្មនោះ។
- របៀបដែលការអនុវត្តគំរូអាជីវកម្ម និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងគំរូអាជីវកម្មនោះត្រូវបានវាយតម្លៃនិងរាយការណ៍ ទៅបុគ្គលិកគ្រប់គ្រងសំខាន់របស់ធនាគារ។
- ហានិភ័យដែលប៉ះពាល់ដល់ការអនុវត្តគំរូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងគំរូអាជីវកម្មនោះ) និងជាពិសេស វិធីដែលហានិភ័យត្រូវបានគ្រប់គ្រង។
- របៀបដែលអ្នកគ្រប់គ្រងអាជីវកម្មទទួលបានសំណង (ឧទាហរណ៍ថាតើសំណងគឺផ្អែកលើតម្លៃសមរម្យនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬ លំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល។
- ភាពញឹកញាប់ បរិមាណ និងពេលវេលានៃការលក់បាននៅការិយបរិច្ឆេទមុន មូលហេតុដែលធ្វើឲ្យការលក់ និងការរំពឹងទុកនៃសកម្មភាពលក់នាពេលអនាគត។ ទោះបីជាយ៉ាងណាក៏ដោយព័ត៌មានពីសកម្មភាពលក់ គឺមិនបានយកមកដាច់ដោយឡែកនោះទេ តែវាជាផ្នែកនៃការវាយតម្លៃជារួមលើរបៀបដែលធនាគារ បង្ហាញពីការសម្រេចលើគោលបំណងរបស់ខ្លួនក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងរបៀបក្នុងការទទួលស្គាល់លំហូរសាច់ប្រាក់។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលដាក់លក់ ឬ បែងចែកព្រមទាំងសកម្មភាព ដែលត្រូវវាយតម្លៃតាមមូលដ្ឋានតម្លៃជាក់ស្តែងត្រូវវាស់វែង តាមរយៈតម្លៃជាក់ស្តែងក្នុងរបាយការណ៍ចំណេញ ឬខាត(“FVTPL”) ពីព្រោះតែទ្រព្យទាំងនោះមិនអាចប្រមូលនូវកិច្ចសន្យាលំហូរសាច់ប្រាក់ ឬ លក់ជាទ្រព្យសកម្មហិរញ្ញវត្ថុបាន។

### ៣.២.២.ការធ្វើតេស្តលើការទូទាត់តែប្រាក់ដើម និងការប្រាក់ប៉ុណ្ណោះ

ជាជំហ៊ានទី២ នៃដំណើរការធ្វើចំណាត់ថ្នាក់របស់ធនាគារ គឺធនាគារវាយតម្លៃលើលក្ខខណ្ឌកិច្ចសន្យា នៃទ្រព្យសកម្មហិរញ្ញវត្ថុដើម្បីកំណត់ថាអាចជាប់តេស្ត SPPI ដែរឬទេ។

សម្រាប់គោលបំណងនៃការវាយតម្លៃ “ប្រាក់ដើម” ត្រូវបានកំណត់ជាតម្លៃជាក់ស្តែងនៃទ្រព្យសកម្មហិរញ្ញវត្ថុលើការទទួលស្គាល់ដំបូង។ “ការប្រាក់” ត្រូវបានកំណត់ជាការទូទាត់សម្រាប់តម្លៃពេលវេលានៃសាច់ប្រាក់ និងសម្រាប់ហានិភ័យឥណទានដែលទាក់ទងនឹងចំនួនទឹកប្រាក់ដែលនៅសល់ក្នុងអំឡុងពេលជាក់លាក់ណាមួយ ចំណែកឯហានិភ័យនិងការផ្តល់ឥណទានដទៃ (ដូចជា ហានិភ័យលើសាច់ប្រាក់ងាយស្រួល និងចំណាយរដ្ឋបាល) រួមទាំងចំណេញ។

ក្នុងការវាយតម្លៃលំហូរសាច់ប្រាក់តាមកិច្ចសន្យាជា SPPI ធនាគារត្រូវតែពិចារណាលើលក្ខខណ្ឌនៃកិច្ចសន្យា។ នេះរួមបញ្ចូលទាំងការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុមានរយៈពេលកិច្ចសន្យាដែលអាចផ្លាស់ប្តូរខណៈវេលា ឬ ចំនួនលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលជាករណីនឹងមិនបំពេញតាមលក្ខខណ្ឌនេះទេ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

## ៣.២. ឧបករណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

### ៣.២.២.ការធ្វើតេស្តលើការទូទាត់តែប្រាក់ដើម និងការប្រាក់ប៉ុណ្ណោះ (តពីទំព័រមុន)

ដើម្បីធ្វើការវាយតម្លៃបាន ធនាគារត្រូវសិក្សារទៅលើ៖

- យថាភាពដែលអាចផ្លាស់ប្តូរចំនួននិងរយៈពេលរបស់លំហូរសាច់ប្រាក់
- ស្ថានភាពវិនិយោគ
- ការបង់ប្រាក់ជាមុននិងការពន្យារពេលបង់
- លក្ខខណ្ឌដែលផ្អាកលើការទាមទាររបស់ធនាគារលើលំហូរសាច់ប្រាក់ពីទ្រព្យសកម្មជាក់លាក់ ណាមួយ (ឧទាហរណ៍៖ ឥណទានធានាដោយទ្រព្យ) និង
- ស្ថានភាពដែលកែប្រែការទូទាត់នៃតម្លៃ នៃសាច់ប្រាក់ ដែលប្រែប្រួលតាមពេលវេលា (ឧទាហរណ៍៖ ការកំណត់អត្រាការប្រាក់ឡើងវិញតាមរយៈពេល ដែលបានកំណត់)។

#### ឥណទានគ្មានសំណង

ក្នុងករណីខ្លះឥណទានផ្តល់ដោយធនាគារ ត្រូវបានធានាដោយទ្រព្យបញ្ចាំរបស់អ្នកខ្ចី មានការដាក់កម្រិតលើធនាគារក្នុងការទាមទារសាច់ប្រាក់ពីទ្រព្យបញ្ចាំទាំងនោះ (ឥណទានគ្មានសំណង)។ ធនាគារ ធ្វើការវិនិច្ឆ័យក្នុងការវាយតម្លៃថាតើឥណទានគ្មានសំណងទាំងនោះ មានគ្រប់ចំនុចដែលតម្រូវដោយ SPPI។ ធនាគារប្រើប្រាស់នូវព័ត៌មានដូចខាងក្រោមក្នុងការវិភាគ៖

- កិច្ចសន្យាឥណទានមាន បញ្ជាក់យ៉ាងច្បាស់លាស់ទៅលើចំនួនទឹកប្រាក់និងកាលបរិច្ឆេទសងត្រឡប់។
- តម្លៃជាក់ស្តែងនៃទ្រព្យបញ្ចាំ ប្រៀបធៀបនឹងតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានធានា។
- សមត្ថភាពនិងឆន្ទៈរបស់អ្នកខ្ចី ក្នុងការទូទាត់តាមកិច្ចសន្យាទោះបីមានការធ្លាក់ចុះនៃតម្លៃទ្រព្យបញ្ចាំក៏ដោយ។
- អ្នកខ្ចីជាឯកតបុគ្គល ឬ ក្រុមហ៊ុន ឬ ក្រុមហ៊ុនដែលបង្កើតក្រោមលក្ខណៈពិសេស។
- ហានិភ័យរបស់ធនាគារ ក្នុងការខាតបង់លើទ្រព្យសកម្មធៀបនឹងឥណទានដែលមានសំណងពេញលេញ។
- តម្លៃទ្រព្យធានារបស់អ្នកខ្ចីដែលធនាគារនឹងអាចទទួលបាន។ និង
- ធនាគារនឹងទទួលបានអត្ថប្រយោជន៍ក្នុងការឡើងថ្លៃនៃទ្រព្យបញ្ចាំ។

#### ការចំណាត់ថ្នាក់ឡើងវិញ នៃទ្រព្យសកម្មនិងអសកម្មហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ បន្ទាប់ពីទទួលស្គាល់ដំបូងរបស់វាឡើយលើកលែងតែក្នុងកាលបរិច្ឆេទ ក្រោយពីធនាគារប្តូរគំរូអាជីវកម្មរបស់ខ្លួន ដើម្បីគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

### ៣.២.៣.ការមិនទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យអសកម្មហិរញ្ញវត្ថុ ទ្រព្យសកម្មហិរញ្ញវត្ថុ

#### ទ្រព្យសកម្មហិរញ្ញវត្ថុ

ធនាគារមិនទទួលស្គាល់លើ ទ្រព្យសកម្មហិរញ្ញវត្ថុនៅពេល ដែលកិច្ចសន្យាក្នុងការប្រមូលសាច់ប្រាក់ ទៅលើទ្រព្យសកម្មមានការផុតកំណត់ ឬការផ្ទេរសិទ្ធិឬក្នុងលក្ខណណាមួយដែលទ្រព្យសកម្មហិរញ្ញវត្ថុមិនស្ថិតក្នុងការទទួលខុសត្រូវ ឬ គ្រប់គ្រងដោយធនាគារ។

ពេលឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពខុសគ្នារវាងតម្លៃយោងរបស់ទ្រព្យ (ឬ តម្លៃយោងដែលបានបែងចែកទៅចំណែកនៃទ្រព្យដែលឈប់ទទួលស្គាល់) និងផលបូកនៃ (i) ការទូទាត់អាចទទួលបាន (រាប់បញ្ចូលទាំងទ្រព្យសកម្មថ្មីដែលយកបាន ដកនូវបំណុលថ្មីដែលត្រូវរាប់រង់) និង (ii) រាល់បង្គរចំណេញឬខាត ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬ ខាត ត្រូវយកមកទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬ ខាត និងចំណូលសរុបផ្សេងៗ។

#### ទ្រព្យអសកម្មហិរញ្ញវត្ថុ

ទ្រព្យអសកម្មហិរញ្ញវត្ថុត្រូវបាន ឈប់ទទួលស្គាល់នៅពេលដែលកាតព្វកិច្ចនៃបំណុលត្រូវបានរំលាយ លុបចោល ឬផុតកំណត់។ នៅពេលដែលទ្រព្យអសកម្មហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានជំនួសដោយទ្រព្យអសកម្មហិរញ្ញវត្ថុមួយទៀត ដោយម្ចាស់ឥណទានតែមួយប៉ុន្តែលក្ខខណ្ឌខុសគ្នា កត់សម្គាល់ ឬលក្ខខណ្ឌនៃបំណុលដែលមានស្រាប់ត្រូវបានកែប្រែ ការផ្លាស់ប្តូរឬកែប្រែបែបនេះ ត្រូវបានចាត់ទុកថាជាការឈប់ទទួលស្គាល់បំណុលដើមនិងការទទួលស្គាល់បំណុលថ្មី។ ភាពខុសគ្នារវាងតម្លៃយោង នៃបំណុលហិរញ្ញវត្ថុដើមនិងការទូទាត់ដែលបានបង់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។





APD BANK
ASIA-PACIFIC DEVELOPMENT BANK

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

## ៣.២. ឧបករណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

### ៣.២.៤.ការកែប្រែ និងការហាមឃាត់ទ្រព្យសកម្មហិរញ្ញវត្ថុ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ ធនាគារត្រូវធ្វើការវាយតម្លៃលើលំហូរសាច់ប្រាក់នៃទ្រព្យសកម្មដែលបានកែប្រែដែលនឹងមានភាពខុសគ្នាខ្លាំង។

ប្រសិនបើលំហូរសាច់ប្រាក់មានភាពខុសគ្នាខ្លាំងនោះ សិទ្ធិលើលំហូរសាច់ប្រាក់នៃកិច្ចសន្យា ពីទ្រព្យសកម្មហិរញ្ញវត្ថុដើមត្រូវបានចាត់ទុកថាផុតកំណត់។ ក្នុងករណីនេះទ្រព្យសកម្មហិរញ្ញវត្ថុដើមត្រូវឈប់ទទួលស្គាល់ ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មីត្រូវបានទទួលស្គាល់ក្នុងតម្លៃជាក់ស្តែងបូកនឹងថ្លៃប្រតិបត្តិការនានា។ កម្រៃដែលទទួលបានជាផ្នែកនៃការកែប្រែត្រូវបានទទួលស្គាល់ដូចខាងក្រោម៖

- ថ្លៃសេវាដែលត្រូវបានចាត់ទុកក្នុងការកំណត់តម្លៃជាក់ស្តែងនៃទ្រព្យសកម្មថ្មីនិងថ្លៃសេវា ដែលតំណាងឲ្យការទូទាត់ថ្លៃប្រតិបត្តិការសមស្របត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងដំបូងនៃទ្រព្យសកម្ម។ និង
- ថ្លៃឈ្នួលផ្សេងទៀតត្រូវបានរាប់បញ្ចូលក្នុងរបាយការណ៍ចំណេញ ឬខាត ដែលជាផ្នែកមួយនៃការចំណេញឬខាតលើការឈប់ទទួលស្គាល់។ ប្រសិនបើលំហូរសាច់ប្រាក់ត្រូវបានកែប្រែនៅពេលដែលអ្នកខ្ចីជួបការលំបាកផ្នែកហិរញ្ញវត្ថុ ដូច្នេះគោលបំណងនៃការកែប្រែជាទូទៅគឺដើម្បីទទួលបានមកវិញនូវលំហូរសាច់ប្រាក់ជាអតិបរិមាតាមលក្ខខណ្ឌកិច្ចសន្យាដើម ជាងការបង្កើតទ្រព្យសកម្មថ្មីដែលមានលក្ខខណ្ឌខុសពីមុនច្រើន។ ប្រសិនបើធនាគារមានផែនការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបមួយ ដែលអាចនាំឲ្យមានការលើកលែងលើលំហូរសាច់ប្រាក់នោះ ធនាគារត្រូវពិចារណាជាមុនថាតើផ្នែកណាមួយនៃទ្រព្យសកម្មគួរតែត្រូវបានលុបចោលមុនពេលការកែប្រែកើតឡើង (សូមមើលខាងក្រោមសម្រាប់គោលនយោបាយ លុបចោល)។ វិធីសាស្ត្រនេះ ជះឥទ្ធិពលដល់លទ្ធផលនៃការវាយតម្លៃលើតម្លៃបរិមាណនិងមានន័យថាជាទូទៅលក្ខណៈវិនិច្ឆ័យនៃការឈប់ទទួលស្គាល់ មិនត្រូវបានបំពេញទេ។
- ប្រសិនបើ ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងដោយចំណាយរំលស់ ឬ FVOCI មិនបណ្តាលឲ្យមានការមិនទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទេនោះធនាគារនឹងធ្វើការគណនាឡើងវិញនូវចំនួនទឹកប្រាក់ដែលបានតម្កល់សរុបនៃទ្រព្យសកម្មហិរញ្ញវត្ថុដោយប្រើអត្រាការប្រាក់ដំបូងដែលមានប្រសិទ្ធភាពនិងទទួលស្គាល់លទ្ធផពីកែសំរួល រឺខាតចំណេញនិងខាត ត្រូវបានកត់ត្រាចុះក្នុងរបាយការណ៍ចំណេញ ឬខាត។ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ អត្រាអណ្តែតអត្រាការប្រាក់មានប្រសិទ្ធភាពដំបូង ដែលត្រូវបានប្រើដើម្បីគណនាការកើនឡើង ឬ ការខាតបង់ត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ននៅពេលធ្វើការកែប្រែ។ ថ្លៃដើម ឬ ថ្លៃឈ្នួលណាមួយដែលទទួលបានជាផ្នែកនៃការកែប្រែ កែប្រែចំនួនតម្លើងសរុបនៃទ្រព្យសកម្មដែលបានកែប្រែ ហើយត្រូវបានគេធ្វើរំលស់លើរយៈពេលនៅសល់នៃទ្រព្យសកម្មដែលបានកែប្រែ។
- ប្រសិនបើការកែប្រែបែបនេះត្រូវបានអនុវត្តដោយសារតែការលំបាក ផ្នែកហិរញ្ញវត្ថុរបស់អ្នកខ្ចីបន្ទាប់មកនោះភាពចំណេញ ឬ ខាតត្រូវបានបង្ហាញរួមគ្នាជាមួយ នឹងការខាតបង់លើឱនភាពនៃតម្លៃ។ ក្នុងករណីផ្សេងទៀតវាត្រូវបានបង្ហាញជាចំណូលការប្រាក់ ដែលបានគណនាដោយអត្រាការប្រាក់ប្រកបដោយប្រសិទ្ធភាព។

### ៣.២.៥.ការកាត់កង

ទ្រព្យសកម្មហិរញ្ញវត្ថុនិងទ្រព្យអសកម្មហិរញ្ញវត្ថុ ត្រូវបានកាត់កងហើយនឹងត្រូវបានដាក់បង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ការដាក់បង្ហាញនេះត្រូវតម្រូវឲ្យធនាគារត្រូវមានសិទ្ធិជាផ្លូវច្បាប់ក្នុងការកាត់កង និងមានបំណងក្នុងការកាត់កងដោយប្រើតម្លៃសុទ្ធ ឬ ដាក់ចូលទៅក្នុងទ្រព្យសកម្មហិរញ្ញវត្ថុនិងទ្រព្យអសកម្មហិរញ្ញវត្ថុ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

## ៣.២. ឧបករណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

### ៣.២.៦.ការវាស់វែងតាមតម្លៃជាក់ស្តែង

តម្លៃ ជាក់ស្តែង' គឺជាតម្លៃដែលត្រូវទទួលក្នុងការលក់ទ្រព្យសកម្ម ឬ ទូទាត់ដើម្បីផ្ទេរបំណុលក្នុងប្រតិបត្តិការ រវាងបុគ្គលនៅក្នុងទីផ្សារ នៅកាលបរិច្ឆេទនៃការវាស់វែងដើម ឬ ក្នុងករណីដែលមិនមានទីផ្សារមានអត្ថប្រយោជន៍ច្រើនបំផុតដែលធនាគារមាន នៅកាលបរិច្ឆេទនោះ។ តម្លៃសមរម្យនៃការទទួលខុសត្រូវឆ្លុះបញ្ចាំងពីហានិភ័យមិនដំណើរការ។

ធនាគារធ្វើការគណនាតម្លៃជាក់ស្តែងនៃ ឧបករណ៍ហិរញ្ញវត្ថុ ដោយប្រើតម្លៃដែលបានកំណត់នៅក្នុងទីផ្សារសេរី។ ទីផ្សារមួយដែលកំណត់ថាជា"ទីផ្សារសកម្ម" គឺនៅក្នុងករណីដែលប្រតិបត្តិការដែលទាក់ទងទៅនឹងទ្រព្យសកម្ម និងទ្រព្យអសកម្មកើតឡើងញឹកញាប់ និងមានព័ត៌មានស្តីពីធាតុទាំងនោះច្រើនដែលអាចយកមកសិក្សាតម្លៃបាននៅពេលដែលធនាគារចង់បាន។

ប្រសិនបើមិនមានតម្លៃកត់ត្រាទុកនៅក្នុងទីផ្សារនោះទេ ដូច្នេះធនាគារត្រូវប្រើវិធីសាស្ត្រក្នុងការវាស់វែងដោយយកព័ត៌មានដែលទាក់ទងទៅ នឹងធាតុចូលរបស់ធនាគារដែលបានគ្រប់គ្រងបានក្នុងកំរិតអតិបរមា និងធាតុចូលរបស់ធនាគារ ដែលមិនអាចគ្រប់គ្រងបានក្នុងកំរិតអប្បបរិមា។

ភស្តុតាងល្អបំផុតនៃតម្លៃជាក់ស្តែងរបស់ឧបករណ៍ហិរញ្ញវត្ថុក្នុងការកំណត់តម្លៃដំបូង ដែលហៅថា តម្លៃប្រតិបត្តិការ ឧទាហរណ៍ តម្លៃជាក់ស្តែងដែលប្រើប្រាស់សម្រាប់ការលក់ឬទិញ។ ប្រសិនបើធនាគារគណនាតម្លៃជាក់ស្តែង នៅក្នុងការកំណត់តម្លៃដំបូងមានភាពខុសគ្នា ពីតម្លៃនៅថ្ងៃធ្វើប្រតិបត្តិការ ហើយតម្លៃជាក់ស្តែងដែលប្រើនោះមានការបញ្ជាក់ ដោយមិនមានការកត់ត្រាតម្លៃនៅក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម និងទ្រព្យអសកម្ម ហើយក៏មិនមានមូលដ្ឋានក្នុងការវាយតម្លៃសម្រាប់ធាតុចូលដែលមិនអាចគ្រប់គ្រងបាន ដែលមានទំហំមិនធំប្រសិនបើធ្វើការប្រៀបធៀបទៅនឹងធាតុផ្សេងដែលមាននៅក្នុងការគណនាខាងលើ ហើយឧបករណ៍ហិរញ្ញវត្ថុត្រូវបានកំណត់ដំបូងដោយប្រើប្រាស់តម្លៃជាក់ស្តែង ការកែតម្រូវត្រូវធ្វើឡើងនៅពេលដែលមានភាពខុសគ្នារវាងតម្លៃទីផ្សារនៅពេលដែលកំណត់ដំបូង និងតម្លៃនៅថ្ងៃដែលប្រតិបត្តិពេលមួយដែលការផ្លាស់ប្តូរបានកើតឡើង។

ការនោះកើត មានឡើង។ ភាពលម្អៀងនឹងត្រូវដាក់ចូលទៅក្នុងរបាយការណ៍ចំណេញ ឬ ខាត ក្នុងគ្រានីមួយៗដែលភាពលម្អៀងនោះបានកើតឡើង ក៏ប៉ុន្តែធនាគារក៏ត្រូវពិចារណាផងដែលថាគ្រានីមួយៗ របស់ឧបករណ៍ទាំងអស់នោះមិនត្រូវយូរពេកឡើយ ហើយការ កំណត់គ្រានីមួយៗ នោះត្រូវមានការសិក្សាដោយប្រើទិន្នន័យទីផ្សារ ឬ ប្រតិបត្តិការដែលចប់សព្វគ្រប់។

ប្រសិនបើទ្រព្យសកម្ម និងទ្រព្យអសកម្មត្រូវបានវាស់វែងដោយប្រើតម្លៃទីផ្សារ ដោយមានតម្លៃលក់ និងតម្លៃទិញ នោះធនាគារអាចគណនាតម្លៃទ្រព្យសកម្ម ក៏ដូចជាធាតុដែលមានរយៈពេលវែងក្នុងតុល្យការរយៈពេលវែង ដោយប្រើអត្រាតម្លៃទិញ និងគណនាតម្លៃទ្រព្យអសកម្មក៏ដូចជាធាតុដែលមានរយៈពេលខ្លីដោយប្រើអត្រាតម្លៃលក់។

ផលប័ត្រនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យអសកម្មហិរញ្ញវត្ថុដែលត្រូវបានប៉ះពាល់ទៅនឹងហានិភ័យទីផ្សារនិងហានិភ័យឥណទាន ដែលត្រូវបានគ្រប់គ្រងដោយធនាគារ ដោយផ្អែកលើហានិភ័យនៃហានិភ័យទីផ្សារ និងហានិភ័យឥណទានត្រូវបានវាស់វែង ដោយផ្អែកលើតម្លៃដែលអាចទទួលបាននៅពេលលក់ធាតុនៅក្នុងតុល្យការរយៈពេលវែង (ឬ ចំណាយដើម្បីផ្ទេរធាតុនៅក្នុងតុល្យការរយៈពេលខ្លី) សម្រាប់ហានិភ័យជាក់ស្តែងណាមួយ។ ការកែកម្រិតផលប័ត្រ ដូចជា អត្រាទិញ លក់ - ឬការកែប្រែហានិភ័យឥណទាន ដែលដូចគ្នាទៅនឹងការគណនារបស់មូលដ្ឋាន នៃហានិភ័យសុទ្ធដែលត្រូវបែងចែកទៅថ្នាក់ទ្រព្យសកម្ម និងទ្រព្យអសកម្មនីមួយៗ នៅក្នុងមូលដ្ឋានកែតម្រូវដែលមានហានិភ័យ។

តម្លៃជាក់ស្តែងនៃទ្រព្យអសកម្មហិរញ្ញវត្ថុ ដែលមានគណនីចរន្តដែលមានចំនួនមិនលើសពីទំហំ ដែលត្រូវបង់ក្រោយពីធ្វើការបន្ទាបតម្លៃនៅថ្ងៃទីមួយដែលធនាគារតម្រូវឲ្យបង់។

ធនាគារទទួលស្គាល់ការផ្ទេរតាមថ្នាក់របស់តម្លៃទីផ្សារ ដោយយកតម្លៃនៅចុងគ្រានៃការចុះផ្សាយរបាយការណ៍ដែលជា

### ៣.២.៧.ការខាតបង់ឥណទានរំពឹងទុក ("ECLs")

ធនាគារទទួលស្គាល់ការខាតបង់សម្រាប់ ECLs លើឧបករណ៍ហិរញ្ញវត្ថុដូចខាងក្រោមដែលមិនត្រូវបានវាស់វែងដោយតម្លៃទីផ្សារដោយដាក់ចូលទៅក្នុងរបាយការណ៍ចំណេញ ឬខាត (FVTPL)៖

- សមតុល្យជាមួយធនាគារផ្សេងៗ។
- ឥណទាននិងបុរេប្រទានដល់អតិថិជន និង
- មូលបត្រដែលត្រូវទទួល





## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

## ៣.២. ឧបករណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

### ៣.២.៧.ការខាតបង់ឥណទានរំពឹងទុក ("ECLs") (តពីទំព័រមុន)

- កិច្ចសន្យាឥណទាននិងកិច្ចសន្យាធានាហិរញ្ញវត្ថុដែលបានចេញ

ECLs ត្រូវបានទាមទារដើម្បីវាស់វែងតាមរយៈសំវិធានធនបាត់បង់នៅចំនួនទឹកប្រាក់ស្មើនឹង៖

- ECL ១២ ខែ ដែល ECL ពេញមួយអាយុកាល ដែលជាលទ្ធផលមកពីការបាត់បង់ លើឧបករណ៍ហិរញ្ញវត្ថុក្នុងអំឡុងពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ (យោងតាមដំណាក់កាលទី ១)។ ឬ
- ECL ពេញមួយអាយុកាល ដែលECL ពេញមួយអាយុកាលគឺជាលទ្ធផលដែលបានមកពីព្រឹត្តិការណ៍ ដែលអាចនឹងធ្វើឲ្យមានការបាត់បង់លើ ឧបករណ៍ហិរញ្ញវត្ថុ (សំដៅទៅលើដំណាក់កាលទី ២ និងដំណាក់កាលទី ៣)។

សំវិធានធនការបាត់បង់សម្រាប់ ECL ពេញមួយអាយុកាល ត្រូវតែគណនាសម្រាប់ឧបករណ៍ហិរញ្ញវត្ថុប្រសិនបើ ហានិភ័យឥណទានលើឧបករណ៍ហិរញ្ញវត្ថុនោះមានកើនឡើងខ្លាំង តាំងពីការទទួលស្គាល់ដំបូង។ ចំពោះឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ECLs ត្រូវបានវាស់វែងក្នុងចំនួនមួយដែលស្មើនឹងECL ១២ខែ។ ព័ត៌មានលម្អិតបន្ថែមស្តីពីការកើនខ្លាំងនៃហានិភ័យឥណទានមានដូចខាងក្រោម។

ECLs គឺជាការប៉ាន់ស្មានដោយផ្អែកលើប្រូបាប៊ីលីតេនៃតម្លៃបច្ចុប្បន្ននៃការបាត់បង់ឥណទាន។ ទាំងនេះត្រូវបានវាស់វែងថាជាតម្លៃបច្ចុប្បន្ន នៃភាពខុសគ្នារវាងលំហូរសាច់ប្រាក់ដោយសារតែធនាគារក្រោមកិច្ចសន្យានិងលំហូរសាច់ប្រាក់ ដែលធនាគាររំពឹងថានឹងទទួលបានពីការថ្លឹងថ្លែងពីស្ថានភាពសេដ្ឋកិច្ចនាពេលអនាគត ដែលធ្វើឲ្យអត្រាការប្រាក់ដែលទទួលយក (EIR) នៃ ទ្រព្យសកម្មមានការធ្លាក់ចុះ។

- ឥណទានកិច្ចសន្យាដែលមិនទាន់បានដាក់ឲ្យអតិថិជនប្រើប្រាស់ ECL គឺជាភាពខុសគ្នារវាងតម្លៃបច្ចុប្បន្ននៃភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលកើតឡើងដោយសារធនាគារប្រសិនបើអ្នកកាន់ការប្តេជ្ញាចិត្តដកឥណទាន និងលំហូរសាច់ប្រាក់ដែលធនាគាររំពឹងថានឹងទទួលបានប្រសិនបើ ឥណទានត្រូវបានដកចេញ និង
- សម្រាប់កិច្ចសន្យាធានាហិរញ្ញវត្ថុ ECL គឺជាភាពខុសគ្នារវាងការចំណាយដែលរំពឹងទុកដើម្បីសងអ្នកកាន់ឧបករណ៍បំណុលដែលបានធានាតិចជាងចំនួនទឹកប្រាក់ដែលធនាគាររំពឹងថានឹងទទួលបានពីអ្នកកាន់បំណុលម្ចាស់បំណុលឬភាគីផ្សេងទៀត។

ធនាគារគណនា ECL លើមូលដ្ឋានបុគ្គលឬផ្អែកលើមូលដ្ឋានសមូហភាពសម្រាប់ផលប័ត្រឥណទានដែលមានលក្ខណៈហានិភ័យសេដ្ឋកិច្ចស្រដៀងគ្នា។ ការគណនាសំវិធានធនបាត់បង់គឺផ្អែកលើតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ដែលរំពឹងទុករបស់ទ្រព្យដោយប្រើ EIR ដើមរបស់ទ្រព្យដោយមិនផ្អែកលើមូលដ្ឋានគណនាបុគ្គល ឬជាសមូហភាពឡើយ។

### ឥណទានអ៊ីមភែរមិននៃទ្រព្យសកម្មហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុមាន «ឥណទានអ៊ីមភែរមិន» នៅពេលព្រឹត្តិការណ៍មួយឬច្រើនដែលមានផលប៉ះពាល់យ៉ាងខ្លាំងលើលំហូរសាច់ប្រាក់ហិរញ្ញវត្ថុនាពេលអនាគតរបស់ទ្រព្យសកម្មហិរញ្ញវត្ថុបានកើតឡើង។ ឥណទានអ៊ីមភែរមិននៃទ្រព្យសម្មហិរញ្ញវត្ថុត្រូវបានគេចាត់ទុកថាជាទ្រព្យសកម្មដំណាក់កាលទី ៣។ ភស្តុតាងនៃឥណទានអ៊ីមភែរមិនរួមមានទិន្នន័យដែលអាចអង្កេតបានអំពីព្រឹត្តិការណ៍ដូចខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុសំខាន់ៗរបស់អ្នកខ្ចី ឬ អ្នកបោះផ្សាយ
- ការមិនគោរពលើកិច្ចសន្យាដូចជាករណីហួសកាលកំណត់ ឬ ហួសកាលបរិច្ឆេទកំណត់
- ការប្រែប្រួលសេដ្ឋកិច្ចដែលធ្វើឲ្យអ្នកខ្ចីមានការលំបាកក្នុងការសងត្រឡប់ក៏ប៉ុន្តែងអ្នកឲ្យខ្ចីមិនបានគិតពិចារណាក្នុងការធ្វើសម្បទានទៅលើឥណទានដែលមានបញ្ហាឡើយ
- ការដកខ្លួនចេញពីទីផ្សារសកម្មដើម្បីការពារកុំឲ្យមានវិបត្តិហិរញ្ញវត្ថុ ឬ
- ការទិញទ្រព្យសកម្មហិរញ្ញវត្ថុក្នុងការបញ្ចុះតម្លៃយ៉ាងខ្លាំងដែលបណ្តាលមកពីការបាត់បង់ឥណទាន។

វាមិនអាចមានលទ្ធភាពដើម្បីកំណត់ព្រឹត្តិការណ៍ដាច់ពីគ្នាតែមួយទេ ផ្ទុយទៅវិញឥទ្ធិពលរួមគ្នានៃព្រឹត្តិការណ៍មួយចំនួនអាចបណ្តាលឲ្យទ្រព្យសកម្មហិរញ្ញវត្ថុក្លាយជាឥណទានអ៊ីមភែរមិន។ ធនាគារវាយតម្លៃថាតើ ឧបករណ៍បំណុលដែលជាទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងដោយការចំណាយរំលស់ឬ FVTOCI ដែលជាឥណទានតាមកាលបរិច្ឆេទរបាយការណ៍នីមួយៗ។ ដើម្បីវាយតម្លៃប្រសិនបើឧបករណ៍បំណុលរដ្ឋ និងបំណុលសាជីវកម្មថយចុះ ឥណទានធនាគារពិចារណាលើកត្តាដូចជាទិន្នផលសញ្ញាប័ណ្ណ អត្រាឥណទាន និងសមត្ថភាពរបស់អ្នកខ្ចីក្នុងការប្រមូលមូលនិធិ។

# ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)
## ៣.២. ឧបករណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)
### ៣.២.៧.ការខាតបង់ឥណទានរំពឹងទុក ("ECLs") (តពីទំព័រមុន)

#### ឥណទានអ៊ីមភែរមិននៃទ្រព្យសកម្មហិរញ្ញវត្ថុ (តពីទំព័រមុន)

ឥណទានត្រូវបានចាត់ទុកថា មានឥណទានអ៊ីមភែរមិន នៅពេលដែលសម្បទានត្រូវបានផ្តល់ដល់អ្នកខ្ចីដោយសារតែលក្ខណមានភាពខ្សោយក្នុងស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចី លុះត្រាតែមានភស្តុតាងបង្ហាញ ការផ្តល់សម្បទានហានិភ័យនៃការមិនទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យា បានថយចុះគួរឲ្យកត់សម្គាល់ និងមិនមានសូចនាករផ្សេងទៀត នៃអ៊ីមភែរមិន។ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ដែលសម្បទានត្រូវបានពិចារណា ប៉ុន្តែមិនបានផ្តល់ឲ្យទ្រព្យ នោះត្រូវបានគេចាត់ទុកថាមានឥណទានអ៊ីមភែរមិន នៅពេលមានភស្តុតាងដែលអាចមើលឃើញពីឥណទានអ៊ីមភែរមិនរួមទាំងការស្របតាមនិយមន័យនៃការគ្មានលទ្ធភាពសង។

និយមន័យនៃការការគ្មានលទ្ធភាពសង (សូមមើលខាងក្រោម) រួមបញ្ចូលទាំងសូចនាករនៃទំនោក្នុងការមិនសងត្រឡប់នូវប្រាក់ និងផ្នែកខាងក្រោយបើសិនជាទឹកប្រាក់នោះលើសការកំណត់ក្នុងរយៈពេល ៩០ ថ្ងៃ ឬ ច្រើនជាង។

#### និយមន័យនៃការគ្មានលទ្ធភាពសង

សារៈសំខាន់ចំពោះការកំណត់របស់ ECL គឺជានិយមន័យនៃការគ្មានលទ្ធភាពសង។ និយមន័យនៃការគ្មានលទ្ធភាពសងត្រូវបានប្រើក្នុងការវាស់បរិមាណ ECL និងក្នុងការកំណត់ ថាតើការខាតបង់លើសំវិធានធនអាស្រ័យលើអាយុកាល ១២ខែ ឬ ECL ពេលមួយអាយុកាល ព្រោះថាការគ្មានលទ្ធភាពសងគឺជាផ្នែកមួយនៃប្រូបាប៊ីលីតេលើលទ្ធភាព មិនអាចសង ("PD") ដែលបះពាល់ដល់ការវាស់វែងនៃ ECL និងការកំណត់អត្តសញ្ញាណ នៃការកើនឡើងគួរឲ្យកត់សំគាល់នៃហានិភ័យឥណទាន។

ធនាគារពិចារណានូវចំនុចខាងក្រោមនេះដែលធ្វើឲ្យមានការគ្មានលទ្ធភាពសងឡើង៖

- អ្នកខ្ចីដែលហួសកាលកំណត់សងលើសពី ៩០ ថ្ងៃលើកាតព្វកិច្ចឥណទានសំខាន់ណាមួយចំពោះធនាគារ។ ឬ
- អ្នកខ្ចីទំនងជាមិនបង់ ឬ បំពេញតាមកាតព្វកិច្ចឥណទានរបស់ខ្លួនចំពោះធនាគារឲ្យបានពេញលេញ។

និយមន័យនៃការគ្មានលទ្ធភាពសង ត្រូវបានប្រើប្រាស់ ដោយធនាគារ សម្រាប់គោលបំណងគណនេយ្យក៏ដូចជាសម្រាប់គោលបំណងគ្រប់គ្រងហានិភ័យឥណទានផ្ទៃក្នុង ក៏ដូចជាការតម្រូវឲ្យមាននៅក្នុងបទបញ្ញត្តិនៃការគ្មានលទ្ធភាពសង។ និយមន័យ នៃការគ្មានលទ្ធភាពសងត្រូវបានរៀបចំយ៉ាងសមស្របដើម្បីឆ្លុះបញ្ចាំងពីលក្ខណៈផ្សេងៗគ្នានៃប្រភេទទ្រព្យខុសៗគ្នា។ ឥណទានវិបារូប៍ត្រូវបានចាត់ទុកថាហួសកាលបរិច្ឆេទកំណត់នៅពេល អតិថិជនមិនគោរពតាមកម្រិតសាច់ប្រាក់ដែលបានកំណត់ ឬ ត្រូវបានកំណត់ឲ្យខ្ចីក្នុងកម្រិតតិចជាទឹកប្រាក់ដែលនៅសល់ក្នុងពេលបច្ចុប្បន្ន។

នៅពេលវាយតម្លៃថាតើអ្នកខ្ចីទំនងជាមិនបង់ ឬ បំពេញតាមកាតព្វកិច្ចឥណទានរបស់ខ្លួនទេ ធនាគារត្រូវគិតគូរទាំងសូចនាករគុណភាពនិងបរិមាណ។ ព័ត៌មានដែលបានវាយតម្លៃអាស្រ័យលើប្រភេទនៃទ្រព្យសម្បត្តិ ឧទាហរណ៍ក្នុងការផ្តល់ឥណទានរបស់ក្រុមហ៊ុន សូចនាករគុណភាពដែលត្រូវបានប្រើគឺនៅពេលមានការមិនគោរពលើកិច្ចព្រមព្រៀង ដែលមិនទាក់ទងនឹងការផ្តល់ឥណទាន។ សូចនាករបរិមាណដូចជាស្ថានភាពហួសកាលកំណត់ និងការមិនបង់ប្រាក់លើកាតព្វកិច្ចមួយទៀតនៃសមភាគីដូចគ្នា គឺជាធាតុចូលសំខាន់នៅក្នុងការវិភាគនេះ។ ធនាគារប្រើប្រាស់ប្រភពព័ត៌មានជាច្រើន ដើម្បីវាយតម្លៃពីភាពមិនប្រក្រតី ដែលត្រូវបានបង្កើតឡើងនៅខាងក្នុង ឬ ទទួលបានពីប្រភពខាងក្រៅ។ ដូចដែលបានកត់សម្គាល់នៅក្នុងនិយមន័យនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលថយចុះ ឥណទានបំណុល គឺជាភស្តុតាងដែលបង្ហាញថាទ្រព្យសកម្ម គឺជាការថយចុះឥណទាន។ ដូច្នេះទ្រព្យសកម្ម ដែលមានឥណទានអ៊ីមភែរមិននឹងរួមបញ្ចូលនូវទ្រព្យដែលមិនត្រូវបានសង ប៉ុន្តែក៏នឹងរួមបញ្ចូលនូវទ្រព្យមិនត្រូវបានសងផ្សេងទៀត ព្រោះថានិយមន័យនៃឥណទានអ៊ីមភែរមិនមានលក្ខណៈទូលំទូលាយជាងនិយមន័យ នៃការគ្មានលទ្ធភាពសង។

#### ការកើនឡើងហានិភ័យឥណទានគួរឲ្យកត់សម្គាល់

ធនាគារត្រួតពិនិត្យរាល់ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ រួមទាំងកិច្ចសន្យាឥណទានដែលបានផ្តល់ និងកិច្ចសន្យាធានារ៉ាប់រងហិរញ្ញវត្ថុ ដែលស្ថិតក្រោមតម្រូវការអ៊ីមភែរមិន ដើម្បីវាយតម្លៃថាតើហានិភ័យឥណទាន បានកើនឡើងគួរឲ្យកត់សម្គាល់ចាប់តាំងពីមានការទទួលស្គាល់ដំបូងដែរទេ។ ប្រសិនបើមានការកើនឡើងគួរឲ្យកត់សម្គាល់នៃហានិភ័យឥណទាន ធនាគារនឹងធ្វើការវាស់វែងលើការខាតបង់លើសំវិធានធន អាស្រ័យលើអាយុកាលជាជាង ECL រយៈពេល ១២ ខែ។ គោលនយោបាយគណនេយ្យរបស់ធនាគារមិនងាយស្រួលក្នុងការប្រើប្រាស់ជាក់ស្តែងទេ ដែលទ្រព្យសកម្មហិរញ្ញវត្ថុមានហានិភ័យ





# ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)
## ៣.២. ឧបករណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)
### ៣.២.៧.ការខាតបង់ឥណទានរំពឹងទុក ("ECLs") (តពីទំព័រមុន)

#### ការកើនឡើងហានិភ័យឥណទានគួរឲ្យកត់សម្គាល់ (តពីទំព័រមុន)

ឥណទានទាប នៅកាលបរិច្ឆេទរបាយការណ៍ត្រូវបានចាត់ទុកថាមិនមានហានិភ័យឥណទានកើនឡើងគួរឲ្យកត់សម្គាល់។ ជាលទ្ធផលធនាគារឃ្លាំមើល រាល់ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ រួមទាំងកិច្ចសន្យាឥណទានដែលបានផ្តល់ និងកិច្ចសន្យាធានារ៉ាប់រងហិរញ្ញវត្ថុដែលស្ថិតក្រោមអ៊ីមភែរមិនចំពោះការកើនឡើងគួរឲ្យកត់សម្គាល់នូវហានិភ័យឥណទាន។

ក្នុងការវាយតម្លៃថាមានឬទេនូវការកើនឡើងគួរឲ្យកត់សម្គាល់នៃហានិភ័យឥណទាន នៅលើឧបករណ៍ហិរញ្ញវត្ថុ ចាប់តាំងពីការទទួលស្គាល់ដំបូង ធនាគារប្រៀបធៀបហានិភ័យនៃការគ្មានលទ្ធភាពសង កើតលើឧបករណ៍ហិរញ្ញវត្ថុនៅកាលបរិច្ឆេទរបាយការណ៍ដោយផ្អែកលើកាលវសាន្ត ដែលនៅសល់នៃឧបករណ៍នាកាលបរិច្ឆេទរបាយការណ៍នៅពេល ដែលឧបករណ៍ហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ជាលើកដំបូង។ ក្នុងការធ្វើការវាយតម្លៃនេះធនាគារពិចារណា ទាំងព័ត៌មានបរិមាណនិងគុណភាពដែលសមហេតុផល និងអាចបញ្ជាក់បានក៏ដូចជាប្រវត្តិបទពិសោធន៍ និងព័ត៌មានមើលឆ្ពោះទៅមុខ ដែលអាចរកបានដោយមិនចាំបាច់ចំណាយ ឬ ការប្រឹងប្រែង ដោយផ្អែកលើបទពិសោធន៍ប្រវត្តិសាស្ត្ររបស់ធនាគារ និងការវាយតម្លៃឥណទានជំនាញរួមទាំងព័ត៌មានមើលឆ្ពោះទៅមុខ។

បែបបទសេដ្ឋកិច្ចជាច្រើនបង្កើតបានជាមូលដ្ឋាន នៃការកំណត់ប្រូបាប៊ីលីតេលើលទ្ធភាពមិនអាចសង នាពេលការទទួលស្គាល់លើកដំបូង និងនៅកាលបរិច្ឆេទរាយការណ៍ជាបន្តបន្ទាប់។ បែបបទសេដ្ឋកិច្ចខុសគ្នានឹងនាំឲ្យមានប្រូបាប៊ីលីតេលើលទ្ធភាពមិនអាចសងខុសគ្នា។ វាគឺជាការថ្លឹងថ្លែងពីស្ថានភាពផ្សេងៗគ្នាដែលបង្កើតជាមូលដ្ឋាននៃប្រូបាប៊ីលីតេលើលទ្ធភាពមិនអាចសងជាមធ្យម ដែលត្រូវបានប្រើដើម្បីកំណត់លើហានិភ័យឥណទានដែលនឹងអាចកើនឡើងគួរឲ្យកត់សម្គាល់ដែរឬទេ។

ចំពោះឥណទានរបស់ក្រុមហ៊ុន ព័ត៌មានត្រូវបានពិនិត្យមើលទៅអនាគត ដោយរួមបញ្ចូលទាំងស្ថាប័ននានា ដែលធនាគារមានដៃគូរពាណិជ្ជកម្មជាមួយ ការពិនិត្យនោះត្រូវរួមបញ្ចូលទាំងរបាយការណ៍ ដែលចេញដោយអ្នកជំនាញសេដ្ឋកិច្ច អ្នកវិភាគហិរញ្ញវត្ថុ អង្គភាពរដ្ឋាភិបាល អង្គភាពពាក់ព័ន្ធ និងអង្គភាពស្រដៀងគ្នាផ្សេងទៀត ក៏ដូចជាព័ត៌មានជាក់ស្តែងផ្សេងៗដែលបានមកពីស្ថានភាពសេដ្ឋកិច្ចទាំងក្នុងនិងក្រៅធនាគារ។

ចំពោះឥណទានរាយរាល់ព័ត៌មានផ្តល់ឥណទាន ឆ្ពោះទៅមុខរួមបញ្ចូលទាំងការព្យាករណ៍ សេដ្ឋកិច្ចដូចគ្នានឹងការផ្តល់ឥណទានក្រុមហ៊ុន និងការព្យាករណ៍បន្ថែមនៃសូចនាករសេដ្ឋកិច្ច ក្នុងស្រុកជាពិសេសសម្រាប់តំបន់ ដែលផ្តោតលើឧស្សាហកម្មជាក់លាក់ ក៏ដូចជាព័ត៌មានដែលបង្កើតនៅខាងក្នុង នៃឥរិយាបថទូទាត់ប្រាក់របស់អតិថិជន។ ធនាគារបែងចែកដៃគូរបស់ខ្លួនទៅថ្នាក់ ហានិភ័យឥណទានផ្ទៃក្នុង ដែលពាក់ព័ន្ធអាស្រ័យលើគុណភាពឥណទានរបស់ពួកគេ។ ព័ត៌មានអំពីបរិមាណគឺជាសូចនាករបឋម នៃការកើនឡើងគួរឲ្យកត់សម្គាល់ នៃហានិភ័យឥណទាន និងផ្អែកលើការប្រែប្រួលក្នុង PD ពេញមួយអាយុកាលដោយការប្រៀបធៀប៖

- អាយុកាលដែលនៅសល់ នៃ PD ពេញមួយអាយុកាលនៅកាលបរិច្ឆេទរាយការណ៍ ជាមួយ
- អាយុកាលដែលនៅសល់ នៃ PD ពេញមួយអាយុកាលសម្រាប់ចំណុចនេះនៅក្នុងពេលវេលាដែលត្រូវបានគេប៉ាន់ស្មាន ដោយផ្អែកលើអង្គហេតុនិងកាលៈទេសៈនៅពេល នៃការទទួលស្គាល់ដំបូងនៃការប៉ះពាល់។

PDs ដែលត្រូវបានប្រើគឺមានលក្ខណៈឆ្ពោះទៅមុខហើយធនាគារប្រើវិធីសាស្ត្រ និងទិន្នន័យដូចគ្នាដើម្បីវាស់សំវិធានធនបាត់បង់សម្រាប់ ECL។ កត្តាគុណភាពដែលបង្ហាញពីការកើនឡើងគួរឲ្យកត់សម្គាល់នៃហានិភ័យឥណទានត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគំរូ PD ឲ្យបានទាន់ពេលវេលា។ ទោះយ៉ាងណាក៏ដោយ ធនាគារនៅតែពិចារណាលើកត្តាគុណភាពមួយចំនួនដាច់ដោយឡែកដើម្បីវាយតម្លៃថាតើហានិភ័យឥណទានបានកើនឡើងគួរឲ្យកត់សម្គាល់ដែរឬទេ។ ចំពោះឥណទានរបស់ក្រុមហ៊ុនមានការផ្តោតជាពិសេសទៅលើទ្រព្យសកម្ម ដែលត្រូវបានបញ្ចូលក្នុង "បញ្ជីឃ្លាំមើល" ដោយចាត់ទុកថាមានហានិភ័យក្នុងបញ្ជីឃ្លាំមើល នៅពេលមានការព្រួយបារម្ភថាភាពគួរឲ្យទុកចិត្តរបស់សមភាគីជាក់លាក់បានចុះខ្សោយ។ សម្រាប់ការផ្តល់ឥណទានរាយ ធនាគារពិចារណាលើការរំពឹងទុកនៃការរង់ចាំ និងថ្ងៃឈប់សម្រាកក្នុងការទូទាត់ពិន្ទុឥណទាន និងព្រឹត្តិការណ៍ដូចជា ភាពមិនមានការងារធ្វើ ក្ស័យធន ការលែងលះ ឬការស្លាប់។

ដោយសារការកើនឡើងគួរឲ្យកត់សម្គាល់នូវហានិភ័យឥណទាន ចាប់តាំងពីការទទួលស្គាល់ដំបូង គឺជាវិធានសមាមាត្រការប្រែប្រួល ដែលបានកំណត់ជាតម្លៃដាច់ខាតនៅក្នុង PD នឹងកាន់តែមានសារៈសំខាន់សម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលមាន PD ដំបូងទាបជាងបើប្រៀបធៀបទៅនឹងឧបករណ៍ហិរញ្ញវត្ថុដែលមាន PD ខ្ពស់ជាងនេះ។

ដើម្បីទប់ស្កាត់ហានិភ័យឥណទានទាន់ពេល នៅពេលទ្រព្យសកម្មផុតកំណត់រយៈពេល ៣០ ថ្ងៃ ធនាគារពិចារណាថាការកើនឡើងនូវហានិភ័យឥណទានបានកើតឡើង ហើយទ្រព្យសកម្មស្ថិតក្នុងដំណាក់កាលទី ២ នៃគំរូអ៊ីមភែរមិន ពោលគឺសំវិធានធនខាតបង់ត្រូវបានវាស់វែងជា ECL ពេញមួយអាយុកាល។ លើសពីនេះទៀតឥណទានដែលត្រូវបានវាយតម្លៃជាលក្ខណៈបុគ្គលនិងត្រូវបានបញ្ចូលក្នុងបញ្ជីតាមដានគឺស្ថិតនៅ

# ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

## ៣.២. ឧបករណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

### ៣.២.៧.ការខាតបង់ឥណទានរំពឹងទុក ("ECLs") (តពីទំព័រមុន)

#### ការកើនឡើងហានិភ័យឥណទានគួរឲ្យកត់សម្គាល់ (តពីទំព័រមុន)

ក្នុងដំណាក់កាលទី ២ នៃគំរូអ៊ីមភែរមិន។ ដូចបានកត់សម្គាល់ប្រសិនបើមានភស្តុតាងបង្ហាញពីឥណទានអ៊ីមភែរមិន នោះទ្រព្យសកម្មទាំងនោះគឺស្ថិតក្នុងដំណាក់កាលទី ៣ នៃគំរូអ៊ីមភែរមិន។

#### ការលុបចោល

ឥណទាននិងមូលប័ត្របំណុល ត្រូវបានលុបចោលនៅពេលដែលធនាគារមិនមានការរំពឹងទុកក្នុងការប្រមូលមកវិញនូវទ្រព្យសម្បត្តិហិរញ្ញវត្ថុ (ទាំងមូលឬផ្នែកខ្លះនៃឥណទាន)។ ករណីនេះកើតឡើងពេលដែលធនាគារកំណត់ថា អ្នកខ្ចីមិនមានទ្រព្យសកម្ម ឬប្រភពចំណូលដែលអាចបង្កើតលំហូរសាច់ប្រាក់គ្រប់គ្រាន់ក្នុងការសងចំនួនទឹកប្រាក់ដែលត្រូវលុបចោល។ ការលុបចោលបំណុលបង្កើតបានជាព្រឹត្តិការណ៍ឈប់ទទួលស្គាល់។ ធនាគារអាចអនុវត្តសកម្មភាពតាមច្បាប់ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលបានលុបចោល។ ការប្រមូលប្រាក់បានវិញ ពីសកម្មភាពនៃការអនុវត្តសកម្មភាពតាមច្បាប់របស់ធនាគារ នឹងបណ្តាលឲ្យមានការចំណេញលើអ៊ីមភែរមិន ដែលនឹងត្រូវបានបង្ហាញជា "ខាតលើអ៊ីមភែរមិនសុទ្ធ លើទ្រព្យសកម្មហិរញ្ញវត្ថុ ឬ ចំណេញនានា" ក្នុងរបាយការណ៍ចំណេញ ឬ ខាត។

#### បទបង្ហាញនៃសំវិធានធនសម្រាប់ ECL នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

ខាតលើសំវិធានធនសម្រាប់ ECL ដែលបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដូចខាងក្រោម៖

- សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់តាមតម្លៃរំលស់៖ ជាការកាត់បន្ថយពីតម្លៃយោងសរុបនៃទ្រព្យសកម្ម
- សម្រាប់កិច្ចសន្យាឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុ ចាត់ទុកជាសំវិធានធន និង
- នៅពេលដែលឧបករណ៍ហិរញ្ញវត្ថុរួមបញ្ចូលទាំងសាច់ប្រាក់ដែលត្រូវបានទម្លាក់ និងពុំទាន់ទម្លាក់ចេញ និងធនាគារមិនអាចកំណត់បានលើ ECL ចំពោះកិច្ចសន្យាឥណទានពុំទាន់ទម្លាក់ ដោយឡែកពីសាច់ប្រាក់ដែលទម្លាក់ហើយនោះ ធនាគារនឹងបង្ហាញជារួមលើការខាតបង់សំវិធានធនសម្រាប់សមាសធាតុទាំងពីរ។ ចំនួនទឹកប្រាក់រួមគ្នា ត្រូវបានបង្ហាញជាការកាត់ចេញពីតម្លៃយោងដុលនៃសាច់ប្រាក់ដែលបានទម្លាក់។ រាល់ការខាតបង់សំវិធានធនដែលលើសពីចំនួនសរុបនៃសាច់ប្រាក់ ដែលបានទម្លាក់នៃតម្លៃយោងដុលនឹងត្រូវបានបង្ហាញជាសំវិធានធន។

### ៣.២.៨.ទ្រព្យអសកម្មហិរញ្ញវត្ថុ និងមូលធន

ឧបករណ៍បំណុលនិងមូលធន ដែលត្រូវបានបោះផ្សាយ ត្រូវបានធ្វើចំណាត់ថ្នាក់ជាទ្រព្យអសកម្មហិរញ្ញវត្ថុ ឬ មូលធនស្របតាមខ្លឹមសារនៃការរៀបចំកិច្ចសន្យា។

ទ្រព្យអសកម្មហិរញ្ញវត្ថុ គឺជាកាតព្វកិច្ចតាមកិច្ចសន្យាក្នុងការប្រគល់សាច់ប្រាក់ ឬ ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត ឬ ដើម្បីប្តូរទ្រព្យសកម្ម ឬ អសកម្មហិរញ្ញវត្ថុ ជាមួយគ្រឹះស្ថានផ្សេងទៀតដែលស្ថិតក្រោមលក្ខខណ្ឌ ដែលអាចនឹងមិនមានអំណោយផលដល់ធនាគារ ឬ កិច្ចសន្យាដែលនឹង ឬ អាចត្រូវបានទូទាត់ជាមួយនឹងឧបករណ៍មូលធនផ្ទាល់របស់ធនាគារ គឺជាកិច្ចសន្យាដែលពុំមែនជានិស្សន្ទវត្ថុ ដែលធនាគារមានឬអាចមានកាតព្វកិច្ច ផ្តល់នូវចំនួនអថេរនៃឧបករណ៍មូលធនផ្ទាល់ខ្លួន ឬ កិច្ចសន្យានិស្សន្ទវត្ថុ លើមូលធនផ្ទាល់ដែលត្រូវបានទូទាត់ក្រៅពីការដោះដូរចំនួនទឹកប្រាក់ថេរ (ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត) ជាមួយនឹងឧបករណ៍ថេរមូលធនមួយចំនួនរបស់ធនាគារ។

ឧបករណ៍មូលធន គឺជាកិច្ចសន្យាទាំងឡាយណាដែលផ្តល់ជាភស្តុតាងនូវតម្លៃសេសសល់លើ ទ្រព្យសកម្មរបស់ក្រុមហ៊ុនបន្ទាប់ពីកាត់បំណុលទាំងអស់របស់ខ្លួន។

ឧបករណ៍មូលធនដែលបោះផ្សាយ ដោយធនាគារត្រូវបានទទួលស្គាល់តាមចំណូល ដែលទទួលបានសុទ្ធនៃថ្លៃដើមផ្ទាល់។ ការទិញមកវិញនូវឧបករណ៍មូនធនផ្ទាល់របស់ធនាគារត្រូវបានទទួលស្គាល់និងកាត់ដោយផ្ទាល់ក្នុងមូលធន។ មិនមានចំណេញ ឬ ខាតត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬ ខាត លើការទិញលក់ បោះផ្សាយ ឬ ការបដិសេធន៍ លើឧបករណ៍មូលធនផ្ទាល់របស់ធនាគារនោះទេ។





# ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

## ៣.២. ឧបករណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

### ៣.២.៨.ទ្រព្យអសកម្មហិរញ្ញវត្ថុ និងមូលធន (តពីទំព័រមុន)

#### ទ្រព្យអសកម្មហិរញ្ញវត្ថុផ្សេងៗ

ទ្រព្យអសកម្មហិរញ្ញវត្ថុផ្សេងៗ រួមទាំងឥណទាន ត្រូវបានវាស់វែងដំបូងដោយតម្លៃជាក់ស្តែងសុទ្ធនៃថ្លៃដើមប្រតិបត្តិការ។ ទ្រព្យអសកម្មហិរញ្ញវត្ថុនានា ត្រូវបានវាស់វែងជាបន្តបន្ទាប់ដោយចំណាយរំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

#### អត្រាការប្រាក់ប្រសិទ្ធភាព

វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព (EIR) គឺជាវិធីសាស្ត្រមួយនៃការគណនាចំណាយរំលស់នៃ ទ្រព្យអសកម្មហិរញ្ញវត្ថុ និងការបែងចែកចំណាយការប្រាក់ក្នុងរយៈពេលដែលពាក់ព័ន្ធ។ EIR គឺជាអត្រាមួយដែលមានការបញ្ចុះតម្លៃជាក់ស្តែង លើសាច់ប្រាក់ទូទាត់ប៉ាន់ស្មាននាពេលអនាគត តាមរយៈអាយុកាលរំពឹងទុកនៃទ្រព្យអសកម្មហិរញ្ញវត្ថុ ឬ ក្នុងករណីដែលសមស្រប ទៅនឹងរយៈពេលខ្លីនៃតម្លៃយោងសុទ្ធ លើការទទួលស្គាល់ដំបូង។ សម្រាប់ព័ត៌មានលម្អិតអំពី EIR សូមមើល ផ្នែក"ចំណូលការប្រាក់សុទ្ធ" ខាងក្រោម។

#### ចំណេញ និងខាតលើការប្តូររូបិយប័ណ្ណបរទេស

សម្រាប់ទ្រព្យអសកម្មហិរញ្ញវត្ថុ ដែលគិតជារូបិយប័ណ្ណបរទេស និងត្រូវបានវាស់វែងតាមតម្លៃរំលស់នៅ ការិយបច្ឆេទបញ្ចប់នៃរបាយការណ៍ ហើយចំណេញនិងខាតលើអត្រាប្តូរប្រាក់បរទេស ត្រូវបានកំណត់ដោយផ្អែកលើការធ្វើរំលស់ថ្លៃដើមនៃឧបករណ៍នោះ ការចំណេញនិងការខាតបង់លើអត្រាប្តូរប្រាក់បរទេសរបស់វាត្រូវបានទទួលស្គាល់នៅក្នុងជួរ "ចំណូលសរុបផ្សេងៗ" ក្នុងរបាយការណ៍ចំណេញ ឬ ខាត នៃទ្រព្យអសកម្មហិរញ្ញវត្ថុដែលមិនមែនជាផ្នែកនៃទំនាក់ទំនងដែលបានកំណត់អត្រាប្តូរប្រាក់។ ចំណែកឯទ្រព្យអសកម្មហិរញ្ញវត្ថុដែលជាផ្នែកនៃឧបករណ៍កំណត់អត្រាប្តូរប្រាក់ សម្រាប់ការកំណត់អត្រាប្តូរប្រាក់លើហានិភ័យរូបិយប័ណ្ណបរទេសនោះ ចំណេញនិងខាតនៃការប្តូរប្រាក់បរទេសត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬ ខាត និងចំណូលសរុបផ្សេងៗ និងត្រូវបានបង្គរនៅក្នុងសមាសធាតុដាច់ដោយឡែកនៃមូលធន។

តម្លាភាពនៃទ្រព្យអសកម្មហិរញ្ញវត្ថុដែលគិតជារូបិយប័ណ្ណបរទេស ត្រូវបានកំណត់ជារូបិយប័ណ្ណបរទេសនោះ ហើយត្រូវបានធ្វើការប្តូរតាមអត្រានៅកាលបរិច្ឆេទបញ្ចប់នៃរបាយការណ៍។ ចំពោះទ្រព្យអសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាម FVTPL សមាសភាគប្តូរប្រាក់បរទេស បង្កើតបានជាចំណែកមួយនៃការចំណេញឬខាតតម្លៃជាក់ស្តែង ហើយត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬ ខាត សម្រាប់ទ្រព្យអសកម្មហិរញ្ញវត្ថុដែលមិនមែនជាផ្នែកនៃទំនាក់ទំនងការពារហានិភ័យដែលធ្វើការកំណត់លើអត្រាប្តូរប្រាក់។

#### ការកែប្រែនិងការឈប់ទទួលស្គាល់ទ្រព្យអសកម្មហិរញ្ញវត្ថុ

ធនាគារឈប់ទទួលស្គាល់ ទ្រព្យអសកម្មហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌរបស់វា ត្រូវបានកែប្រែហើយលំហូរសាច់ប្រាក់នៃបំណុលដែលបានកែប្រែនោះមានភាពខុសគ្នាខ្លាំង។ ក្នុងករណីនេះហិរញ្ញវត្ថុថ្មី ដែលបានកែប្រែត្រូវបានទទួលស្គាល់តាមតម្លៃទីផ្សារ។ ភាពខុសគ្នារវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដែលបានទទួលស្គាល់ និងការពិចារណាបង់ត្រូវបានទទួលស្គាល់លើរបាយការណ៍ចំណេញ ឬ ខាតលទ្ធផល។ ការពិចារណាលើការបង់រួមបញ្ចូលទាំងទ្រព្យសកម្មដែលមិនមែនជាហិរញ្ញវត្ថុដែលបានផ្ទេរប្រសិនបើមាន និងការសន្មតនៃបំណុលរួមទាំងទ្រព្យអសកម្មហិរញ្ញវត្ថុដែលបានកែប្រែថ្មី។

ប្រសិនបើការកែប្រែទ្រព្យអសកម្មហិរញ្ញវត្ថុ មិនត្រូវបានកត់ត្រានោះទេ ការចំណាយរំលស់បំណុលត្រូវបានគណនាឡើងវិញដោយបញ្ចុះអត្រាការប្រាក់ប្រសិទ្ធភាព ហើយចំណេញ ឬ ខាតនៅក្នុងការបញ្ចុះនេះ នឹងត្រូវដាក់ចូលទៅក្នុងរបាយការណ៍ចំណេញ ឬ ខាតលទ្ធផល។ ចំពោះទ្រព្យអសកម្មហិរញ្ញវត្ថុអត្រាអណ្តែត អត្រាការប្រាក់មានប្រសិទ្ធភាពដើមដែលត្រូវបានប្រើដើម្បីគណនាចំណេញ ឬ ខាតត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន។ ថ្លៃដើមនិងកម្រៃសេវា ត្រូវបានទទួលស្គាល់ជាការកែតម្រូវ ដូច្នេះធនាគារនឹងទទួលបានតម្លៃយោងមួយនៃបំណុល ដែលនឹងត្រូវបានធ្វើរំលស់រហូតដល់គ្រាចុងក្រោយ ហើយតម្លៃយោងនោះនឹងត្រូវគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព។

# ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

## ៣.៣. ទ្រព្យ និងបរិក្ខារ

ផ្នែក នៃទ្រព្យ និងបរិក្ខារត្រូវបានកត់ត្រាតាមតម្លៃដើមដករំលស់បង្គរ និងការខាតបង់លើឱនភាពតម្លៃបង្គរប្រសិនបើមាន។ នៅពេលដែលធាតុនៃទ្រព្យ និងបរិក្ខារមានអាយុកាលប្រើប្រាស់ខុសៗគ្នា ធាតុទាំងនោះត្រូវបានចាត់ទុកជាផ្នែកផ្សេងគ្នារបស់ទ្រព្យ និងបរិក្ខារ។

ចំណេញ ឬ ខាតនៃការលក់ចេញផ្នែកនៃទ្រព្យ និងបរិក្ខារណាមួយត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬ ខាត។

រំលស់ ត្រូវបានគណនាដើម្បីលុបចោលថ្លៃដើមនៃទ្រព្យ និងបរិក្ខារ ដកចេញនូវតម្លៃនៅសល់ ដោយប្រើវិធីសាស្ត្ររំលស់ថេរទៅតាមអាយុកាល ប្រើប្រាស់ប៉ាន់ស្មាន និងត្រូវទទួលស្គាល់ជាចំណេញ ឬ ខាត នៅក្នុងរបាយការណ៍ចំណេញ ឬ ខាត។

| | ចំនួនឆ្នាំនៃអាយុកាលប្រើប្រាស់ |
|---|---|
| ការជួសជុលកែលំអ | ៥ ឆ្នាំ |
| គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ | ៥ ឆ្នាំ |
| បរិក្ខារ | ៥ ឆ្នាំ |
| បរិក្ខារព័ត៌មានវិទ្យា | ៥ ឆ្នាំ |
| យានយន្ត | ៤-៥ ឆ្នាំ |

វិធីសាស្ត្ររំលស់អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ ត្រូវបានពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ ហើយត្រូវកែសម្រួលប្រសិនបើសមស្រប ។

បរិក្ខារកំពុងសាងសង់ មិនត្រូវបានរំលស់នោះទេ លុះត្រាតែបរិក្ខារទាំងនោះ ត្រូវបានរៀបចំរួចរាល់សម្រាប់ការប្រើប្រាស់ ដូចដែលបានសម្រេចដោយគណៈគ្រប់គ្រង។

ការចំណាយបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃទ្រព្យ និងបរិក្ខារដែលបានទទួលស្គាល់រួចមក ហើយត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ធនាគារលើសពីស្តង់ដារដើម។ រាល់ការចំណាយបន្ទាប់ផ្សេងទៀត ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង។

ការចំណេញ ឬ ខាត លើការលុបចោលទ្រព្យ និងបរិក្ខារមួយ ត្រូវកំណត់បាន ដោយប្រៀបធៀបសាច់ប្រាក់ទទួលបានពីការលក់បរិក្ខារ និងចំនួននៅសល់របស់ទ្រព្យ និងបរិក្ខារនោះ នឹងត្រូវបានទទួលស្គាល់ជាចំនួនសុទ្ធ នៅក្នុងចំណេញផ្សេងៗ នៅក្នុងរបាយការណ៍ចំណេញ ឬ ខាត។

ទ្រព្យ និងបរិក្ខារដែលបានរំលស់អស់ត្រូវបានរក្សាទុកនៅក្នុងរបាយការណ៍តុល្យការ រហូតដល់ពេលដែលវាត្រូវបានកំទេចចោល ឬ ឈប់ទទួលស្គាល់។

## ៣.៤. សូហ្វវែរ

ទ្រព្យសកម្មអរូបី ដែលរួមមានកុំព្យូទ័រសូហ្វវែរដែលបានទិញ និងចំណាយពាក់ព័ន្ធផ្សេងៗ ត្រូវបានរាយការណ៍តាមថ្លៃដើមដករំលស់បង្គរ និងការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ប្រសិនបើមាន។ រំលស់ត្រូវបានទទួលស្គាល់ជាចំណាយក្នុងរបាយការណ៍ចំណេញ ឬ ខាតផ្អែកតាមមូលដ្ឋានរំលស់ថេរនៅអត្រា ២០% ប្រចាំឆ្នាំ។ ប្រសិនបើមានការបញ្ជាក់ណាមួយដែលបង្ហាញថាមានការផ្លាស់ប្តូរអត្រារំលស់ ឬ អាយុកាលប្រើប្រាស់នៃទ្រព្យសកម្មអរូបី ការរំលស់នឹងត្រូវបានធ្វើឡើងវិញ ដើម្បីស្របតាមអត្រារំលស់ថ្មី។

សូហ្វវែរកំពុងដំឡើង មិនត្រូវបានរំលស់នោះទេ លុះត្រាតែសូហ្វវែរទាំងនោះ ត្រូវបានរៀបចំរួចរាល់សម្រាប់ការប្រើប្រាស់ ដូចដែលបានសម្រេចដោយគណៈគ្រប់គ្រង។

## ៣.៥. ភតិសន្យា

ធនាគារ វិនិច្ឆ័យថា កិច្ចសន្យាមួយ ជាភតិសន្យាឬទេ គឺនាពេលចាប់ផ្តើមកិច្ចសន្យា។

ធនាគារទទួលស្គាល់សិទ្ធិប្រើប្រាស់លើទ្រព្យសកម្មមួយ និងទ្រព្យអសកម្មភតិសន្យាដែលពាក់ព័ន្ធ ទៅតាមកិច្ចព្រមព្រៀងភតិសន្យាទាំងអស់ដែលខ្លួន ជាអ្នកជួល លើកលែងតែការជួលទ្រព្យសកម្មដែលមានតម្លៃទាប។ ចំពោះការជួលទាំងនោះ ធនាគារទទួលស្គាល់ការទូទាត់ភតិសន្យា ជាការចំណាយប្រតិបត្តិការដោយឈរលើមូលដ្ឋានគ្រឹះទៅតាមរយៈពេលកិច្ចសន្យា។





# ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

## ៣.៥. ភតិសន្យា (តពីទំព័រមុន)

### សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម

សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម គឺរួមបញ្ចូលនូវការវាស់វែងជាដំបូង នៃទ្រព្យអសកម្មភតិសន្យា ពាក់ព័ន្ធការទូទាត់ភតិសន្យាធ្វើឡើងនៅ ឬ មុនថ្ងៃចាប់ផ្តើម និងថ្លៃដើមដំបូងទាក់ទងបើមាន។ បន្ទាប់មកត្រូវបានវាស់វែងតាមតម្លៃដើម ដកបង្គររំលស់ និងឱនភាពតម្លៃលើការខាតបង់។

សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម ត្រូវរំលស់ទៅតាមរយៈពេលខ្លីជាងណាមួយ រវាងរយៈពេលជួលនិងអាយុកាលមានប្រយោជន៍នៃទ្រព្យសកម្មនោះ។ ការរំលស់ ត្រូវចាប់ផ្តើមពីកាលបរិច្ឆេទចាប់ផ្តើមនៃការជួល។

សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម ត្រូវបានបង្ហាញជា ដាច់ដោយឡែកនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### ទ្រព្យអសកម្មភតិសន្យា

ទ្រព្យអសកម្មភតិសន្យា ត្រូវបានវាស់ដំបូងតាមតម្លៃបច្ចុប្បន្ន នៃការទូទាត់ថ្លៃឈ្នួលដែលពុំទាន់បង់ គិតត្រឹមកាលបរិច្ឆេទចាប់ផ្តើមនៃការជួលដែលបញ្ចុះតម្លៃប្រើប្រាស់អត្រាកំណើនឥណទាន ដែលជាការប្រាក់ដែលធនាគារត្រូវបង់ដើម្បីខ្ចី ក្នុងរយៈពេលស្រដៀងគ្នា ជាមួយនឹងទ្រព្យបញ្ចាំស្រដៀងគ្នាដែលចាំបាច់ដើម្បីទទួលបានទ្រព្យសកម្មមួយ ដែលមានតម្លៃប្រហាក់ប្រហែលនឹងសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ក្នុងបរិយាកាសសេដ្ឋកិច្ចស្រដៀងគ្នា។

ការទូទាត់ភតិសន្យាដែលរួមបញ្ចូល ការវាស់វែងនៃទ្រព្យអសកម្មភតិសន្យាមានដូចជា៖

- ការទូទាត់ថ្លៃជួលថេរ ដកចេញនូវផលប្រយោជន៍ពីភតិសន្យា
- ប្រាក់ពិន័យសម្រាប់ការបញ្ចប់កិច្ចសន្យាជួលប្រសិនបើការកំណត់រយៈពេលជួលបានឆ្លុះបញ្ចាំងពីការអនុវត្តជម្រើសដើម្បីបញ្ចប់កិច្ចសន្យាជួល។

ទ្រព្យអសកម្មភតិសន្យាត្រូវបានបង្ហាញដាច់ដោយឡែកនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

បន្ទាប់មកទ្រព្យអសកម្មភតិសន្យាត្រូវបានវាស់វែង ដោយបង្កើនតម្លៃរបស់វាទៅតាមការប្រាក់លើទ្រព្យអសកម្មភតិសន្យា (ដោយប្រើវិធីរំលស់ការប្រាក់ប្រសិទ្ធភាព) និងដោយកាត់បន្ថយចំនួនតម្លៃរបស់វា ទៅតាមសាច់ប្រាក់ទូទាត់នៃភតិសន្យា។

ធនាគារនឹងធ្វើការវាស់វែងជាថ្មីលើទ្រព្យអសកម្មភតិសន្យា (និងធ្វើការកែសម្រួល ដែលពាក់ព័ន្ធនឹងសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម) នៅពេលដែល៖

- រយៈពេលនៃការជួលមានការផ្លាស់ប្តូរ ដែលករណីនេះ ទ្រព្យអសកម្មភតិសន្យានឹងត្រូវវាស់វែងជាថ្មីដោយប្រើប្រាស់ការទូទាត់ថ្មី និងអត្រាបញ្ចុះតម្លៃថ្មី។
- កិច្ចសន្យាភតិសន្យាបានកែប្រែ និងការកែប្រែនៃភតិសន្យានោះមិនទទួលស្គាល់ជាភតិសន្យាដោយឡែក ដែលករណីនេះ ទ្រព្យអសកម្មភតិសន្យានឹងត្រូវវាស់វែងជាថ្មី ដោយប្រើប្រាស់ការទូទាត់ថ្មី និងអត្រាបញ្ចុះតម្លៃថ្មី។

### ភតិសន្យារយៈពេលខ្លី និងភតិសន្យានៃទ្រព្យសកម្មដែលមានតម្លៃទាប

ធនាគារអនុវត្តការលើកលែងលើការទទួលស្គាល់កិច្ចសន្យាជួលរយៈពេលខ្លី ចំពោះការជួលឧបករណ៍ការិយាល័យរយៈពេលខ្លី (ឧទាហរណ៍៖ ការជួលដែលមានរយៈពេល ១២ខែ ឬ តិចជាងគិតចាប់ពីថ្ងៃចាប់ផ្តើម និងមិនមានជម្រើសទិញ)។ ធនាគារក៏អនុវត្ត ការលើកលែងការទទួលស្គាល់ការជួលទ្រព្យសកម្មដែលមានតម្លៃទាប ចំពោះការជួលឧបករណ៍ការិយាល័យដែលត្រូវបានចាត់ទុកថាមានតម្លៃទាប។ ការទូទាត់ប្រាក់នៃការជួលយៈពេលខ្លីនិងការជួលទ្រព្យសកម្មដែលមានតម្លៃទាប ត្រូវបានទទួលស្គាល់ថាជាការចំណាយផ្អែកលើមូលដ្ឋានគ្រឹះត្រង់តាមរយៈពេលជួល។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

## ៣.៦. ឱនភាពនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្ម មិនមែនហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាណណាមួយដែលបង្ហាញថា ទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង ការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលបានវិញរបស់ទ្រព្យសកម្មនឹងត្រូវបានធ្វើឡើង។

តម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ឬ ឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាង តម្លៃប្រើប្រាស់ និងតម្លៃទីផ្សារដកចំណាយដើម្បីលក់ចេញ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់ លំហូរទឹកប្រាក់រំពឹងថានឹងទទួលបាននាពេលអនាគត ត្រូវបានអប្បហារដោយប្រើអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងទីផ្សារបច្ចុប្បន្នលើតម្លៃពេលវេលានៃសាច់ប្រាក់ និងហានិភ័យជាក់លាក់ សម្រាប់ទ្រព្យសកម្មទាំងនោះ។ សម្រាប់គោលបំណងនៃការត្រួតពិនិត្យលើ ឱនភាពនៃតម្លៃទ្រព្យសកម្ម ត្រូវបានដាក់បញ្ចូលគ្នាជាក្រុមដែលអាចបង្កើតសាច់ប្រាក់បានតូចបំផុតពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃទ្រព្យសកម្មដទៃទៀត ឬ ក្រុមទ្រព្យសកម្មដទៃទៀតហៅកាត់ថា (“ឯកតា បង្កើតសាច់ប្រាក់”)។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្មមួយ ឬឯកតា បង្កើតសាច់ប្រាក់មានចំនួនលើសពីតម្លៃដែលអាចប្រមូលមកបានវិញ។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬ ខាត។

## ៣.៧. អត្ថប្រយោជន៍និយោជិត

### អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី

អត្ថប្រយោជន៍របស់និយោជិតរយៈពេលខ្លី ត្រូវបានកត់ត្រាជាចំណាយនៅពេលសេវាកម្ម បានផ្ដល់ដោយ និយោជិតដល់ធនាគាររួចហើយ។

### អត្ថប្រយោជន៍និយោជិតរយៈពេលវែង

កាតព្វកិច្ចរបស់ធនាគារ ទាក់ទងនឹងអត្ថប្រយោជន៍រយៈពេលវែងរបស់និយោជិក គឺចំនួនទឹកប្រាក់នៃអត្ថប្រយោជន៍ដែលនិយោជិតទទួលបានពីការផ្តល់សេវាកម្មរបស់ខ្លួន ក្នុងអំឡុងពេលបច្ចុប្បន្ន និងរយៈពេលមុនៗ។ អត្ថប្រយោជន៍នេះ ត្រូវបានធ្វើអប្បហារដើម្បីកំណត់តម្លៃបច្ចុប្បន្ន។ ការវាស់វែងឡើងវិញ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត ក្នុងអំឡុងពេលដែលបានកើតឡើង។

## ៣.៨. សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬ កាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយមានលទ្ធភាពដែលតម្រូវឲ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈសារវន្តសំវិធានធនត្រូវបានកំណត់ដោយការបញ្ចុះតម្លៃលំហូរទឹកប្រាក់ដែលរំពឹងថានឹងទទួលបាននាពេលអនាគតតាមអត្រាមុនបង់ពន្ធព្រោះវាឆ្លុះបញ្ចាំងពីការប៉ាន់ស្មានទីផ្សាបច្ចុប្បន្ន នៃតម្លៃពេលវេលានៃប្រាក់កាស និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។

## ៣.៩. វិធីរំលស់អត្រាការប្រាក់ប្រសិទ្ធភាព

វិធីរំលស់អត្រាការប្រាក់ប្រសិទ្ធភាព គឺជាអត្រាមួយដែលបញ្ចុះតម្លៃយ៉ាងជាក់លាក់លើប៉ាន់ស្មានលំហូរសាច់ប្រាក់នឹងទូទាត់ ឬ នឹងទទួលបាននាពេលអនាគត ពីអាយុកាលរំពឹងទុក នៃទ្រព្យសកម្ម ឬ ទ្រព្យអសកម្មហិរញ្ញវត្ថុ ទៅតម្លៃយោងដុលសរុបនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ ទៅតម្លៃរំលស់ នៃទ្រព្យអសកម្មហិរញ្ញវត្ថុ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព ធនាគារ ប៉ាន់ស្មានទុក លើលំហូរសាច់ប្រាក់ដោយ ពិចារណា លើរយៈពេលនៃកិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនបានគិតទៅលើការខាតបង់លើឥណទានរំពឹងទុកនោះទេ។ ការគណនាត្រូវរួមបញ្ចូលទាំងអស់នូវកម្រៃ និងចំនួនបានបង់ និងទទួលបានរវាងភាគីសងខាង ទៅតាមកិច្ចសន្យា ដែលជាផ្នែករួម នៃអត្រាការប្រាក់ប្រសិទ្ធភាព កម្រៃប្រតិបត្តិការ និងការបង់បុព្វលាភ ឬ ការបញ្ចុះតម្លៃផ្សេងៗទៀត។

កម្រៃប្រតិបត្តិការ គឺជាកម្រៃកំណើន ដែលបង្កឡើងដោយផ្ទាល់ចំពោះការទិញយក បោះផ្សាយឬការបោះចោលទ្រព្យសកម្មហិរញ្ញវត្ថុ ឬ ទ្រព្យអសកម្មហិរញ្ញវត្ថុ។ កម្រៃកំណើនគឺជាកម្រៃមួយ ដែលនឹងមិនត្រូវបានកើតឡើង ប្រសិនបើអង្គភាពមិនបានទិញយក បោះផ្សាយ ឬ បោះចោលឧបករណ៍ហិរញ្ញវត្ថុ។





## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

## ៣.៩. វិធីរំលស់អត្រាការប្រាក់ប្រសិទ្ធភាព (តពីទំព័រមុន)

### ៣.៩.១. ចំណូលការប្រាក់

ចំណូលការប្រាក់ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬ ខាត ដោយប្រើវិធីរំលស់ការប្រាក់ប្រសិទ្ធភាព។ វាត្រូវបានគណនាប្រើប្រាស់អត្រាការប្រាក់ប្រសិទ្ធភាព ទៅតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុលើកលែងតែ៖

- ទ្រព្យសកម្មហិរញ្ញវត្ថុទិញមក ឬ មានស្រាប់ ដែលមានឱនភាពឥណទាន។ អត្រាការប្រាក់ប្រសិទ្ធភាព ដែលបានកែតម្រូវលើឥណទាននឹងត្រូវយកមកប្រើប្រាស់ ទៅលើតម្លៃរំលស់ដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុ។
- ទ្រព្យសកម្មហិរញ្ញវត្ថុមិនបានទិញមក ឬ មិនមានស្រាប់ដែលមានឱនភាពឥណទាន ប៉ុន្តែក្រោយមកត្រូវបានក្លាយជាទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាព។ អត្រាការប្រាក់ប្រសិទ្ធភាពនាការិយបរិច្ឆេទបន្ទាប់ នឹងត្រូវយកមកប្រើប្រាស់ទៅលើតម្លៃរំលស់ដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

អត្រាការប្រាក់ប្រសិទ្ធភាពដែលបានកែតម្រូវលើឥណទាន គឺជាអត្រាមួយដែលបញ្ចុះតម្លៃយ៉ាងជាក់លាក់លើប៉ាន់ស្មានលំហូរសាច់ប្រាក់នឹងទូទាត់ ឬនឹងទទួលបាននាពេលអនាគត ពីអាយុកាលរំពឹងទុកនៃទ្រព្យសកម្ម ឬទ្រព្យអសកម្មហិរញ្ញវត្ថុទៅតាមតម្លៃរំលស់នៃទ្រព្យអសកម្មហិរញ្ញវត្ថុ ដែលជាទ្រព្យសកម្មហិរញ្ញវត្ថុទិញមកឬមានស្រាប់ ដែលមានឱនភាពឥណទាន។

ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើវិធីរំលស់អត្រាការប្រាក់ប្រសិទ្ធភាព ដែលបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬ ខាត និងចំណូលសរុបផ្សេងៗ បានរួមបញ្ចូលផងដែរលើការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងដោយតម្លៃរំលស់។

### ៣.៩.២.ចំណាយការប្រាក់

ចំណាយការប្រាក់ក៏ត្រូវបានគណនាដោយប្រើវិធីរំលស់អត្រាការប្រាក់ប្រសិទ្ធភាព សម្រាប់ទ្រព្យអសកម្មហិរញ្ញវត្ថុ ដែលបានរក្សាទុកនៅតម្លៃរំលស់។ ចំណាយការប្រាក់ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងចំណូលសរុបផ្សេងៗ បានរួមបញ្ចូលផងដែរលើទ្រព្យអសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងដោយតម្លៃរំលស់។

## ៣.១០. កម្រៃ និងចំណូលផ្សេងៗ

កម្រៃ និង ចំណូលផ្សេងៗ ត្រូវទទួលស្គាល់ជា សេវាកម្មពាក់ព័ន្ធ ដែលបានផ្តត់ផ្គង់។

កិច្ចសន្យាជាមួយអតិថិជន ដែលធ្វើឲ្យមានការទទួលស្គាល់លើឧបករណ៍ហិរញ្ញវត្ថុ នៅក្នុងធនាគារ និងក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អាចនឹងនៅក្នុងវិសាលនុភាពខ្លះរបស់ CIFRS ៩ និងវិសាលនុភាពខ្លះរបស់ CIFRS ១៥។ ប្រសិនបើមានករណីនេះដំបូង ធនាគារនឹងអនុវត្តតាម CIFRS ៩ ដើម្បីបំបែក និងវាស់វែង ផ្នែកនៃកិច្ចសន្យា ដែលនៅក្នុងវិសាលនុភាព នៃ CIFRS ៩ និងបន្ទាប់មក អនុវត្តតាម CIFRS ១៥ ទៅលើផ្នែកនៅសល់។

## ៣.១១. ពន្ធលើប្រាក់ចំណូល

ពន្ធលើប្រាក់ចំណូល ឬ ខាតក្នុងការិយបរិច្ឆេទរួមមានពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ និងពន្ធពន្យារ។ ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬ ខាត លើកលែងតែក្នុងករណីដែលវាទាក់ទងទៅនឹងសមាសធាតុ ដែលត្រូវទទួលស្គាល់ជាផ្នែកមួយនៃមូលធន ក្នុងករណីនេះវាក៏ត្រូវបានកំណត់បង្ហាញជាផ្នែកមួយនៃមូលធនផងដែរ។

ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងទុកថា ត្រូវបង់ទៅលើប្រាក់ចំណូលជាប់ពន្ធក្នុងការិយបរិច្ឆេទដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬ បានអនុម័តជាអាទីនៅនាកាលបរិច្ឆេទរាយការណ៍ ជាមួយនឹងនិយ័តភាពណាមួយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ។

ពន្ធពន្យារត្រូវបានកត់ត្រាតាមវិធីសាស្រ្តតារាងតុល្យការទៅលើភាពលំអៀងជាបណ្តោះអាសន្នរវាងតម្លៃ យោងនៃទ្រព្យសកម្ម និងបំណុលក្នុងគោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងប្រើសម្រាប់ការគិតពន្ធ។

តម្លៃនៃប្រាក់ពន្ធពន្យារដែលបានកំណត់នោះ គឺផ្អែកលើលក្ខណៈនៃការជឿជាក់នឹងទទួលបាន ឬការទូទាត់ ដែលនឹងកើតឡើងរវាងតម្លៃសុទ្ធនៃទ្រព្យសកម្ម និងបំណុលដោយប្រើអត្រាពន្ធកំណត់នៅនាកាលបរិច្ឆេទរាយការណ៍ ។

ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានទទួលស្គាល់ តែក្នុងករណីអាចនឹងកើតមានឡើងទៅលើប្រាក់ចំណេញ ជាប់ពន្ធនាពេលអនាគត ដែលអាចប្រើប្រាស់ជាមួយនឹងទ្រព្យសកម្ម។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានកាត់បន្ថយក្នុងករណីដែលវាមិនអាចកើតឡើងនូវអត្ថប្រយោជន៍នៃពន្ធដែលពាក់ព័ន្ធដែលអាចនឹងប្រើប្រាស់បាន។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

### ៣.១២. ទុនបម្រុងតាមបទប្បញ្ញត្តិ

ស្របតាមប្រកាសនៃធនាគារជាតិនៃកម្ពុជា លេខ ធ៧-០១៧-៣៤៤ ស្តីពីចំណាត់ថ្នាក់ហានិភ័យ ឥណទាន និងសំវិធានធនលើអ៊ីមភែរមិន កម្រិតអ៊ីមភែរមិនគណនា អនុលោមតាមសំវិធានធនបទប្បញ្ញត្តិ ដែលខ្ពស់ជាងកម្រិតអ៊ីមភែរមិនដែលគណនាអនុលោមតាម CIFRS នឹងត្រូវផ្ទេរពី គណនីចំណេញ ឬ ខាតបង្គរទៅទុនបម្រុងតាមបទប្បញ្ញត្តិ (កំណត់សម្គាល់លេខ ២១)។

### ៣.១៣. សម្ព័ន្ធញាតិ

ភាគីដែលត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិរបស់ធនាគារ ប្រសិនបើភាគីនោះមានលទ្ធភាពគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលលើភាគីមួយទៀត ឬមានឥទ្ធិពលយ៉ាងខ្លាំងទៅលើភាគីនេះក្នុងការធ្វើសេចក្តីសម្រេចលើផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការ ឬ បញ្ច្រាសមកវិញ។ ដូចគ្នានេះដែរ ប្រសិនបើធនាគារ និងភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួមមួយ ឬក៏មានឥទ្ធិពលយ៉ាងខ្លាំង។ សម្ព័ន្ធញាតិអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល និងរួមបញ្ចូលនូវរូបវន្តបុគ្គលណាម្នាក់នៃសមាជិកគ្រួសារដែលជិតស្និទ្ធ ក៏ត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិដែរ។

# ៤ ការវិនិច្ឆ័យ និងការប៉ាន់ស្មានគណនេយ្យសំខាន់ៗ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារដោយអនុលោមតាម CIFRSs ទាមទារឲ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យការប៉ាន់ស្មាន និងការសន្មតដែលប៉ះពាល់ដល់ចំនួនទឹកប្រាក់ និងការបង្ហាញនៃទ្រព្យសកម្ម និងទ្រព្យអសកម្មអំឡុងពេលការិយបរិច្ឆេទហិរញ្ញវត្ថុ និងចំនួនទឹកប្រាក់ដែលបានរាយការណ៍ និងដាក់បង្ហាញនូវចំណូល និងចំណាយនៅក្នុងការិយបរិច្ឆេទ។ លទ្ធផលនៃការវិនិច្ឆ័យគណនេយ្យ និងការប៉ាន់ស្មានតាមនិយមន័យស្មើរតែមិនស្មើរនឹងលទ្ធផលជាក់ស្តែង។

ការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មត នឹងត្រូវបន្តវាយតម្លៃអាស្រ័យលើបទពិសោធន៍ និងកត្តាផ្សេងទៀត រួមបញ្ចូលទាំងការរំពឹងទុកនាពេលអនាគតដែលសមហេតុផលនឹងជឿទុកចិត្តបាន។

### ៤.១. ការវិនិច្ឆ័យ

ចំនុចបន្ទាប់នេះនឹងបង្ហាញពីកត្តាសំខាន់ក្នុងការវិនិច្ឆ័យ ដែលជាផ្នែកមួយក្នុងការធ្វើការប៉ាន់ស្មាន (កំណត់សម្គាល់លេខ ៤.២) ដែលគណៈគ្រប់គ្រងបានប្រើនូវគោលនយោបាយគណនេយ្យរបស់ធនាគារ និងមានផលមានប៉ះពាល់យ៉ាងខ្លាំងទៅលើចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

#### (i) ការកើនឡើងគួរឲ្យកត់សំគាល់នូវហានិភ័យឥណទាន

ដូចបានពន្យល់ក្នុងកំណត់សម្គាល់លេខ ៣ ECL គឺជាវាស់វែង ដោយសមវិធានធនស្មើនឹង ECL ១២ខែ សម្រាប់ទ្រព្យសកម្មដំណាក់កាលទី ១ ឬ ECL ពេញមួយកាលវសាន សម្រាប់ទ្រព្យសកម្មដំណាក់កាលទី ២ ឬ ដំណាក់កាលទី ៣។ ទ្រព្យសកម្មឈានដល់ដំណាក់កាលទី ២ នៅពេលដែលហានិភ័យឥណទាន មានការកើនឡើងយ៉ាងខ្លាំងតាំងពីការទទួលស្គាល់ដំបូង។ CIFRS ៩ មិនបានកំណត់ទៅលើធាតុមួយណាដែលធ្វើឲ្យមានការកើនឡើងខ្លាំង។ ដូច្នេះក្នុងការវាយតម្លៃ ថាតើហានិភ័យឥណទាននៃទ្រព្យសកម្មបានកើនឡើងគួរឲ្យកត់សម្គាល់នោះ ធនាគារបានគិតគូរពីគុណភាព បរិមាណ និងព័ត៌មានដែលអាចមើលទៅមុខបាន។

#### (ii) ការវាយតម្លៃគំរូអាជីវកម្ម

ចំណាត់ថ្នាក់ និង ការវាស់វែងនៃទ្រព្យសកម្មហិរញ្ញវត្ថុ អាស្រ័យលើលទ្ធផលនៃ SPPI និងការធ្វើតេស្តគំរូអាជីវកម្ម។ ធនាគារកំណត់គំរូអាជីវកម្មនៅកម្រិតមួយដែលឆ្លុះបញ្ចាំងពីរបៀបដែលក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានគ្រប់គ្រងជាមួយគ្នា ដើម្បីសម្រេចបាននូវគោលដៅអាជីវកម្មជាក់លាក់។ ការវាយតម្លៃនេះរួមបញ្ចូលទាំងរបៀបដែលលទ្ធផលនៃទ្រព្យត្រូវបានវាយតម្លៃ និងសន្មតហានិភ័យដែលប៉ះពាល់ដល់ការអនុវត្តទ្រព្យសកម្ម និងរបៀបនៃការគ្រប់គ្រង និងរបៀបដែលអ្នកគ្រប់គ្រងទ្រព្យសកម្មត្រូវបានទូទាត់សង។

ធនាគារត្រួតពិនិត្យទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែងដោយចំណាយរំលស់ ឬតម្លៃសមស្រប តាមរយៈប្រាក់ចំណូលលម្អិតផ្សេងទៀត





## ៤. ការវិនិច្ឆ័យ ការប៉ាន់ស្មាន គណនេយ្យសំខាន់ៗ(តពីទំព័រមុន)

### ៤.១. ការវិនិច្ឆ័យ (តពីទំព័រមុន)

#### (ii) ការវាយតម្លៃគំរូអាជីវកម្ម (តពីទំព័រមុន)

ដែលត្រូវបានគេទទួលស្គាល់មុនកាលកំណត់ ដើម្បីស្វែងយល់ពីហេតុផលនៃការជំរុះចោលរបស់ពួកគេ ដោយគិតថាទ្រព្យសកម្មទាំងនោះត្រូវបានកាន់កាប់សមហេតុផលទៅនឹងគោលបំណងរបស់អាជីវកម្មឬទេ ។ ការត្រួតពិនិត្យ គឺជាផ្នែកមួយនៃការវាយតម្លៃជាបន្តរបស់ធនាគារដោយគិតថាគំរូអាជីវកម្មដែលទ្រទ្រង់ទ្រព្យសកម្មហិរញ្ញវត្ថុដែលនៅសេសសល់ នៅតែបន្តមានលក្ខណៈសមរម្យ និងហានិភ័យដែលជះឥទ្ធិពលដល់ការអនុវត្តទ្រព្យសម្បត្តិ និងរបៀបដែលការគ្រប់គ្រងទាំងនេះ និងរបៀបដែលអ្នកគ្រប់គ្រងទ្រព្យសម្បត្តិត្រូវបានទូទាត់សង។

#### (iii) ការបង្កើតក្រុមនៃទ្រព្យសកម្មដែលមានលក្ខណៈហានិភ័យឥណទានស្រដៀងគ្នា

នៅពេលដែល ECLs ត្រូវបានវាស់វែងជាមូលដ្ឋានសមូហភាពឧបករណ៍ហិរញ្ញវត្ថុត្រូវបានដាក់ជាក្រុមផ្អែកលើលក្ខណៈហានិភ័យរួម។ កំណត់សម្គាល់ ៣.២ បានរៀបរាប់លម្អិតអំពីលក្ខណៈដែលបានពិចារណានៅក្នុងការវិនិច្ឆ័យនេះ។ ធនាគារត្រួតពិនិត្យ លើភាពសមស្របអំពីចរិកលក្ខណៈហានិភ័យឥណទានតាមមូលដ្ឋានវាយតម្លៃជាបន្តបន្ទាប់ ប្រសិនបើទ្រព្យសកម្មទាំងនោះ នៅមានចរិកលក្ខណៈស្រដៀងគ្នា។ នេះត្រូវបានទាមទារដើម្បីធានាថាគួរតែមានការផ្លាស់ប្តូរលក្ខណៈហានិភ័យនៃឥណទាន មានការបែងចែកឡើងវិញនូវទ្រព្យសកម្មសមស្រប។ នេះអាចបណ្តាលឲ្យផលប័ត្រថ្មីកំពុងត្រូវបានបង្កើតឡើង ឬ ទ្រព្យសម្បត្តិដែលផ្លាស់ប្តូរទៅតាមផលប័ត្រដែលមានស្រាប់ អាចឆ្លុះបញ្ចាំងឲ្យកាន់តែប្រសើរឡើង នូវលក្ខណៈហានិភ័យឥណទានស្រដៀងគ្នានៃក្រុមទ្រព្យសកម្មនោះ។

ការបែងចែកជាផ្នែក និងការផ្លាស់ប្តូរនូវបណ្តុំទ្រព្យសកម្ម គឺជារឿងធម្មតានៅពេលមានការកើនឡើងខ្លាំងនូវហានិភ័យឥណទាន (ឬនៅពេលដែលការកើនឡើងខ្លាំងនេះ ត្រូវបានធ្លាក់ចុះមកវិញ ) ហើយដូច្នេះទ្រព្យសកម្មផ្លាស់ប្តូរពី ១២ ខែទៅ ECL ពេញមួយជីវិត ឬ ផ្ទុយទៅវិញ ប៉ុន្តែវាក៏អាចកើតឡើងក្នុងផលប័ត្របន្ត ដើម្បីវិនិច្ឆ័យទៅលើមូលដ្ឋានដូចគ្នា នៃ១២ ខែ ឬ ECL ពេញមួយជីវិត ប៉ុន្តែចំនួន ECL មានការផ្លាស់ប្តូរពីព្រោះហានិភ័យឥណទានរបស់ផលប័ត្រមានលក្ខណៈខុសគ្នា។

#### (iv) គំរូ និងការសន្មតដែលបានប្រើ

ធនាគារប្រើគំរូ និងការសន្មតផ្សេងៗគ្នាក្នុងការវាស់តម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុក៏ដូចជាក្នុងការប៉ាន់ស្មាន ECL។ ការវិនិច្ឆ័យត្រូវបានអនុវត្តក្នុងការកំណត់គំរូសមស្របបំផុតសម្រាប់ប្រភេទទ្រព្យនីមួយៗ ក៏ដូចជាសម្រាប់កំណត់ការសន្មតដែលបានប្រើនៅក្នុងគំរូទាំងនេះ រួមទាំងការសន្មតដែលទាក់ទងនឹងកត្តាជំរុញនៃហានិភ័យឥណទាន។

### ៤.២. ការប៉ាន់ស្មាន

ការសន្មតសំខាន់ៗ ទាក់ទងនឹងអនាគតនិងប្រភពគន្លឹះផ្សេងទៀតនៃការប៉ាន់ស្មាន លើភាពមិនច្បាស់លាស់ ត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ដែលមានហានិភ័យគួរឲ្យកត់សម្គាល់ ក្នុងការធ្វើឲ្យការកែប្រែជាសារវន្តលើតម្លៃយោងទ្រព្យសកម្ម និងទ្រព្យអសកម្មក្នុងឆ្នាំហិរញ្ញវត្ថុបន្ទាប់ត្រូវបានពណ៌នាដូចខាងក្រោម៖

ធនាគារផ្អែកលើការសន្មតនិងការប៉ាន់ស្មានរបស់ខ្លួនលើប៉ារ៉ាម៉ែត្រដែលមានស្រាប់នាពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ កាលៈទេសៈកើតឡើង និងការសន្មត អំពីការវិវត្តនាពេលអនាគត។ ក៏ប៉ុន្តែ ប្រសិនបើមានការប្រែប្រួល បណ្តាលពីស្ថានភាពទីផ្សារឬកាលៈទេសៈណាមួយលើសពីការគ្រប់គ្រងរបស់ធនាគារ។ បម្រែបម្រួលទាំងនោះ នឹងឆ្លុះបញ្ចាំងក្នុងការប៉ាន់ស្មាននៅពេលដែលវាកើតឡើង។

#### (i) ពន្ធ

ពន្ធ ត្រូវបានគណនាផ្អែកលើមូលដ្ឋាននៃច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារនិងការបកស្រាយបច្ចុប្បន្ន។ ទោះបីយ៉ាងណាក្តីបទប្បញ្ញត្តិទាំងនេះអាចមានការប្រែប្រួលតាមអំឡុងពេលណាមួយ ហើយការសម្រេចចុងក្រោយនៃការចំណាយពន្ធ នឹងត្រូវធ្វើឡើងបន្ទាប់ពីមានការត្រួតពិនិត្យដោយអគ្គនាយកដ្ឋានពន្ធដារ (“GDT”)។ លិខិតប្រកាសពន្ធរបស់ធនាគារត្រូវស្ថិតក្រោមការត្រួតពិនិត្យតាមកាលកំណត់ដោយ GDT។

ដោយសារការអនុវត្តច្បាប់ពន្ធនិងបទប្បញ្ញត្តិចំពោះប្រតិបត្តិការជាច្រើនប្រភេទ ងាយនឹងមានការបកស្រាយខុសៗគ្នា បរិមាណដែលបានរាយការណ៍ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុអាចត្រូវបានផ្លាស់ប្តូរនៅពេលក្រោយតាមការសំរេចចុងក្រោយដោយ GDT។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់រាល់ការខាតពន្ធដែលពុំទាន់បានប្រើប្រាស់ និងភាពខុសគ្នាបណ្តោះអាសន្នត្រឹមកម្រិតប្រហាក់ប្រហែល ដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតដែលអាចមាន ដើម្បីប្រើប្រាស់ទូទាត់ជាមួយការខាតទាំងនោះ។ ការវិនិច្ឆ័យក្នុងការគ្រប់គ្រងចំាបាច់ត្រូវធ្វើឡើងក្នុងការកំណត់បរិមាណនៃពន្ធពន្យារជាទ្រព្យសកម្ម ដែលអាចទទួលស្គាល់បាន ដោយពឹងផ្អែកលើពេលវាលា និងកម្រិតនៃចំណូលជាប់ពន្ធនាពេលអនាគត ជាមួយនឹងផែនការយុទ្ធសាស្រ្តពន្ធនាពេលអនាគត។

## ៤. ការវិនិច្ឆ័យ ការប៉ាន់ស្មាន គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

## ៤.២ ការប៉ាន់ស្មាន (តពីទំព័រមុន)

### (ii) ការសម្រេចនូវ បរិមាណ និងការវាស់វែងលើទិដ្ឋភាពនាពេលអនាគតពាក់ព័ន្ធ សម្រាប់ប្រភេទផលិតផលឬទីផ្សារនីមួយៗ និងការកំណត់ព័ត៌មានឆ្ពោះទៅមុខពាក់ព័ន្ធនឹងទិដ្ឋភាពនីមួយៗ៖

នៅពេលវាស់វែង ECL ធនាគារប្រើប្រាស់ព័ត៌មានឆ្ពោះទៅមុខ ដោយសមហេតុផលនិងអាចទុកចិត្តបាន ដែលផ្អែកលើការសន្មត លើបម្រែបម្រួលលើកត្តាសេដ្ឋកិច្ចផ្សេងៗនាពេលអនាគត និងថាតើកត្តាទាំងនេះនឹងមានឥទ្ធិពលលើគ្នាយ៉ាងដូចម្តេច។ កំណត់សម្គាល់ ៣.២ នឹងផ្តល់នូវព័ត៌មានលម្អិតបន្ថែមទៀតអំពីការប៉ាន់ស្មានលើព័ត៌មានឆ្ពោះទៅមុខ។

### (iii) ភវនីយភាពលើឥណទានខូច (PD)

PD គឺជាធាតុមួយដ៏សំខាន់ក្នុងការវាស់វែង ECL។ PD គឺជាការប៉ាន់ប្រមាណ នៃភវនីយភាព លើការខាតបង់ក្នុងអំឡុងពេលផ្តេកមួយ ការគណនាត្រូវបានរួមបញ្ចូលទិន្នន័យ នៃបទពិសោធន៍ពីមុនមក ការសន្មត និងការរំពឹងទុកនៃលក្ខខណ្ឌនាពេលអនាគត។ កំណត់សម្គាល់លេខ ៣.២ នឹងផ្តល់នូវព័ត៌មានលម្អិតបន្ថែមទៀតរួមមានទាំង ការវិភាគអំពីបម្រែបម្រួលរបស់ ECL ដែលបានរាយការណ៍នេះទៅនឹងការផ្លាស់ប្តូរ PD ដែលបណ្តាលមកពីការផ្លាស់ប្តូរនៃកត្តាសេដ្ឋកិច្ច។

### (iv) ការខាតបង់លើឥណទានខូច (LGD)

LGD គឺជាការប៉ាន់ស្មានមួយលើការខាតបង់របស់ឥណទានខូច។ វាផ្អែកលើភាពខុសគ្នារវាង លំហូរសាច់ប្រាក់ត្រូវទទួលបានតាមកិច្ចសន្យា និង សាច់ប្រាក់ដែលម្ចាស់បំណុលរំពឹងនឹងទទួលបាន ដែលក្នុងនោះគិតបញ្ចូលទាំងលំហូរសាច់ប្រាក់នឹងបានពីវត្ថុបញ្ចាំ និងឧបករណ៍ពង្រឹងឥណទានដទៃ។ កំណត់សម្គាល់ ៣.២ នឹងផ្តល់នូវព័ត៌មានលម្អិតបន្ថែមទៀតរួមមានការវិភាគអំពីបម្រែបម្រួលរបស់ ECL ដែលបានរាយការណ៍នេះ ទៅនឹងការផ្លាស់ប្តូរ LGD ដែលបណ្តាលមកពីការផ្លាស់ប្តូរនៃកត្តាសេដ្ឋកិច្ច។





# មូលប្បទានប័ត្រ និងសាច់ប្រាក់ក្នុងដៃ

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| មូលប្បទានប័ត្រក្នុងដៃ | 500,000 | 2,037,000 | 8,650,000 | 34,989,250 |
| សាច់ប្រាក់ក្នុងដៃ | | | | |
| ដុល្លារអាមេរិក | 6,507,142 | 26,510,097 | 4,850,996 | 19,622,279 |
| ប្រាក់រៀល | 73,163 | 298,066 | 117,362 | 474,729 |
| | **7,080,305** | **28,845,163** | **13,618,358** | **55,086,258** |

សម្រាប់គោលបំណង នៃរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ក្នុងដៃ និងសាច់ប្រាក់សមមូល មានដូចជា៖

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| មូលប្បទានប័ត្រ និង សាច់ប្រាក់ក្នុងដៃ | 7,080,305 | 28,845,163 | 13,618,358 | 55,086,258 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 5,529,115 | 22,525,615 | 9,080,661 | 36,731,274 |
| សមតុល្យនៅធនាគារដទៃ | 7,920,988 | 32,270,105 | 6,902,648 | 27,921,211 |
| | **20,530,408** | **83,640,883** | **29,601,667** | **119,738,743** |

# សមតុល្យនៅធនាគារជាតិនៃកម្ពុជា

សមតុល្យ នៅធនាគារជាតិនៃកម្ពុជា មានជាដុល្លារអាមេរិក និងប្រាក់រៀលដូចខាងក្រោម៖

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| គណនីចរន្ត | | | | |
| ដុល្លារអាមេរិក | 2,421,508 | 9,865,224 | 9,060,284 | 36,648,849 |
| ប្រាក់រៀល | 3,097,737 | 12,620,181 | 10,462 | 42,319 |
| គណនីទូទាត់ | 9,870 | 40,210 | 9,916 | 40,110 |
| មូលបត្រអាចជួញដូរបាន ("NCDs") ដែលមានកាលកំណត់លើស 3 ខែ | 49,092 | 200,001 | 4,049,444 | 16,380,001 |
| ការប្រាក់បង្គរដែលនឹងទទួលពី NCDs | 574 | 2,338 | 1,408 | 5,695 |
| | **5,578,781** | **22,727,954** | **13,131,514** | **53,116,974** |
| សំវិធានធនលើ ECLs | (6,696) | (27,280) | (15,760) | (63,749) |
| | **5,572,085** | **22,700,674** | **13,115,754** | **53,053,225** |







# សមតុល្យនៅធនាគារដទៃ

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| គណនីចរន្ត | 7,692,790 | 31,340,426 | 6,222,519 | 25,170,089 |
| គណនីសន្សំ | 228,198 | 929,679 | 680,129 | 2,751,122 |
| បញ្ញើមានកាលកំណត់ | 2,718,213 | 11,074,000 | 1,000,000 | 4,045,000 |
| ការប្រាក់បង្គរដែលនឹងទទួលបាន | 17,480 | 71,214 | 9,192 | 37,182 |
| | **10,656,681** | **43,415,319** | **7,911,840** | **32,003,393** |
| សំវិធានធនលើ ECLs | (12,522) | (51,015) | (8,872) | (35,887) |
| | **10,644,159** | **43,364,304** | **7,902,968** | **31,967,506** |

សមតុល្យទាំងនេះ គឺជាគណនីប្រាក់រៀល និងដុល្លារអាមេរិក ដែលទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំចាប់ពី០% ទៅ ៣.២៥% (២០២០៖ ០% ទៅ ២.៧៥%)។

# ឥណទាន និងបុរេប្រទានទៅអតិថិជន - សុទ្ធ

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| **ឥណទានពាណិជ្ជកម្ម** | | | | |
| ឥណទានរយៈពេលខ្លី | - | - | 4,320,067 | 17,474,671 |
| ឥណទានរយៈពេលវែង | 210,004,329 | 855,557,636 | 106,417,191 | 430,457,538 |
| ឥណទានវិបារូបន៍ | 7,677,135 | 31,276,648 | 3,848,280 | 15,566,293 |
| **ឥណទានអ្នកប្រើប្រាស់** | | | | |
| ឥណទានគេហដ្ឋាន | 30,254,049 | 123,254,996 | 15,224,236 | 61,582,035 |
| ឥណទានមានកាលកំណត់ | 1,422,281 | 5,794,373 | 581,636 | 2,352,717 |
| **សរុបឥណទាន និងបុរេប្រទានដល់អតិថិជន - ដុល** | **249,357,794** | **1,015,883,653** | **130,391,410** | **527,433,254** |
| កម្រៃដំណើរការផ្តល់ឥណទានពុំទាន់រំលស់ | (1,191,833) | (4,855,528) | (721,645) | (2,919,054) |
| **តម្លៃយោង** | **248,165,961** | **1,011,028,125** | **129,669,765** | **524,514,200** |
| សំវិធានធនលើ ECLs | (119,864) | (488,326) | (13,981) | (56,554) |
| **សរុបឥណទាន និងបុរេប្រទាន - សុទ្ធ** | **248,046,097** | **1,010,539,799** | **129,655,784** | **524,457,646** |

សំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុក លើឥណទាន និងបុរេប្រទានទៅអតិថិជន មានដូចខាងក្រោម៖

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| ដំណាក់កាលទី 1 | 119,864 | 488,326 | 13,981 | 56,554 |
| ដំណាក់កាលទី 2 | - | - | - | - |
| ដំណាក់កាលទី 3 | - | - | - | - |
| **សរុប** | **119,864** | **488,326** | **13,981** | **56,554** |

ការវិភាគបន្ថែមនៃឥណទាន និងបុរេប្រទានទៅអតិថិជនមានដូចខាងក្រោម៖

(i) ចំណាត់ថ្នាក់របស់ឥណទាន ដុល

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| ដំណាក់កាលទី 1 | 249,357,794 | 1,015,883,653 | 130,391,410 | 527,433,254 |
| ដំណាក់កាលទី 2 | - | - | - | - |
| ដំណាក់កាលទី 3 | - | - | - | - |
| **សរុប** | **249,357,794** | **1,015,883,653** | **130,391,410** | **527,433,254** |

(ii) សំដៅទៅកំណត់សម្គាល់លេខ ៣០.២ ការវិភាគលើហានិភ័យឥណទាន នៃគុណភាពឥណទាន។

(iii) សំដៅទៅ កំណត់សម្គាល់លេខ ៣០.២ ការវិភាគលើកាលកំណត់ប្រភេទរូបិយប័ណ្ណទ្រព្យធានា និវាសនដ្ឋានទំនាក់ទំនង និងទំហំហានិភ័យ។

(iv) វិភាគតាមអត្រាការប្រាក់ (ប្រចាំឆ្នាំ)៖

| | ២០២១ | ២០២០ |
|---|---|---|
| អត្រាការប្រាក់ | 7.0% - 14.4% | 7.5% - 9.5% |





# មូលបត្រដែលត្រូវទទួល

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| មូលបត្រដែលត្រូវទទួល | 1,000,000 | 4,074,000 | - | - |
| ការប្រាក់បង្គរដែលត្រូវទទួល | 17,329 | 70,598 | - | - |
| | **1,017,329** | **4,144,598** | **-** | **-** |
| សំវិធានធនលើ ECLs | (127) | (517) | - | - |
| | **1,017,202** | **4,144,081** | **-** | **-** |

នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ ធនាគារបានទិញមូលបត្រ តម្លៃ១.០០លានដុល្លាអាមេរិក ដែលមានអត្រាថេរ និងការធានា ដោយមានកាលបរិច្ឆេទកំណត់សង នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៤។ មូលបត្រនេះត្រូវបានធានាដោយក្រុមហ៊ុនអូរើស៊ី ខេមបូឌាន អ៊ិនវេសមេន ខបភើរេសិន។ មូលបត្រនេះ ទទួលបានអត្រាការប្រាក់ ៥.៥០% ក្នុងមួយឆ្នាំ និងត្រូវសងជាប្រចាំឆ្នាំចាប់ផ្តើមថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២ ទៅ។ ធនាគារ មិនមានចំណាយលើការទិញបំណុលនោះទេ។

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ធនាគារបានទទួលចំណូលការប្រាក់ចំនួន ១៧,៣២៩ ដុល្លាអាមេរិក (កំណត់សម្គាល់លេខ ២២)។

# ទ្រព្យសកម្មផ្សេងៗ

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| ប្រាក់កក់ | 687,587 | 2,801,229 | 113,844 | 460,499 |
| ចំណាយបង់មុន | 86,169 | 351,053 | 11,841 | 47,897 |
| ទ្រព្យសកម្មផ្សេងៗ | 43,063 | 175,439 | 2,368 | 9,578 |
| | **816,819** | **3,327,721** | **128,053** | **517,974** |

# ប្រាក់តម្កល់តាមច្បាប់

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| ប្រាក់ធានាលើដើមទុន | 7,750,000 | 31,573,500 | 7,750,000 | 31,348,750 |
| ទុនបម្រុង | 9,215,601 | 37,544,358 | 3,209,938 | 12,984,199 |
| | **16,965,601** | **69,117,858** | **10,959,938** | **44,332,949** |

## *ប្រាក់ធានាលើដើមទុន*

ស្របតាមប្រកាសលេខ ធ៧-០១-១៣៦ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ធនាគារតម្រូវឲ្យតម្កល់ប្រាក់ធានាលើដើមទុន ស្មើនឹង ១០% នៃដើមទុនចុះបញ្ជី នៅឯធនាគារជាតិនៃកម្ពុជា។

ប្រាក់បញ្ញើនេះ មិនត្រូវបានប្រើប្រាស់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារទេ ហើយអាចដកមកវិញបាន នៅពេលធនាគារបញ្ឈប់ប្រតិបត្តិការអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ប្រាក់តម្កល់តាមច្បាប់ ទទួលបានការប្រាក់ក្នុងអត្រាចន្លោះពី ០.០៤% ទៅ ០.០៩% ប្រចាំឆ្នាំ (២០២០៖ ចន្លោះពី ០.០៦% ទៅ ០.៤៨% ប្រចាំឆ្នាំ)។

## ១១. ប្រាក់តម្កល់តាមច្បាប់ (តពីទំព័រមុន)

*ប្រាក់បម្រុងកាតព្វកិច្ច*

យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ B៧-០២០-២៣០ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ធនាគារពាណិជ្ជកម្មត្រូវរក្សាប្រាក់បម្រុងនៅធនាគារជាតិនៃកម្ពុជា ក្នុងទម្រង់ជាបញ្ញើកាតព្វកិច្ច ដែលគណនាតាមអត្រា ៧.០% នៃប្រាក់បញ្ញើអតិថិជន និងប្រាក់កម្ចីជាជារូបិយវត្ថុប្រាក់រៀលនិងរូបិយប័ណ្ណផ្សេងទៀត។

### សូហ្វវែរ

| | សូហ្វវែរកុំព្យូទ័រ | សូហ្វវែរមិនទាន់បញ្ចប់ | សរុប |
|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **2021** | | | |
| **តម្លៃដើម** | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2021 | 809,857 | 48,000 | 857,857 |
| ការទិញបន្ថែម | 2,845,115 | 305,944 | 3,151,059 |
| ការផ្ទេរ | 48,000 | (48,000) | - |
| ការលុបចោល | (875,641) | - | (875,641) |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | **2,827,331** | **305,944** | **3,133,275** |
| **រំលស់បង្គរ** | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2021 | 447,631 | - | 447,631 |
| រំលស់ក្នុងការិយបរិច្ឆេទ | 177,717 | - | 177,717 |
| ការលុបចោល | (555,528) | - | (555,528) |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | **69,820** | **-** | **69,820** |
| **តម្លៃយោងគណនេយ្យ** | | | |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | **2,757,511** | **305,944** | **3,063,455** |
| **សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.3)** | **11,234,100** | **1,246,416** | **12,480,516** |
| **2020** | | | |
| **តម្លៃដើម** | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2020 | 484,916 | 165,137 | 650,053 |
| ការទិញបន្ថែម | 209,759 | - | 209,759 |
| ការផ្ទេរ | 117,137 | (117,137) | - |
| ការលក់ | (1,955) | - | (1,955) |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 | **809,857** | **48,000** | **857,857** |
| **រំលស់បង្គរ** | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2020 | 292,245 | - | 292,245 |
| រំលស់ក្នុងការិយបរិច្ឆេទ | 156,461 | - | 156,461 |
| ការលក់ | (1,075) | - | (1,075) |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 | **447,631** | **-** | **447,631** |
| **តម្លៃយោងគណនេយ្យ** | | | |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 | **362,226** | **48,000** | **410,226** |
| **សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.3)** | **1,465,204** | **194,160** | **1,659,364** |





### ទ្រព្យ និងបរិក្ខារ

| | ការជួសជុលកែលំអ | គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ | បរិក្ខារ | បរិក្ខារព័ត៌មានវិទ្យា | យានយន្ត | សរុប |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **2021** | | | | | | |
| **តម្លៃដើម** | | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2021 | 816,795 | 51,457 | 224,341 | 78,416 | 218,321 | 1,389,330 |
| ការទិញបន្ថែម | 5,225 | 15,756 | 92,263 | 996,226 | - | 1,109,470 |
| ការលក់ | - | (546) | - | - | - | (546) |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | **822,020** | **66,667** | **316,604** | **1,074,642** | **218,321** | **2,498,254** |
| **រំលស់បង្គរ** | | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2021 | 710,959 | 45,330 | 153,474 | 30,901 | 187,703 | 1,128,367 |
| រំលស់ក្នុងឆ្នាំ | 103,726 | 5,114 | 41,325 | 37,254 | 29,307 | 216,726 |
| ការលក់ | - | (546) | - | - | - | (546) |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | **814,685** | **49,898** | **194,799** | **68,155** | **217,010** | **1,344,547** |
| **តម្លៃយោងគណនេយ្យ** | | | | | | |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | **7,335** | **16,769** | **121,805** | **1,006,487** | **1,311** | **1,153,707** |
| **សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.3)** | **29,883** | **68,317** | **496,234** | **4,100,427** | **5,341** | **4,700,202** |
| **2020** | | | | | | |
| **តម្លៃដើម** | | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2020 | 816,795 | 49,067 | 188,755 | 60,033 | 216,571 | 1,331,221 |
| ការទិញបន្ថែម | - | 2,390 | 37,221 | 35,987 | 1,750 | 77,348 |
| ការលក់ | - | - | (1,635) | (17,604) | - | (19,239) |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 | **816,795** | **51,457** | **224,341** | **78,416** | **218,321** | **1,389,330** |
| **រំលស់បង្គរ** | | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2020 | 547,457 | 35,847 | 115,221 | 32,214 | 144,320 | 875,059 |
| រំលស់ក្នុងឆ្នាំ | 163,502 | 9,483 | 39,495 | 14,768 | 43,383 | 270,631 |
| ការលក់ | - | - | (1,242) | (16,081) | - | (17,323) |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 | **710,959** | **45,330** | **153,474** | **30,901** | **187,703** | **1,128,367** |
| **តម្លៃយោងគណនេយ្យ** | | | | | | |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 | **105,836** | **6,127** | **70,867** | **47,515** | **30,618** | **260,963** |
| **សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.3)** | **428,107** | **24,784** | **286,656** | **192,198** | **123,850** | **1,055,595** |

# ភតិសន្យា

## *សិទ្ធិលើការប្រើប្រាស់ទ្រព្យសកម្ម*

ធនាគារបានជួលទ្រព្យសកម្មផ្សេងៗ រួមមានម៉ាស៊ីនហ្វូតូកូពី យានយន្ត និងការិយាល័យសម្រាប់រយៈពេលចាប់ពី ១ ទៅ ១០ឆ្នាំ ដែលអាចនឹងបន្តជាថ្មីឡើងវិញ ដោយមានការឯកភាពពីភាគីទាំងសងខាង។

ធនាគារបានអនុវត្ត ការលើកលែងការទទួលស្គាល់ចំពោះ 'ភតិសន្យារយៈពេលខ្លី' និង 'ភតិសន្យា នៃទ្រព្យសកម្មដែលមានតម្លៃទាប' ទៅលើម៉ាស៊ីនហ្វូតូកូពី និង យានយន្តរបស់ខ្លួន។ ចំណាយការជួលលើភតិសន្យាទ្រព្យសកម្មមានរយៈពេលខ្លី ត្រូវបានទទួលស្គាល់ក្នុងគណនេយ្យចំណាយប្រតិបត្តិការផ្សេងៗ (កំណត់សម្គាល់លេខ ២៥)។

បង្ហាញខាងក្រោមគឺជាតម្លៃយោងនៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្មដែលបានទទួលស្គាល់ និងទ្រព្យអសកម្មភតិសន្យា និងការប្រែប្រួលនៅក្នុងការិយបរិច្ឆេទ៖

**សិទ្ធិលើការប្រើប្រាស់ ទ្រព្យសកម្ម**

| | ២០២១ | | ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| **តម្លៃដើម** | | | | |
| នាថ្ងៃទី1 ខែមករា | 593,554 | 2,400,926 | 593,554 | 2,418,733 |
| ការទិញ | 11,363,094 | 46,225,066 | - | - |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | 85,392 | - | (17,807) |
| នាថ្ងៃទី31 ខែធ្នូ | **11,956,648** | **48,711,384** | **593,554** | **2,400,926** |
| **រំលស់បង្គរ** | | | | |
| នាថ្ងៃទី1 ខែមករា | 478,141 | 1,934,080 | 379,216 | 1,545,306 |
| រំលស់ក្នុងការិយបរិច្ឆេទ | 218,268 | 887,914 | 98,925 | 403,317 |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | 15,176 | - | (14,543) |
| នាថ្ងៃទី31 ខែធ្នូ | **696,409** | **2,837,170** | **478,141** | **1,934,080** |
| **តម្លៃយោង** | | | | |
| នាថ្ងៃទី31 ខែធ្នូ | **11,260,239** | **45,874,214** | **115,413** | **466,846** |

**ទ្រព្យអសកម្មភតិសន្យា**

| | ២០២១ | | ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| នាថ្ងៃទី1 ខែមករា | 136,286 | 551,277 | 246,952 | 1,006,329 |
| ភតិសន្យាបន្ថែម | 10,824,620 | 44,034,554 | - | - |
| ការប្រាក់ពន្លាពីការធ្វើអប្បហារ | 68,246 | 277,625 | 9,334 | 38,055 |
| សាច់ប្រាក់ទូទាត់ | (158,035) | (642,886) | (120,000) | (489,240) |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | 68,361 | - | (3,867) |
| នាថ្ងៃទី31 ខែធ្នូ | **10,871,117** | **44,288,931** | **136,286** | **551,277** |





## ១៤. ភតិសន្យា (តពីទំព័រមុន)

**ទ្រព្យអសកម្មភតិសន្យា**

| | ២០២១ | | ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| ផ្នែកចរន្ត និងអចរន្ត | | | | |
| ផ្នែកចរន្ត | 252,579 | 1,029,007 | 116,328 | 470,547 |
| ផ្នែកអចរន្ត | 10,618,538 | 43,259,924 | 19,958 | 80,730 |
| | **10,871,117** | **44,288,931** | **136,286** | **551,277** |
| ការវិភាគលើកាលកំណត់-លំហូរសាច់ប្រាក់តាមកិច្ចសន្យាគ្មានអប្បហារ | | | | |
| តិចជាង 1ឆ្នាំ | 1,011,105 | 4,113,175 | 120,000 | 489,240 |
| 1 ទៅ 5ឆ្នាំ | 7,699,637 | 31,322,123 | 20,000 | 81,540 |
| លើសពី 5ឆ្នាំ | 16,066,355 | 65,357,932 | - | - |
| **ទ្រព្យអសកម្មភតិសន្យាគ្មានអប្បហារសរុប** | **24,777,097** | **100,793,230** | **140,000** | **570,780** |

### *តារាងខាងក្រោមនេះ បង្ហាញពីចំណាយទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬ ខាត៖*

| | ២០២១ | | ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| រំលស់លើសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | 218,268 | 887,914 | 98,925 | 403,317 |
| ភតិសន្យារយៈពេលខ្លី (កំណត់សម្គាល់លេខ 25) | 86,639 | 352,447 | 12,086 | 49,274 |
| ការប្រាក់ពន្លាពីការធ្វើអប្បហារ (កំណត់សម្គាល់លេខ 22) | 68,246 | 277,625 | 9,334 | 38,055 |
| ភតិសន្យានៃទ្រព្យសកម្មតម្លៃទាប (កំណត់សម្គាល់លេខ 25) | 9,679 | 39,375 | 775 | 3,160 |
| **ចំណាយភតិសន្យាសរុប** | **382,832** | **1,557,361** | **121,120** | **493,806** |

# ពន្ធលើប្រាក់ចំណេញ

## *(i) បំណុលពន្ធលើប្រាក់ចំណូល*

| | ២០២១ | | ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| នាថ្ងៃទី1 ខែមករា | 741,924 | 3,001,083 | 582,067 | 2,371,923 |
| ពន្ធលើប្រាក់ចំណូលក្នុងគ្រា | 1,177,930 | 4,791,819 | 795,091 | 3,241,586 |
| ពន្ធលើប្រាក់ចំណូលដែលបានបង់ | (896,170) | (3,645,620) | (635,234) | (2,589,849) |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | 23,207 | - | (22,577) |
| **នាថ្ងៃទី31 ខែធ្នូ** | **1,023,684** | **4,170,489** | **741,924** | **3,001,083** |

## ១៥. ពន្ធលើប្រាក់ចំណេញ (តពីទំព័រមុន)

### *(ii) ចំណាយពន្ធលើប្រាក់ចំណូល*

| | សម្រាប់ការិយបរិច្ឆេទ បញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | សម្រាប់ការិយបរិច្ឆេទ បញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| ពន្ធលើប្រាក់ចំណូលក្នុងគ្រា | 1,177,930 | 4,791,819 | 795,091 | 3,241,586 |
| ចំណូលលើពន្ធពន្យារ | (94,967) | (386,326) | (67,933) | (276,963) |
| **ចំណាយពន្ធលើប្រាក់ចំណូល** | **1,082,963** | **4,405,493** | **727,158** | **2,964,623** |

អនុលោមទៅតាមច្បាប់សារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ធនាគារមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូលដោយគណនាតាមអត្រា ២០% នៃប្រាក់ចំណេញជាប់ពន្ធ និង ពន្ធអប្បបរមា ដែលគណនាតាមអត្រា ១% នៃប្រាក់ចំណូលសរុប ដោយយកមួយណាដែលមានចំនួនធំជាងគេ។

ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណូល ដែលបានគណនាតាមអត្រាពន្ធ២០%ជាផ្លូវការទៅនឹងចំណាយពន្ធលើប្រាក់ចំណូល ដែលបង្ហាញក្នុងរបាយការណ៍ចំណេញ ឬខាត មានដូចខាងក្រោម៖

| | សម្រាប់ការិយបរិច្ឆេទ បញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | សម្រាប់ការិយបរិច្ឆេទ បញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| **ប្រាក់ចំណេញមុនដកពន្ធ** | **5,045,165** | **20,523,732** | **3,583,868** | **14,611,429** |
| ពន្ធលើប្រាក់ចំណូលផ្អែកតាមអត្រាពន្ធជាផ្លូវការ 20% | 1,009,033 | 4,104,746 | 716,774 | 2,922,288 |
| ចំណាយមិនអាចកាត់កងបាន | 73,930 | 300,747 | 10,384 | 42,335 |
| **ចំណាយពន្ធលើប្រាក់ចំណូល** | **1,082,963** | **4,405,493** | **727,158** | **2,964,623** |

### *(iii) ពន្ធពន្យារជាទ្រព្យសកម្ម*

ភាពខុសគ្នាបណ្តោះអាសន្ន ដែលបានទទួលស្គាល់ក្នុងការិយបរិច្ឆេទ ដែលបង្កឲ្យមានពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ មានដូចខាងក្រោម៖

| | ២០២១ | | ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.3) |
| កម្រៃដំណើការផ្តល់ឥណទានដែលពុំទាន់រំលស់ | 238,359 | 971,075 | 144,328 | 583,807 |
